ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី

មន្ទីរកិច្ចការនារីខេត្តព្រៃវែង

# វគ្គបណ្តុះបណ្តាល

ស្តីពី

# ចំណេះដឹងយេនឌ័រ

# ការធ្វើអោយកុមារមានសិទ្ធិពិតប្រាកដ និងកិច្ចការពារកុមារ

សំរាប់

# ក្រុមប្រឹក្សាឃុំ គណៈកម្មការគាំទ្រគំរោង និងក្រុមជួយខ្លួនឯង

ថ្ងៃទី ............... ខែ .......... ឆ្នាំ២០១០

ស្រុកកំពង់ត្របែក ស្រុកបាភ្នំ និងស្រុកមេសាង ខេត្តព្រៃវែង

រៀបចំដោយ

មន្ទីរកិច្ចការនារីខេត្តព្រៃវែង

សហការ/ឧបត្ថម្ភដោយ

អង្គការឃែរអន្តរជាតិប្រចាំនៅកម្ពុជា

# កម្មវិធីវគ្គបណ្តុះបណ្តាល

## <u>ស្តីពី</u>

## ចំណេះដឹងយេនឌ័រ_កាធ្វើអោយកុមារមានសិទ្ធិពិតប្រាកដ និងកិច្ចការពារកុមារ

| ☞ **ថ្ងៃទីមួយ** | | |
|---|---|---|
| **ពេលវេលា** | **សកម្មភាព** | **អ្នកសំរបសំរួល** |
| ៧:៣០-៨:០០ | -ជួបជុំចុះវគ្គមានអ្នកចូលរួម | អ្នកសំរបសំរួល |
| ៨:០០-៨:១០ | -ពិធីបើកវគ្គ+ប្រសាសន៍សំណេះសំណាលបើកកម្មវិធី | តំណាងឃុំ |
| ៨:១០-៩:១០ | -ការណែនាំអោយស្គាល់គ្នា.ការបង្កើតវិន័យ<br>-ការរំពឹងទុក .ការបង្ហាញពីគោលបំណងកម្មវិធីវគ្គ | អ្នកសំរបសំរួល<br>+អ្នកចូលរួម |
| ៩:១០-៩:៣០ | -បំពេញបញ្ជីសំនួរសាកល្បងមុនវគ្គ | អ្នកសំរបសំរួល |
| ៩:៣០-៩:៤៥ | សំរាកអាហារសំរ៉ន់ | |
| ៩:៤៥-១១:៣០ | -យេនឌ័រជាអ្វី? | អ្នកសំរបសំរួល |
| ១១:៣០-២:០០ | 🕐 **សំរាកអាហារថ្ងៃត្រង់** | |
| ២:០០-៣:៣០ | -តួនាទីយេនឌ័រ | អ្នកសំរបសំរួល |
| ៣:៣០-៣:៤៥ | សំរាកអាហារសំរ៉ន់ | |
| ៣:៤៥-៤:២០ | -តម្រូវការយេនឌ័រ | អ្នកសំរបសំរួល |
| ៤,២០-៥,០០ | -ស្ត្រី និងការធ្វើសេចក្តីសំរេច | អ្នកសំរបសំរួល |
| ☞ **ថ្ងៃទីពីរ** | | |
| ៧:៣០-៧:៤០ | -ល្បែងថាមពល | អ្នកសំរបសំរួល |
| ៧,៤០-៨.០០ | -រំលឹកមេរៀន | អ្នកសំរបសំរួល |
| ៨:០០-៨:៤០ | -កុមារត្រូវមានសិទ្ធិ និងត្រូវការសិទ្ធិ | អ្នកសំរបសំរួល |
| ៨:៤០-៩:៣០ | -សិទ្ធិជាមូលដ្ឋានរបស់កុមារ | អ្នកសំរបសំរួល |
| ៩:៣០-៩:៤៥ | សំរាកអាហារសំរ៉ន់ | |
| ៩:៤៥-១០:១៥ | -សិទ្ធិជាមូលដ្ឋាន "ត" | អ្នកសំរបសំរួល |
| ១០:១៥-១១:៣០ | -គោលការណ៍ជាមូលដ្ឋានពាក់ព័ន្ធនិងសិទ្ធិកុមារ | អ្នកសំរបសំរួល |
| ១១:៣០-២:០០ | 🕐 **សំរាកអាហារថ្ងៃត្រង់** | |
| ២:០០-៣:៣០ | -កត្តាដែលនាំឱ្យមានការរំលោភសិទ្ធិកុមារ | អ្នកសំរបសំរួល |

| | | |
|---|---|---|
| ៣:៣០-៣:៤៥ | សំរាកអាហារសំរ៉ន់ | |
| ៣:៤៥-៥:០០ | -ការដោះស្រាយបញ្ហា រំលោភសិទ្ធិកុមារ | អ្នកសំរបសំរួល |
| ☞ **ថ្ងៃទីបី** | | |
| ៧:៣០-៧:៤០ | -ល្បែងថាមពល | អ្នកសំរបសំរួល |
| ៧:៤០-៨:០០ | -រំលឹកមេរៀន | អ្នកសំរបសំរួល |
| ៨:០០-៨:៤០ | -កុមារដែលត្រូវការកិច្ចការពារពិសេស | អ្នកសំរបសំរួល |
| ៨:៤០-៩:៣០ | -កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា | អ្នកសំរបសំរួល |
| ៩:៣០-៩:៤៥ | សំរាកអាហារសំរ៉ន់ | |
| ៩:៤៥-១០:៣០ | -កុមារដែលរស់នៅក្នុងគ្រួសសារដែលមានអំពើហិង្សា | អ្នកសំរបសំរួល |
| ១០:៣០.១១:០០ | -កុមារដែលត្រូវគេរំលោភផ្លូវភេទ | អ្នកសំរបសំរួល |
| ១១:០០.១១:៣០ | -កុមារចេញពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ | អ្នកសំរបសំរួល |
| ១១:៣០-២:០០ | **សំរាកអាហារថ្ងៃត្រង់** | |
| ២:០០-២:៣០ | កុមារត្រូវគេកេងប្រវ័ញ្ចកំលាំងពលកម្ម | អ្នកសំរបសំរួល |
| ២:៣០-៣:០០ | -កុមារពិការ | អ្នកសំរបសំរួល |
| ៣:០០-៣:៣០ | -កុមារទំនាស់ និងច្បាប់ | អ្នកសំរបសំរួល |
| ៣:៣០-៣:៤៥ | សំរាកអាហារសំរ៉ន់ | |
| ៣:៤៥-៤:០៥ | -សង្ខេបវគ្គបណ្តុះបណ្តាល | អ្នកសំរបសំរួល |
| ៤:០៥-៤:២៥ | -បំពេញបញ្ជីសំនួរក្រោយវគ្គ | អ្នកសំរបសំរួល |
| ៤:២៥-៤:៣០ | -វាយតម្លៃវគ្គបណ្តុះបណ្តាល | អ្នកចូលរួម |
| ៤:៣០-៥:០០ | -ពិធីបិទវគ្គ | តំណាងឃុំ |

*សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់ !*

**<u>គោលបំណង</u>** : នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល អ្នកចូលរួមនឹង :

- ទទួលបាននូវចំណេះដឹង ស្តីពី យេនឌ័រ-ការធ្វើឱ្យកុមារមានសិទ្ធិពិតប្រាកដ-កិច្ចការពារកុមារ
- យល់ដឹងពីតួនាទី ការងារប្រចាំថ្ងៃ របស់បុរស-ស្ត្រី
- យល់ដឹងពី ផ្នត់គំនិត-ឥរិយាបថ របស់គ្រួសារ និងសហគមន៍
- យល់ដឹងពី មូលហេតុដែលកុមារត្រូវការសិទ្ធិ និងត្រូវមានសិទ្ធិ
- យល់ដឹងពី សិទ្ធិជាមូលដ្ឋាន របស់កុមារ និងគោលការណ៍ពាក់ព័ន្ធនានា
- យល់ដឹងពី ប្រភពដែលកុមារត្រូវការកិច្ចការពារ

**<u>លទ្ធផលរំពឹងទុក</u>**

- បុរស-ស្ត្រីចេះជួយចែករំលែកការងារគ្នា
- កុមារទទួលបានសិទ្ធិពិតប្រាកដ
- កុមារទទួលបានការ ការពារ

## <u>មាតិកា នៃវគ្គបណ្តុះបណ្តាល</u>


**ផ្នែក ទី១ : យេនឌ័រ**

<u>ប្រធានបទ ទី១</u> : យេនឌ័រជាអ្វី ?

<u>ប្រធានបទ ទី២</u> : តួនាទីយេនឌ័រ

<u>ប្រធានបទ ទី៣</u>: តំរូវការយេនឌ័រ

<u>ប្រធានបទ ទី៤</u> : ស្ត្រី និងការធ្វើសេចក្តីសំរេច

**ផ្នែក ទី២ : ការធ្វើឱ្យកុមារមានសិទ្ធិពិតប្រាកដ**

<u>ប្រធានបទ ទី១</u> : កុមារត្រូវមានសិទ្ធិ និងការពារសិទ្ធិ

<u>ប្រធានបទ ទី២</u> : សិទ្ធិជាមូលដ្ឋានរបស់កុមារ

<u>ប្រធានបទ ទី៣</u> : គោលការណ៍ជាមូលដ្ឋានពាក់ពន្ធ័នឹងសិទ្ធិកុមារ

<u>ប្រធានបទ ទី៤</u> : កត្តាដែលនាំឱ្យមានការរំលោភសិទ្ធិកុមារ

ប្រធានបទ ទី៥ : ការដោះស្រាយបញ្ហារំលោភសិទ្ធិកុមារ

**ផ្នែក ទី៣ : កិច្ចការពារកុមារ**

ប្រធានបទ ទី១ : កុមារត្រូវការកិច្ចការពារពិសេស

ប្រធានបទ ទី២ : កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា

ប្រធានបទ ទី៣ : កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា

ប្រធានបទ ទី៤ : កុមារដែលត្រូវគេរំលោភផ្លូវភេទ

ប្រធានបទ ទី៥ : កុមារត្រូវគេកេងប្រវ័ញ្ច កំលាំងពលកម្ម

ប្រធានបទ ទី៦ : កុមារចាកចេញពីសហគមន៍ ដែលគ្មានឪពុកម្តាយទៅជាមួយ

ប្រធានបទ ទី៧ : កុមារពិការ

ប្រធានបទ ទី៨ : កុមារទំនាស់នឹងច្បាប់

*********

# ផ្នែក ទី១

# យេនឌ័រ

## ប្រធានបទ : យេនឌ័រជាអ្វី?

*ឯកសារភ្ជាប់ ១.១*

### ១. លក្ខណៈដូចគ្នា និងខុសគ្នារវាងទារកនិងទារិកា

យើងទាំងអស់គ្នាបានដឹងហើយថា ទារិកា និងទារក ( កូនស្រីនិងកូនប្រុសដែលទើបនឹងកើត ) មានលក្ខណៈដូចគ្នា ដូចជា រូបរាងកាយ មានខួរក្បាល មានការស្រេកឃ្លាន ត្រូវការថ្នាក់ថ្នម និងបំប៉នចំណីអាហារដូច គ្នា (ការបំបៅដោះ ស្មើគ្នា) ។ មានតែសរីរាង្គផ្នែកភេទទេ ដែលបញ្ជាក់ពីភាពខុសគ្នារវាងកូនប្រុស និងកូនស្រី ។

*ឯកសារភ្ជាប់ ១.២*

### ២. ផ្នត់គំនិតនិងការប្រព្រឹត្តរបស់សង្គមមកលើកូនប្រុសនិងកូនស្រី

ជាទូទៅគ្រួសារ និងសហគមន៍ភាគច្រើនមានការគិតទុក និងការប្រព្រឹត្តទៅលើ កូនប្រុស និងកូនស្រី ខុសៗគ្នា ។ ជាក់ស្តែង គ្រួសារនិងសហគមន៍ភាគច្រើនបានជំរុញ និងផ្តល់ឱកាសដល់កូនប្រុសអោយទទួលបានការ អប់រំ រៀនសូត្របាន ជ្រៅជ្រះ បំប៉នចំណីអាហារ ( ជាទម្លាប់របស់ម្តាយឪពុក ច្រើនផ្គត់ផ្គង់ចំណីអាហារអោយកូន ប្រុសច្រើនជាងកូនស្រី )។ កូនប្រុសអាចទទួលបាន ព័ត៌មាន ឬដំណឹងផ្សេងៗច្រើនជាងកូនស្រី តាមរយៈការចូល រួមក្នុងសង្គមខាងក្រៅ និងមានសេរីភាពសេពគប់មិត្តភ័ក្តិ ។ លើសពីនេះទៀត គ្រួសារ និងសហគមន៍ទទួលបាន ការទូន្មាន និងជំរុញអោយកូនប្រុសមានភាពក្លាហាន ដើម្បីក្លាយជាអ្នកដឹកនាំនៅក្នុងគ្រួសារ និងសហគមន៍ ។ ចំណែកឯកូនស្រីវិញ គ្រួសារនិងសហគមន៍បានទូន្មាន និងលើកទឹកចិត្តអោយធ្វើការងារផ្ទះ អត់ធ្មត់ សុភាពរាប សារ ទន់ភ្លន់ ស្តាប់បង្គាប់ឪពុកម្តាយ និងប្តី មិនត្រូវជំទាស់ ប្រឆាំង និងមិនចាំបាច់រៀនសូត្រច្រើនទេ និងជំរុញ អោយឆាប់រៀបការ ។ ម្យ៉ាងទៀត គ្រួសារនិងសហគមន៍ភាគច្រើនបាន រារាំង ឬហាមឃាត់មិនអោយកូនស្រី ទទួលព័ត៌មាន និងដឹងរឿងរ៉ាវច្រើន ដូចជាការអប់រំពីសុខភាពបន្តពូជ ទំនាក់ទំនង ជាមួយមិត្តភ័ក្រ្ត និងមិនអោយ និយាយ និងបញ្ចេញយោបល់ច្រើន ។ ដូចនេះ ការរំពឹងទុក និងការប្រព្រឹត្តរបស់សង្គម មកលើកូនស្រីនិងកូនប្រុស ស្ត្រីនិងបុរស ទាំងអស់ខាងលើនេះ គឺជាយេនឌ័រ ។

**និយមន័យយេនឌ័រ :**

**+ យេនឌ័រ គឺជាការកំណត់របស់ សង្គម សហគមន៍ និងគ្រួសារ ពាក់ពន្ធ័ និងការបែងចែក ពលកម្ម ការអប់រំ សិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ និងតួនាទី ដល់កូនប្រុស និងកូនស្រី បុរស និងស្ត្រី ហើយអាចផ្លាស់ប្តូរបាន ។**

**មានតែសេរីរាង្គភេទ ដែលមិនអាចកែប្រែបាន ។**

**<u>និយមន័យភេទ</u> :**

+ **ភេទ គឺជាលក្ខណៈជីវសាស្រ្ត ពីកំណើតដែលធម្មជាតិបានកំណត់ហើយមិនអាចផ្លាស់ប្តូរបាន។**

## ភាពខុសប្លែកគ្នារវាងយេនឌ័រនិងភេទ

| | |
|---|---|
| **តួនាទីភេទ** | **តួនាទីយេនឌ័រ** |
| **លក្ខណៈជីវសាស្រ្ត** | **កំណត់ដោយសង្គម** |
| ↓ | ↓ |
| **មិនអាចផ្លាស់ប្តូរនិងកែប្រែបានទេ** | **អាចផ្លាស់ប្តូរនិងកែប្រែបាន** |

<u>ឧទាហរណ៍</u>

មានតែស្រ្តីទេ ដែលអាចមានផ្ទៃពោះ និង បំបៅកូនដោយទឹកដោះម្តាយ និង មានតែបុរសទេ ដែលអាចផ្តល់មេជីវិត ។

<u>ឧទាហរណ៍</u>

- ស្រ្តីនិងបុរស អាចធ្វើជាវិស្វករ និងអ្នកគ្រប់គ្រងបានដូចគ្នា ។ -ស្រ្តីនិងបុរស អាចធ្វើការងារ ផ្ទះសម្បែង និង ថែទាំកូនចៅបានដូចគ្នា ។

*ឯកសារភ្ជាប់ ១.៣*

## ៣. <u>ផលប៉ះពាល់ជាអវិជ្ជមានចំពោះក្មេងស្រី ស្រ្តី គ្រួសារ សហគមន៍ និងសង្គម</u>

ដោយសារផ្នត់គំនិត និងការប្រព្រឹត្តរបស់គ្រួសារ សហគមន៍ និងសង្គមភាគច្រើន ធ្វើអោយមានផលប៉ះ ពាល់ជាអវិជ្ជមានជាច្រើនដល់ក្មេងស្រី និងស្រ្តី ។

ជាក់ស្តែងក្មេងស្រី និងស្រ្តីភាគច្រើនទទួលបានការអប់រំទាប បានធ្វើអោយប៉ះពាល់ដល់ ការថែទាំសុខ ភាពមានការលំបាកក្នុងការរកការងារធ្វើ និងទទួលប្រាក់ចំណូលទាប មិនសូវមានភាពក្លាហាន ងាយទទួលរងនូវការកេងប្រវ័ញ្ច ងាយចាញ់បោកគេ និងរងនូវអំពើហិង្សា (ដូចជាការជួញដូរផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ) ។

ផ្អែកលើលទ្ធផលទាំងនេះ ធ្វើអោយសហគមន៍មានការរើសអើង កាន់តែខ្លាំងទៅលើ ស្រ្តី និងក្មេងស្រី ហើយបានធ្វើអោយពួកគេកាន់តែងាយរងគ្រោះ និងមានឱកាសតិចតួចក្នុងការចូលរួមការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការធ្វើសេចក្តីសំរេចក្នុងគ្រួសារ និងក្នុងសហគមន៍ ដូចជាប្រធានក្រុម មេភូមិ មេឃុំ ចៅសង្កាត់ ថ្នាក់ដឹកនាំស្រុក.... ។ល ។

## ៤. ការកែលំអរផ្នត់គំនិត និងការប្រព្រឹត្តរបស់គ្រួសារ សហគមន៍ និងសង្គម

យេនឌ័រកើតឡើងមកពីផ្នត់គំនិត និងការប្រព្រឹត្តរបស់សង្គម សហគមន៍ និងគ្រួសារ ហើយបានផ្តល់ផលប៉ះពាល់អវិជ្ជមានដល់ស្ត្រី និងក្មេងស្រីព្រមទាំងសង្គម សហគមន៍ និងគ្រួសារទាំងមូល ។

ដូចនេះគ្រួសារ និងសហគមន៍ ត្រូវរួមគ្នាកែប្រែនូវ ឥរិយាបថ និងការប្រព្រឹត្តទាំងនេះតាមរយៈ ការជំ រុញ និងផ្តល់ ឱកាសអោយក្មេងស្រី និងក្មេងប្រុស ស្ត្រី និងបុរស ទទួលបានឱកាសស្មើៗគ្នាក្នុងការអប់រំ ការថែទាំ ទំនុកបំរុង កិច្ចការពារ និងសេវាផ្សេងៗ និងបង្កើនភាពអង់អាច ដើម្បីអោយពួកគេមានសមត្ថភាព និងលទ្ធភាព គ្រប់គ្រាន់ក្នុងការចូលរួម ការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការធ្វើសេចក្តីសំរេចនៅក្នុងគ្រួសារនិងសង្គម ។

## ប្រធានបទ : តួនាទីយេនឌ័រ

*ឯកសារភ្ជាប់ ២.១*

## ១. ការងារប្រចាំថ្ងៃរបស់បុរស ស្ត្រី

ការងារដែលបុរសស្ត្រីធ្វើជារៀងរាល់ថ្ងៃមានបីប្រភេទ ១. ការងារមានកម្រៃ ២. ការងារគ្មានកម្រៃ និង ៣. ការងារសហគមន៍ ។

**១.ការងារមានកម្រៃ** រួមមាន ការងារកែច្នៃម្ហូបអាហារ ការលក់ដូរ ស៊ីឈ្នួល អ្នកធ្វើការងារមន្ត្រីរាជ ការ អ្នកធ្វើការងារអង្គការនានា ។ល។

**២.ការងារមិនមានកម្រៃ** រួមមានការងារផ្ទះសម្បែង ចំអិនម្ហូបអាហារ ថែទាំទំនុកបំរុងគ្រួសារ អប់រំ កូនចៅ ។ល។

**៣.ការងារសហគមន៍** គឺជាការងារស្ម័គ្រចិត្ត ដូចជាការចូលរួមលើកផ្លូវលំ ស្តាប្រឡាយ ស្តាស្រះសហគ- មន៏ ចូលរួម ការងារអភិវឌ្ឍន៍ក្នុង ភូមិ ឃុំ សង្កាត់ និងស្រុក ខណ្ឌ ធ្វើអនាម័យក្នុងភូមិ ធ្វើបុណ្យក្នុងភូមិ ។ល។

ជារៀងរាល់ថ្ងៃស្ត្រីធ្វើការងារច្រើនរួមទាំងការងារផ្ទះសម្បែង ការថែទាំគ្រួសារ និងការងារក្រៅផ្ទះ ដើម្បីជួយរក ប្រាក់ចំណូល។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់ថា ការងារមេផ្ទះមានតម្លៃស្មើគ្នា នឹងកម្រៃដែល បានមកពីការងារធ្វើនៅក្រៅផ្ទះ។ បច្ចុប្បន្ន សង្គម សហគមន៍ និងគ្រួសារភាគច្រើននៅតែចាត់ទុកថា ការងារផ្ទះ សម្បែង ឬការងារមេផ្ទះ និងការថែទាំគ្រួសារជាការងារគ្មានតម្លៃនិងជាការងារកំប៉ិកកំប៉ុក តែជាក់ស្តែង ការងារទាំងនេះត្រូវការ ការព្យាយាមអត់ធ្មត់ និងចំណាយពេលវេលាច្រើន។ ពេលខ្លះ ស្ត្រីអាចរកប្រាក់ចំណូល និងធ្វើ ការងារផ្ទះសម្បែងក្នុង ពេលតែមួយបាន ដូចជាលក់ឥវ៉ាន់ នំចំនី ឬចិញ្ចឹមសត្វ និងដាំដំណាំរួមផ្សំ។ ទន្ទឹមនឹងនេះ ស្ត្រីបានចូលរួមក្នុង ការងារសហគមន៍ ដូចជាការងាររៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋាន ចូលរួមក្នុង គណៈកម្មការនានា ក្រុមប្រឹក្សាឃុំសង្កាត់ តំណាងភូមិ ជាដើម ប៉ុន្តែពួកគេមិនសូវមានតួនាទីជាអ្នកដឹកនាំ និងគ្រប់ គ្រងលើការងារ ទាំងនោះទេ។

ស្ត្រី និងបុរសអាចធ្វើការទាំងបីប្រភេទបានដូចគ្នា លើកលែងតែតួនាទីភេទ ដែលស្ត្រីជាអ្នកពរពោះ និងបុរសជាអ្នក ផ្តល់មេជីវិត។ ក្នុងចំនោមការងារទាំងបី មិនមានការងារណាមួយដែលស្ត្រី និងបុរសមិនអាចធ្វើ បាននោះទេ ប៉ុន្តែជាក់ស្តែងសង្គម និងសហគមន៍ ភាគច្រើនបានកំណត់ និងបែងចែកការងារ និងការទទួលខុស ត្រូវដល់ក្មេងស្រី ស្ត្រី និងក្មេងប្រុស បុរស ខុសៗគ្នាតាំងពីតូចមក ។

## ២. សារៈសំខាន់នៃការងារទាំងបីប្រភេទ

ការងារទាំងនេះមានតម្លៃ និងមានសារៈសំខាន់ដូចៗគ្នា មានទំនាក់ និងជួយបំពេញឱ្យគ្នាទៅវិញទៅមក ដោយមិន អាចកាត់ផ្តាច់ការងារណាមួយបានឡើយ។ ការងារផ្ទះបានជួយបំពេញឱ្យការងារក្រៅផ្ទះ ឬការងារ រក ប្រាក់ចំណូល ហើយក៏ មិនអាចកាត់ផ្តាច់ការចូលរួមក្នុងការងារសហគមន៍ផងដែរ។ ឧទាហរណ៍ៈ អ្នកចង់ទៅលក់ដូរ នៅផ្សារ រត់ម៉ូតូឌុប ឬធ្វើការងារ សំណង់ បើគ្មានអ្នកធ្វើការងារផ្ទះ ដូចជាដាំស្ល ថែទាំផ្ទះសម្បែង និង កូនចៅ អ្នកមិនអាចទៅធ្វើការងារទាំងអស់នោះបាន ងាយស្រួលឡើយ។ ការជួយរំលែកការងារទៅវិញទៅមក នឹងនាំ មកនូវការអោយតម្លៃដល់គ្រួសារ និងធ្វើឱ្យគ្រួសារមាន សុភមង្គល មានការរីកចម្រើនធ្វើអោយចំណេញពេល វេលា សម្រាប់ប្រកបរបរផ្សេងទៀត និងឈានទៅកាត់បន្ថយ អំពើហិង្សាក្នុងគ្រួសារ។

ម្យ៉ាងវិញទៀតការងារសហគមន៍ គឺជម្រុញនិងតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មរបស់ស្ត្រីនិងបុរស ដើម្បីធ្វើ សេចក្តីសម្រេច និងភាពជាម្ចាស់ក្នុងការអភិវឌ្ឍន៍មូលដ្ឋាន និងដោះស្រាយតម្រូវការអាទិភាពរបស់ពួក គេ ។

# ប្រធានបទ ៖ តម្រូវការយេនឌ័រ

ដោយសារតែទំនាក់ទំនង តួនាទី និងសិទ្ធិអំណាចដែលសង្គម សហគមន៍ និងគ្រួសារបានផ្តល់ដល់ស្ត្រី បុរសមានលក្ខណៈខុសគ្នាសេចក្តីត្រូវការរបស់ពួកគេ ក៏មានលក្ខណៈខុសគ្នាទៅតាមនោះដែរ ។ ដូចច្នេះវាមាន សារៈសំខាន់ណាស់ក្នុងការយល់ដឹង និងវិភាគបែងចែកឱ្យបានច្បាស់ពីតម្រូវការទាំងនោះដើម្បីធ្វើឱ្យកម្មវិធីគំរោង និងផែនការអភិវឌ្ឍន៍នានាបានឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់បុរស នៅក្នុងសហគមន៍ និងមូលដ្ឋាន ។

*ឯកសារភ្ជាប់ ៣.១*

## ១. តម្រូវការយេនឌ័រចំពោះមុខ

ជាទូទៅ ដោយសារតួនាទីដែលកំណត់ឡើងដោយសង្គម និងធម្មជាតិ ស្ត្រីមានតម្រូវការមួយចំនួនពាក់ព័ន្ធនឹងការងារ ប្រចាំថ្ងៃរបស់ខ្លួនដូចជា ទឹកស្អាត បង្គន់អនាម័យ ថ្នាក់អក្ខរកម្ម មណ្ឌលសុខភាព ជំនាញបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំតណទានសំរាប់មុខរបរ ។ល។

បុរសក៏មានតម្រូវការខាងលើនេះដូចស្ត្រីដែរ ប៉ុន្តែដោយបុរសមិនសូវបានចូលរួមធ្វើការងារផ្ទះសម្បែង ការទំនុកបំរុងគ្រួសារ ទើបពួកគាត់មិនសូវបានគិតដល់តម្រូវការខាងលើនេះ ។ បន្ថែមលើនេះបុរសមានតម្រូវ ការទាក់ទងនឹងការជួយសំរាលដល់ការងាររបស់ពួកគាត់ដូចជា ម៉ាស៊ីនបូមទឹក ម៉ាស៊ីនភ្ជួររាស់ ម៉ាស៊ីនបោកស្រូវ ម៉ូតូ ឬបច្ចេកវិជ្ជាទំនើបៗ ។ល។

តម្រូវការទាំងអស់ខាងលើនេះ គឺជា **តម្រូវការចំពោះមុខរបស់ស្ត្រីនិងបុរស** ។

ការវិភាគ និងការធ្វើផែនការដោយយកចិត្តទុកដាក់លើតម្រូវការចំពោះមុខទាំងនេះ មានភាពចាំបាច់ ណាស់ដើម្បីធានាថារាល់កម្មវិធី និងគំរោងនានាត្រូវបានគ្រោងរៀបចំឡើងវិញ ដើម្បីបំពេញនូវតម្រូវការពិត ប្រាកដរបស់ស្ត្រី បុរស និងកុមារ ដើម្បីអាចកែប្រែស្ថានភាពជីវភាពបានប្រសើរជាងមុន ។

*ឯកសារភ្ជាប់ ៣.២*

## ២. តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ ៖

ម្យ៉ាងវិញទៀត ផ្អែកលើស្ថានភាពបច្ចុប្បន្នដោយ ស្ត្រីមានចំនួនតិចក្នុងជួរជាអ្នកដឹកនាំនៅគ្រប់លំដាប់ថ្នាក់ដូចនេះ ស្ត្រីត្រូវមានតំរូវការជាពិសេសដើម្បីឱ្យមានឱកាសទទួលបាននូវតួនាទីឋានៈ មានសិទ្ធិអំណាចជាអ្នក ដឹកនាំ និងអ្នកធ្វើ ជាអ្នកធ្វើសំរេចនៅគ្រប់កំរិត ដូចជានៅក្នុងសភាជាតិ រាជរដ្ឋាភិបាលថ្នាក់ដឹកនាំខេត្តក្រុង ស្រុកខណ្ឌ

ក្រុមប្រឹក្សាឃុំសង្កាត់ ថ្នាក់**ដឹកនាំភូមិ** ប្រធានសមាគមន៍ថែទាំផ្លូវ ព្រៃឈើ ។ល។ ដែលទាំងអស់នេះ គឺជា **តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ**។

បុរស ក៏មានតម្រូវការនេះដែរ ប៉ុន្តែសព្វថ្ងៃ បុរសមានតួនាទីជាអ្នកដឹកនាំច្រើននៅគ្រប់លំដាប់ថ្នាក់ និងមានឱកាស ច្រើនក្នុងការចូលរួមជាអ្នកធ្វើសេចក្តីសំរេច នៅគ្រប់លំដាប់ថ្នាក់តាំងពីគ្រួសាររហូតដល់សហគមន៍ និងសង្គមជាតិ ។

ការដោះស្រាយតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ គឺធ្វើឡើងតាមរយៈការបង្កើត ឬកែប្រែ គោលនយោបាយសំរាប់កែ លំអរឋានៈ និងតួនាទីស្ត្រី និងលប់បំបាត់នូវរាល់ការរើសអើងលើស្ត្រីនិងកុមារ ។ ជាទូទៅដំណោះស្រាយនេះច្រើនទាក់ទង ទៅនឹង គោលការណ៍សមភាព និងសមធមិដែលអាចធ្វើឱ្យស្ត្រី និងកុមារីមានឱកាស ស្មើនឹងបុរស នឹងកុមារា ក្នុងការទទួល ការបណ្តុះបណ្តាលការអប់រំ ការធ្វើសេចក្តីសំរេច ប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នា សិទ្ធិកាន់កាប់ដីធ្លី និងទ្រព្យសម្បត្តិ ដទៃទៀត សិទ្ធិសេរីភាពក្នុងការផ្តល់កំណើតកូន សិទ្ធិគ្រប់គ្រងលើធនធានផ្សេងៗ និងការចូលរួមក្នុងដំណើរការ អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ។ល។

# ប្រធានបទ : ស្ត្រី និងការធ្វើសេចក្តីសំរេច

*ឯកសារភ្ជាប់ ៤.១*

## ១. ស្ថានភាពស្ត្រី ក្នុងការធ្វើសេចក្តីសំរេច :

បច្ចុប្បន្នស្ត្រីដែលមានតួនាទីជាអ្នកដឹកនាំនៅគ្រប់លំដាប់ថ្នាក់នៅមានកំរិតនៅឡើយ :

- ស្ត្រីប្រមាណ ៣០% នៃថ្នាក់ដឹកនាំភូមិ ។(២០០៦)
- ស្ត្រីប្រមាណ ១៦% ជាសមាជិកាក្រុមប្រឹក្សាឃុំសង្កាត់។ (២០០៧)
- ស្ត្រីជាអភិបាលរងរាជធានី ខេត្ត មានប្រមាណ ១៦.៧៨ %
- ស្ត្រីជាអភិបាលរងក្រុង ស្រុក ខណ្ឌ មានប្រមាណ ២៣.៧៩ % (២០០៨)
- ស្ត្រីជាក្រុមប្រឹក្សារាជធានី ខេត្ត មានប្រមាណ ៩.៨៩ %
- ស្ត្រីជាក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានប្រមាណ ១២.៦៨ %
- ស្ត្រីប្រមាណ ៨ % ជាសមាជិករាជរដ្ឋាភិបាលកម្ពុជា អណត្តិទី៤។(២០០៨)
- ស្ត្រីប្រមាណជាង ១៤% ជាសមាជិកាព្រឹទ្ធសភា។(២០០៦)
- ស្ត្រីប្រមាណជាង ២១% ជាសមាជិការដ្ឋសភាជាតិ។(២០០៨)

### រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

" ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ។

...មានសិទ្ធិជ្រើសរើសមុខរបរសមស្របទទួលប្រាក់បំណាច់ ស្មើគ្នាចំពោះការងារដូចគ្នា។ ក្នុងនោះ ក៏បានកំណត់លើ ការចាត់ឱ្យមានវិធានការទប់ស្កាត់ និងលុបបំបាត់ការរើសអើងគ្រប់ប្រភេទ ប្រឆាំង នឹងស្ត្រី។

*ឯកសារភ្ជាប់ ៤.២*

## ២. មូលហេតុដែលស្ត្រីជាថ្នាក់ដឹកនាំ និងថ្នាក់ធ្វើសេចក្តីសំរេចមានចំនួនតិច :

- សង្គមនៅមានការរើសអើង ដោយយល់ថា ស្ត្រីមិនអាចធ្វើជាអ្នកដឹកនាំបាន ។
- ស្ត្រីមានបន្ទុកការងារច្រើន ទាំងការងារផ្ទះសម្បែង ការងារថែទាំ និងទំនុកបំរុងក្រុមគ្រួសារ រកប្រាក់ ចំណូល ។
- ស្ត្រីមិនសូវមានការជឿជាក់លើខ្លួនឯង និងចំណេះដឹងនៅមានកំរិត ។
- ខ្វះការគាំទ្រ និងជំរុញពីគ្រួសារ និងសហគមន៍។

## ៣. <u>សារៈសំខាន់នៃការចូលរួមរបស់ស្ត្រី</u>

- ស្ត្រី គឺជាធនធានមនុស្សដ៏សំខាន់ ស្ត្រីមានគំនិតប្រាជ្ញា ភាពវៃឆ្លាត អាចធ្វើជាអ្នកធ្វើសេចក្តីសំរេច និង អ្នកដឹកនាំនៅគ្រប់លំដាប់ថ្នាក់។
- ស្ត្រី អាចយល់សុខទុក្ខ និងតម្រូវការរបស់ស្ត្រី។
- ស្ត្រីអាចបង្ហាញជាគំរូអ្នកដឹកនាំល្អដល់ក្មេងស្រី និង សង្គមទាំងមូល។

# ផ្នែក ទី២

# ការធ្វើឱ្យកុមារមានសិទ្ធិពិតប្រាកដ

# ១. កុមារត្រូវមានសិទ្ធិ និងត្រូវការសិទ្ធិ

*ឯកសារភ្ជាប់ ១.១*

តើហេតុអ្វីបានជាកុមារចាំបាច់ត្រូវមានសិទ្ធិ និងត្រូវការសិទ្ធិ?

- កុមារមានសិទ្ធិពិសេស ពីព្រោះពួកគេ គឺជាកុមារ ។ យើងដឹងថា កុមារត្រូវការការថែទាំ និងការ យកចិត្តទុកដាក់ជាពិសេស ពីព្រោះពួកគេនៅតូចៗ និងងាយរងគ្រោះហើយនៅពេលដែលពួកគេ នៅក្មេងខ្ចីយ៉ាងនេះ ពួកគេមិនអាចរស់នៅបានដោយគ្មានការជួយពីមនុស្សពេញវ័យឡើយ ។
- ជាទូទៅមនុស្សត្រូវមានសិទ្ធិជាមូលដ្ឋាន។ កុមារក៏ជាមនុស្សដែរ ដូច្នេះពួកគេត្រូវមានសិទ្ធិ សេរីភាព សេចក្តីថ្លៃថ្នូរ ភាពស្មើគ្នា សេចក្តីសុខ និងសុវត្ថិភាព ដូចមនុស្សធំដែរ ។ កុមារគ្រប់រូបមានសិទ្ធិ ដូចៗគ្នាទាំងអស់ ។
- នៅពេលដែលយើងបង្រៀនមនុស្សធំអំពីសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ពួកគេអាចតវ៉ា និងទាមទារសិទ្ធិនោះបាន។ ផ្ទុយទៅវិញចំពោះកុមារដោយសារពួកគេនៅតូច ពួកគេមិនអាចតវ៉ាទាមទារសិទ្ធិ របស់ខ្លួនដូចមនុស្សធំបានឡើយ ។
- សិទ្ធិកុមារសំខាន់ណាស់ ព្រោះកុមារ គឺជាអនាគតរបស់ពួកយើង ជាក្តីសង្ឃឹម និងជាឱកាសដ៏មានតម្លៃសម្រាប់ សហគមន៍ ប្រទេសជាតិ និងពិភពលោករបស់យើងនាពេលអនាគត ។

ដូច្នេះ វាមានសារៈសំខាន់ណាស់ដែលយើងត្រូវដឹងថា កុមារត្រូវបានទទួលសិទ្ធិរបស់ពួកគេ ទើបពួកគេអាចអភិវឌ្ឍ ទៅដល់សក្តានុពលអតិបរមារបស់ខ្លួនបាន ។

# ២. សិទ្ធិជាមូលដ្ឋានរបស់កុមារ

*ឯកសារភ្ជាប់ ២.១*

## ១. តើកុមារត្រូវការអ្វីខ្លះ?

### ក). ការរស់រានមានជីវិត

ក្នុងការរស់រានមានជីវិត កុមារត្រូវការ :

- ❖ ម្ហូបអាហារគ្រប់គ្រាន់ និងមានគុណភាពល្អ
- ❖ ទឹកស្អាតសម្រាប់បរិភោគ
- ❖ សម្លៀកបំពាក់ស្អាតសម្រាប់ស្លៀកពាក់ និងការពារខ្លួន
- ❖ ផ្ទះសម្រាប់រស់នៅ
- ❖ រស់នៅដោយមានសុខុមាលភាព និងគេចផុតពីជំងឺ
- ❖ ការយកចិត្តទុកដាក់ពីឪពុកម្តាយ និងសមាជិកគ្រួសារផ្សេងទៀត
- ❖ ...។ល។

### ខ). ការអភិវឌ្ឍ

- ❖ សាលារៀនល្អ គ្រូបង្រៀន និងសៀវភៅ ។
- ❖ លោកគ្រូ អ្នកគ្រូបង្រៀនពួកគេឱ្យរីកចម្រើនប្រកបដោយសន្តិភាព សេរីភាព ភាពថ្លៃថ្នូរ និង សេចក្តីស្រលាញ់ទើបពួកគេអាចបន្តបង្រៀនទៅដល់អ្នកដទៃ នៅពេលពួកគេធំឡើង
- ❖ ពេលវេលា និងទីកន្លែងលេងកំសាន្តជាមួយកុមារដទៃ
- ❖ ដឹងពីពិភពលោកទាំងមូលតាមវិធីមួយដែលគេអាចដឹងបាន
- ❖ សេរីភាពក្នុងការលេង និងធ្វើសកម្មភាពផ្សេងៗ
- ❖ ឧបករណ៍ សម្រាប់ក្មេងលេង
- ❖ ទីកន្លែសម្រាប់លេងកំសាន្ត
- ❖ កន្លែងសម្រាប់គេងដែលមានភាពកក់ក្តៅ
- ❖ ...។ល។

### គ). ការការពារ

ក្នុងការការពារ កុមារត្រូវការ :

- ❖ ឱ្យគេយកចិត្តទុដាក់ចំពោះខ្លួន

- អាជ្ញាធរពាក់ពន្ធ័ដើម្បីការពារពីការជួញដូរ
- ឪពុកម្តាយការពារ និងមិនលក់ពួកគេ ទៅឱ្យអ្នកដទៃ
- ការថែទាំយ៉ាងពិសេសបើសិនជាកុមារពិការ ឬមានតម្រូវការចាំបាច់
- រស់នៅដោយគ្មានការរំលោភបំពាន និងកេងប្រវ័ញ្ច
- ឱ្យគេយកទៅចញ្ចឹម និងថែទាំប្រសិនបើកុមារមិនមានគ្រួសារ ឬសាច់ញាតិសម្រាប់ថែទាំ
- ឱ្យអ្នកជួយពួកគេភ្លាម១ នៅពេលមានការលំបាក សង្គ្រាមឬគ្រោះមហន្តរាយនានា
- ...។ល។

**ឃ). ការចូលរួម**

ក្នុងការចូលរួមកុមារត្រូវការ :

- ឱ្យអ្នកស្តាប់ពួកគេ សួរពួកគេថា តើពួកគេកំពុងគិតអ្វីជាពិសេសនៅពេលដែលការគិតរបស់អ្នកជះឥទ្ធិពលដល់ពួកគេ
- ឱ្យមានការផ្សព្វផ្សាយព័ត៌មានសមស្របដល់ពួកគេ
- ដឹងព័ត៌មានអំពីសុខភាព និងសុវត្ថិភាពរបស់ពួកគេ
- ឱ្យមនុស្សពេញវ័យសាកសួរពីគំនិតរបស់ពួកគេ
- រៀនបញ្ចេញមតិយោបល់ដោយគ្មានការភ័យខ្លាច ពីការគំរាមគំហែង ឬដាក់ទណ្ឌកម្ម
- ក្លឹបកីឡា
- សៀវភៅសម្រាប់អាន និងអាចទទួលព័ត៌មានបាន
- ...។ល។

*ឯកសារភ្ជាប់ ២.២*

## ២. សិទ្ធិនានាដែលស្ថិតនៅក្នុងផ្នែកនីមួយៗនៃសិទ្ធិជាមូលដ្ឋានរបស់កុមារ រួមមាន :

**ក). ការរស់រានមានជីវិត**

- សិទ្ធិមានជីវិតរស់នៅ
- សិទ្ធិទទួលបានការជួយជ្រោមជ្រែងមុនគេ
- សិទ្ធិទទួលបានសេវាសុខភាព
- សិទ្ធិទទួលបានការប្រើប្រាស់ទឹកដោយសុវត្ថិភាព
- សិទ្ធិទទួលបានអនាម័យ
- សិទ្ធិទទួលបានទីជម្រក និងម្ហូបអាហារ

❖ សិទ្ធិទទួលបានការថែទាំជាពិសេសប្រសិនបើកុមារពិការ

❖ ...។ល។

## ខ). ការអភិវឌ្ឍ

❖ ការទទួលបានការអប់រំចាំបាច់ដោយឥតបង់ថ្លៃ (នៅថ្នាក់បឋមសិក្សា)។ ការអប់រំរួមបញ្ចូលទាំងការបង្រៀនកុមារអំពីសន្តិភាព ការយល់ដឹងទូទៅ ការអធ្យាស្រ័យគ្នា ការទំនាក់ទំនងជា មួយអ្នកដទៃប្រកប ដោយសេចក្តីថ្លៃថ្នូរ និងការអភិវឌ្ឍកុមារលើកាយសម្បទា គំនិត ប្រាជ្ញា ស្មារតី...។ល។

❖ សិទ្ធិលេងល្បែងកំសាន្ត

❖ សិទ្ធិមានឈ្មោះ មានសញ្ជាតិ និងជាសមាជិកក្នុងសហគមន៍។

❖ ...។ល។

## គ). ការពារ

❖ សិទ្ធិទទួលបានការការពារពីការធ្វើអាជីវកម្មផ្លូវភេទ ឬការរំលោភ

❖ សិទ្ធិទទួលបានការការពារពីការរំលោភបំពានលើរាងកាយ និងស្មារតី

❖ សិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចពលកម្មកុមារ

❖ សិទ្ធិទទួលបានការការពារពីផលលំបាកនៃសង្គ្រាម

❖ សិទ្ធិទទួលបានការការពារពីការជួញដូរ

❖ ...។ល។

## ឃ). ការចូលរួម

❖ សិទ្ធិក្នុងការចូលរួមមតិយោបល់

❖ សិទ្ធិមានសេរីភាពក្នុងការសម្តែងមតិ

❖ សិទ្ធិទទួលបានព័ត៌មានសមស្រប

❖ ...។ល។

# ៣. គោលការណ៍ជាមូលដ្ឋានពាក់ព័ន្ធនឹងសិទ្ធិកុមារ

*ឯកសារភ្ជាប់ ៣.១*

## ៣.១ ការមិនរើសអើង

ការមិនរើសអើងមានន័យថា គ្រប់សិទ្ធិទាំងអស់របស់កុមារត្រូវយកទៅអនុវត្តជាមួយ គ្រប់កុមារ ទាំងអស់ ឬរាល់កុមារទាំងឡាយមានសិទ្ធិដូចគ្នាក្នុងការអភិវឌ្ឍរបស់ពួកគេដោយមិនគិតថាកុមារនោះ :

- ❖ មកពីណា សម្បុរអ្វី មានឬក្រ ធាត់ឬស្គម មានសុខភាពល្អ ឬពិការ
- ❖ កាន់សាសនាអ្វី ឬគ្មានសាសនា
- ❖ មានតែឪពុក ឬមានតែម្ដាយ ឬមានតែជីដូនជីតាចិញ្ចឹម ឬមានតែបងៗជាអ្នកថែរក្សា មានឬ គ្មានផ្ទះ
- ❖ មានឬគ្មានភាសា ជាតិសាសន៍ ឬគំនិតយោបល់ ... ។ល។

ទាំងនេះបង្ហាញឱ្យឃើញថា សិទ្ធិកុមារត្រូវអនុវត្តដោយគ្មានការរើសអើងចំពោះកុមារណាមួយ ឡើយ ។

គោលការណ៍នៃការមិនរើសអើងពុំមែនមានន័យថា កុមារគ្រប់រូបត្រូវបានអនុវត្តសិទ្ធិ ស្មើៗគ្នា ដាច់ខាតនោះទេ គឺតម្រូវទៅតាមស្ថានភាពជាក់ស្ដែង និងតម្រូវការរបស់កុមារម្នាក់ៗ ហើយត្រូវធានា ថាកុមារា ឬកុមារីនោះមានឱកាសពេញលេញក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន និង គ្មានកុមារណាម្នាក់ ដែលមាន សិទ្ធិតិចជាងកុមារផ្សេងទៀតឡើយ ។

ឧទាហរណ៍ :

កុមារគ្រប់រូបនៅក្នុងសហគមន៍មានសិទ្ធិស្មើគ្នាក្នុង :

- ❖ ការទទួលបានសេវាសុខភាព
- ❖ ការចូលរៀននៅសាលារដ្ឋ
- ❖ ការទទួលបានទឹកស្អាតសម្រាប់បរិភោគ
- ❖ ការបញ្ចេញទស្សនៈ និងមតិយោបល់
- ❖ ... ។ល។

នៅក្នុងអនុសញ្ញាស្ដីពីសិទ្ធិកុមារបានចែងយ៉ាងច្បាស់អំពីកាលៈទេសៈ និងតម្រូវការជា ពិសេស សម្រាប់កុមាររបស់ក្រុមជនជាតិភាគតិច ដូចជាកុមារជនជាតិដើមភាគតិច កុមារក្នុង ក្រុមសាសនា តូចៗ ...។ល។ មានករណីមួយចំនួនរដ្ឋាភិបាលត្រូវចាត់វិធានការដើម្បីធានាថា កុមារទាំងឡាយរបស់

ក្រុមភាគតិច ទាំងនោះអាចអនុវត្តនូវប្រពៃណីវប្បធម៌សាសនា ឬនិយាយ ភាសារបស់ក្រុមគេបាន ដោយប្រសើរ ។

ដើម្បីធានាឱ្យមានការអនុវត្តសិទ្ធិកុមារបានពេញលេញ មានកុមារខ្លះត្រូវការ ការថែទាំ និងការយកចិត្តទុកដាក់ជាពិសេសជាងកុមារផ្សេងទៀត ដូចជាកុមារពិការ កុមាររងាយរង គ្រោះជាដើម ។

**ឧទាហរណ៍ :**

កុមារពីរនាក់នៅក្បែរគ្នា តែពួកគេមានឱកាសបានទទួលសិទ្ធិក្នុងការអប់រំខុសគ្នាយ៉ាង ខ្លាំង ដោយសារតែគ្រួសាររបស់កុមារម្នាក់ទៀតមានជីវភាពធូរធារ ហើយអាចបញ្ជូនកូនទៅ សាលាដោយ គ្មានបញ្ហា ។ក្នុងករណីនេះគោលការណ៍នៃភាពមិនរើសអើងបានតម្រូវឱ្យជួយ ឬធ្វើអន្តរាគមន៍នានា ដើម្បីឱ្យ កុមារដែលមានជីវភាពក្រីក្រអាចចូលរៀនដូចកុមារម្នាក់ទៀតដែរ ។

*ឯកសារភ្ជាប់ ៣.២*

## ៣.២ ឧត្តមប្រយោជន៍របស់កុមារ

ឧត្តមប្រយោជន៍របស់កុមារមានន័យថា ជាការគិតគូរជាចម្បងលើផលប្រយោជន៍របស់សង្គម ដោយធ្វើការ ថ្លឹងថ្លែង ពីសិទ្ធិស្វ័យភាពរបស់កុមារ និងតម្រូវការការពាររបស់ពួកគេ ។

នៅពេលដែលឪពុកម្តាយ អ្នកមានកាតព្វកិច្ចទទួលខុសត្រូវ ឬមនុស្សដទៃទៀតដែលជាប់ទាក់ទងនិងការ លើកស្ទួយ និងការការពារកុមារ គិតពិចារណាដើម្បីធ្វើសេចក្តីសម្រេច ដែលពាក់ព័ន្ធនឹងផលប្រយោជន៍កុមារ គេត្រូវចោទសួរខ្លួនឯងថា តើអ្វីទៅជាឧត្តមប្រយោជន៍របស់កុមារ? ហើយការសម្រេចចិត្តរបស់គេផ្តល់នូវ ឧត្តមប្រយោជន៍ដល់កុមារដែរឬទេ? នេះមានន័យថា រាល់សកម្មភាពទាំងឡាយណា ដែលពាក់ព័ន្ធនឹងកុមារ ទោះបីជាអនុវត្តដោយស្ថាប័នសាធារណៈ ឯកជន តុលាការ ឬអង្គការនានាត្រូវ តែយកចិត្តទុកដាក់ជាចម្បង លើឧត្តមប្រយោជន៍របស់កុមារ ។

**ឧទាហរណ៍ :**

បើសិនជាចៅក្រមសម្រេចពីការផ្តល់សិទ្ធិគ្រប់គ្រងកូននៅក្នុងករណី ប្តីប្រពន្ធលែងលះគ្នា ការសម្រេច របស់ចៅក្រមនោះ ត្រូវយោងលើមូលដ្ឋាននៃឧត្តមប្រយោជន៍របស់កុមារ ថាតើឪពុក ឬម្តាយ ដែលកុមារ អាចរស់នៅ បានស្រួលពោលគឺមិនមែនអាស្រ័យលើការចង់បានរបស់ឪពុក ឬម្តាយនោះទេ ។

នៅក្នុងមាត្រាមួយចំនួនរបស់ អនុសញ្ញាស្តីពីសិទ្ធិកុមារក៏បានកំណត់ អំពីឧត្តមប្រយោជន៍របស់កុមារ ផងដែរ ដូចជា ការទំនាក់ទំនងក្នុងគ្រួសារការការពារពីការរំលោភបំពាន ការផ្តល់នូវការថែរក្សា និងការចិញ្ចឹម បីបាច់ ហ្វឹកហ្វឺនដើម្បីអោយមានការអភិវឌ្ឍ និងការការពារបានពេញបរិបូណ៌ ។

ការអនុវត្តតាមប្រពៃណី វប្បធម៌ ដែលធ្វើឡើងដើម្បីឧត្តមប្រយោជន៍របស់កុមារបាន លុះណាតែការអនុវត្ត នោះគោរពបាននូវសិទ្ធិផ្សេងៗទៀត ដូចជា សិទ្ធិក្នុងការទទួលបានសេវាសុខភាពល្អប្រសើរ ជាដើម ហើយត្រូវហាម ឃាត់ទង្វើ និងការអនុវត្តតាមប្រពៃណីមួយចំនួនដែលធ្វើអោយមានការប៉ះពាល់ និងឈឺចាប់ដល់កុមារទាំងផ្នែក រាងកាយ ផ្លូវចិត្ត ស្មារតី សីលធម៌ និងការអភិវឌ្ឍសង្គម ឧទាហរណ៍ : ដូចជា ការព្យាបាលតាមបែបបុរាណ ដោយធ្វើការវាយដំ លើរាងកាយកុមារដើម្បីបណ្តេញខ្មោច ព្រាយ បិសាចជាដើម ។

*ឯកសារភ្ជាប់ ៣.៣*

## ៣.៣ សិទ្ធិរស់រានមានជីវិត និងការអភិវឌ្ឍ

កុមារមានសិទ្ធិក្នុងការរស់រានមានជីវិត និងការអភិវឌ្ឍ មានន័យថាអ្នកពាក់ព័ន្ធទាំងឡាយត្រូវ ធានាថាខ្លួនបានផ្តល់សេវាជាមូលដ្ឋានដល់កុមារ និងផ្តល់ឱកាសស្មើគ្នាសម្រាប់កុមារទាំងអស់ដើម្បីធ្វើ ការអភិវឌ្ឍខ្លួនគេបាន ពេញបរិបូណ៌ ។

**ឧទាហរណ៍ :**

បើមានទារកកើត ឪពុក ឬម្តាយមានកាតព្វកិច្ចត្រូវទៅរាយការណ៍ចុះសៀវភៅកំណើត នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារកនោះ ។ ការចុះសំបុត្រកំណើត នេះធ្វើអោយកុមារមានឈ្មោះ និងទទួលបាននូវមធ្យោបាយផ្សេងៗសម្រាប់រស់រាន និងអភិវឌ្ឍន៍របស់ពួកគេ។ សំបុត្រកំណើតផ្តល់អោយកុមារនូវអត្តសញ្ញាណស្របច្បាប់នៅក្នុងប្រទេស ឬជាតិសាសន៍របស់ពួកគេ។ អត្តសញ្ញាណ ស្របច្បាប់នេះ ជាមូលដ្ឋានដែលជួយអោយកុមារ បានទទួលនូវប្រព័ន្ធសេវានានា ដូចជាសេវាសុខភាព សេវាអប់រំ ជាដើម។ បើកុមារមិនមានសំបុត្រ កំណើតដែលជាភស្តុតាងនៃអត្តសញ្ញាណ និងសិទ្ធិត្រូវទទួលបាននោះពួកគេ មិនអាចទទួលបាននូវសេវា សង្គម ដែលជាមធ្យោបាយសម្រាប់រស់រាន និងអភិវឌ្ឍន៍បានឡើយ ។

*ឯកសារភ្ជាប់ ៣.៤*

## ៣.៤ គោរពមតិយោបល់របស់កុមារ

ការគោរពមតិយោបល់របស់កុមារ មានន័យថា មតិយោបល់របស់កុមារមានសារៈសំខាន់ណាស់ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។ ដូច្នេះ ទស្សនៈ និងការយល់ឃើញរបស់កុមារ ត្រូវបានគេយក ទៅពិចារណាយ៉ាងល្អិតល្អន់ មុនពេលធ្វើសេចក្តីសម្រេចចិត្ត ។ គោលការណ៍នេះ មានទំនាក់ទំនងទៅនឹង ឧត្តមប្រយោជន៍របស់កុមារផងដែរ ដូចនេះកុមារគប្បីចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចនានា ដែលប៉ះពាល់ដល់

ផលប្រយោជន៍របស់ពួក គេទៅតាមអាយុសមស្របរបស់កុមារ។ កុមារមានសិទ្ធិ និងលទ្ធភាពក្នុងការបង្កើត នូវការយល់ឃើញរបស់ខ្លួន និងបង្ហាញនូវការយល់ឃើញទាំងនោះដោយសេរី ពិសេសនៅពេលដែលមាន ការប៉ះពាល់ដល់ពួកគេ ។

**ឧទាហរណ៍ :**

កុមារម្នាក់គិតថា ទៅសាលារៀនជាការខាតបង់ពេលវេលាយ៉ាងច្រើន តែដើម្បីបំពេញនូវឧត្តម ប្រយោជន៍ គេបានជំរុញអោយកុមារនោះចូលរៀនតាមអាយុដែលបានកំណត់ ។ ពេលនោះកុមារបាន បង្ហាញនូវ ការយល់ឃើញ របស់ខ្លួនថា សាលាមានបរិស្ថានមិនល្អ គ្មានទីធ្លាសម្រាប់រត់លេងជាដើម ។ គំនិតរបស់កុមារ នេះត្រូវបានគេយកទៅ ពិចារណា ហើយបានចូលរួមចំណែកក្នុងការកែលម្អប្រព័ន្ធអប់រំ និងជួយអោយបរិស្ថាន សាលាកាន់តែល្អប្រសើរឡើង។ ការធ្វើការកែលម្អទាំងនេះបានផ្តល់ផលប្រយោជ ន៍ ដល់កុមារទូទៅផងដែរ ។

# ៤. កត្តាដែលនាំអោយមានការ រំលោភបំពានសិទ្ធិកុមារ

ការរំលោភបំពានលើសិទ្ធិកុមារមានទំនាក់ទំនងទៅនឹង :

- ❖ ស្ថានភាពរស់នៅរបស់កុមារ
- ❖ សហគមន៍ និងបរិស្ថានដែលកុមាររស់នៅ

*ឯកសារភ្ជាប់ ៤.១*

## ៤.១ ស្ថានភាពរស់នៅរបស់កុមារ

➢ **ស្ថានភាពគ្រួសារ :**

- កុមាររស់ក្នុងគ្រួសារដែលក្រីក្រ ឬក្រីក្របំផុត តែពេលខ្លះកុមារដែលរស់នៅក្នុងគ្រួសារដែលមានជីវភាពធូធារ ក៏អាចទទួលរងនូវការរំលោភបំពានសិទ្ធិរបស់ខ្លួនដែរ ។

- កុមាររស់ក្នុងគ្រួសារដែលឪពុកម្តាយលែងលះគ្នា ឬឪពុកម្តាយដែលប្រព្រឹត្តអំពើហិង្សា ។

- កុមាររស់នៅក្នុងគ្រួសារដែលមានសមាជិកគ្រួសារច្រើន ( មានបងប្អូនច្រើននាក់ ) ។

- កុមាររស់នៅជាមួយឪពុក ឬម្តាយចុង

➢ **ស្ថានភាពកុមារ :**

- កុមារកំព្រា

- កុមារពិការ

- កុមារជាមេគ្រួសារដែលត្រូវចិញ្ចឹមប្អូនៗច្រើននាក់

- ... ។ល ។

## ៤.២ សហគមន៍ និងបរិស្ថានដែលកុមាររស់នៅ

- ខ្វះការទទួល និងផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិកុមារ

- ចំណេះដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត

- មានការទទួលស្គាល់ថា ការរំលោភបំពានលើរាងកាយជាករណីធម្មតា

- មិនទាន់មានអង្គការ ស្ថាប័នដើម្បីជួយកុមារនៅតាមសហគមន៍

- ប្រជាពលរដ្ឋខ្លះមានការរើសអើងចំពោះកុមារ ( ឧទាហរណ៍ : អ្នកខ្លះស្រលាញ់កូនស្រី ហើយមិនចូលចិត្តកូន ប្រុស ឬមានការរើសអើងចំពោះកុមារមានជំងឺអេដស៍ ឬកុមារពិការជាដើម ) ។

- ប្រជាពលរដ្ឋខ្លះចាត់ទុកកូនថា ជាកម្មសិទ្ធិផ្តាច់មុខរបស់ខ្លួន

- ដំណោះស្រាយករណីរំលោភបំពានលើកុមារ តាមរយៈការសម្រុះសម្រួលជាលុយកាក់រវាងជន ល្មើស និងជនរងគ្រោះដែលខុសនឹងនីតិវិធីច្បាប់ ។

- ការព្យាបាលតាមបែបបុរាណដែលខុសឆ្គង

- ... ។ល ។

# ៥. ការដោះស្រាយបញ្ហាការរំលោភសិទ្ធិកុមារ

*ឯកសារភ្ជាប់ ៥.១*

**+ សកម្មភាពសំខាន់ៗមានដូចខាងក្រោម :**

- ផ្សព្វផ្សាយនៅក្នុងសហគមន៍អំពីសិទ្ធិរបស់ស្ត្រី និងកុមារ
- ប្រមូលព័តិមានទាក់ទងនឹងបញ្ហារបស់ស្ត្រី និងកុមារ
- រៀបចំផែនការ និងអនុវត្តផែនការដើម្បីជួយអោយជីវិតរបស់ស្ត្រី និងកុមារបានប្រសើរឡើង
- បង្រៀនសហគន៍អំពីបញ្ហាស្ត្រី និងកុមារ និងវិធីដោះស្រាយ
- ជួយជំរុញអោយមានការផ្តល់សេវាសម្រាប់ស្ត្រី និងកុមារកាន់តែល្អប្រសើរឡើង
- លើទឹកចិត្តស្ត្រីអោយចូលរួមយ៉ាងសកម្ម ក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច ពិសេសការសម្រេចដែលពាក់ព័ន្ធនឹងស្ត្រី និងកុមារ
- ជួយអោយកុមារចាកផុតពីការរំលោភ និងការកេងប្រវ័ញ្ចគ្រប់យ៉ាង
- ជំរុញអោយមានការចុះបញ្ជីកំណើតដល់កុមារ
- ជំរុញឪពុកម្តាយអោយនាំកូនទៅទទួលថ្នាំបង្ការគ្រប់មុខ និងមានការរស់នៅបានល្អប្រសើរ
- ...។ល។

*ឯកសារភ្ជាប់ ៥.២*

## ៥.១ អ្នកទាមទារសិទ្ធិ និងអ្នកមានភាតព្វកិច្ចទទួលខុសត្រូវ

### ក). អ្នកទាមទារសិទ្ធិ

អ្នកទាមទារសិទ្ធិ គឺជាមនុស្សដែលមានការចាប់អារម្មណ៍លើបញ្ហាមានការជាប់ទាក់ទិន នឹងបញ្ហា និងមានចំណែកក្នុងបញ្ហានោះ ហើយត្រូវការការគាំទ្រ និងទទួលជំនួយពីអ្នកមានកាតព្វកិច្ចទទួលខុស ត្រូវ ។

អ្នកទាមទារសិទ្ធិនៅក្នុងសហគមន៍មានដូចជា :

- កុមារ
- ឪពុកម្តាយ
- អង្គការមិនមែនរដ្ឋាភិបាល
- អ្នកផ្តល់សេវាអប់រំ
- អ្នកផ្គត់ផ្គង់សេវាសុខភាព
- ...។ល។

**ខ). អ្នកមានកាតព្វកិច្ចទទួលខុសត្រូវ**

អ្នកមានកាតព្វកិច្ចទទួលខុសត្រូវ គឺជាអ្នកមានកាតព្វកិច្ចក្នុងការដោះស្រាយបញ្ហាពីព្រោះ គេមានធនធាន ចំណេះដឹង អំណាច និងការគ្រប់គ្រងដែលអាចដោះស្រាយបញ្ហា ឬអាចកែប្រែគោលការនយោ បាយបាន ។

អ្នកមានកាតព្វកិច្ចទទួលខុសត្រូវ ដែលមាននៅក្នុងសហគមន៍ ដូចជា :

- ប្រធានប៉ុស្តិ៍នគរបាល រដ្ឋាបាលឃុំ សង្កាត់ជាអ្នកការពារកុមារពីការកេងប្រវ័ញ្ច

- ប្រធានមណ្ឌលសុខភាពឃុំ សង្កាត់ ជាអ្នកជួយថែទាំសុខភាពកុមារ

- គណៈគ្រប់គ្រងផ្នែកសិក្សាធិការឃុំ សង្កាត់ជាអ្នកជួយកុមារអោយទទួលបានការអប់រំល្អប្រសើរ

- អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើបញ្ហារបស់កុមារ

- ព្រះសង្ឃ គ្រូបង្រៀន អ្នកតំណាងភូមិចូលរួមជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធឱ្យ សម្រេចតួនាទីរបស់ខ្លួន ។

អ្នកមានកាតព្វកិច្ចទទួលខុសត្រូវមាននៅច្រើនថ្នាក់ដូចជា នៅថ្នាក់ឃុំ សង្កាត់ ថ្នាក់ស្រុក ខណ្ឌ ថ្នាក់ ខេត្ត ក្រុង និងថ្នាក់ជាតិជាដើម ។

នៅពេលមានបញ្ហា និងសិទ្ធិមួយចំនួនត្រូវបានរំលោភ ចាំបាច់ត្រូវទាមទាររក អ្នកមានកាតព្វកិច្ច ទទួលខុសត្រូវ ទាំងនៅថ្នាក់ស្រុក ខណ្ឌ និងឬនៅថ្នាក់ខេត្ត ក្រុង ។ គួររំលឹកថា មុននឹងអ្នកចេញទៅខាង ក្រៅស្វែងរកជំនួយ អ្នកត្រូវជួយទាក់ទងជាមួយអ្នកមានកាតព្វកិច្ចទទួលខុសត្រូវនៅថ្នាក់ឃុំ សង្កាត់ របស់អ្នកជាមុនសិន ។ ជយនកាលគេ អាចមានចម្លើយ ឬដំណោះស្រាយចំពោះបញ្ហារំលោភសិទ្ធិកុមារបាន ។ ដូច្នេះអ្នកមិនគួរបំភ្លេចពីធនធានដែលអាច ប្រើប្រាស់បាននៅថ្នាក់ឃុំ សង្កាត់ឡើយ ។

*ឯកសារភ្ជាប់ ៥.៣*

## ៥.២ ការកំណត់សិទ្ធិដែលត្រូវបានគេរំលោភ

បញ្ហាដែលបានបរិយាយនៅក្នុងតារាងខាងក្រោម គ្រាន់តែជា ឧទាហរណ៍ប៉ុណ្ណោះ ។

| ល.រ | ឧទាហរណ៍ | សិទ្ធិដែលត្រូវបានគេរំលោភ |
|---|---|---|
| ១ | ទារក ៦០% មិនបានចាក់ថ្នាំបង្ការជំងឺ | សិទ្ធិទទួលសេវាសុខភាព និងសិទ្ធិរស់រានមានជីវិត |
| ២ | មានកុមារអាយុ៣ទៅ៥ឆ្នាំ ចំនួនត្រឹមតែ២.១% ប៉ុណ្ណោះបានចុះឈ្មោះចូលរៀននៅមត្តេយ្យសាលារដ្ឋ | សិទ្ធិក្នុងការអភិវឌ្ឍ សិទ្ធិទទួលការអប់រំ |
| ៣ | ក្នុងចំណោមកម្មករឡឥដ្ឋ៣០នាក់មានកុមារ១០នាក់ ដែលមានអាយុពី១២ឆ្នាំ ទៅ ១៤ឆ្នាំ | សិទ្ធិទទួលការការពារពីការកេងប្រវ័ញ្ចកម្លាំង ពលកម្មកុមារសិទ្ធិក្នុងការអភិវឌ្ឍ |
| ៤ | កុមារទទួលរងការរំលោភបំពាន លើរូបរាងកាយ | សិទ្ធិទទួលការការពារពីការរំលោភបំពាន |

| | | |
|---|---|---|
| | ដោយសារអំពើហិង្សាក្នុងគ្រួសារ | |

*ឯកសារភ្ជាប់ ៥.៤*

## ៥.៣ ការកំណត់អ្នកមានភាតព្វកិច្ចទទួលខុសត្រូវ

| ល.រ | ឧទាហរណ៍ | អ្នកមានកាតព្វកិច្ចទទួលខុសត្រូវ |
|---|---|---|
| ១ | ទារក ៦០% មិនបានចាក់ថ្នាំបង្ការជំងឺ | អ្នកផ្តល់សេវាសុខភាពនៅគ្រប់កម្រិត ទាំងអស់របស់រដ្ឋាភិបាល ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក |
| ២ | មានកុមារអាយុ៣ទៅ៥ឆ្នាំ ចំនួនត្រឹមតែ២.១% ប៉ុណ្ណោះបានចុះឈ្មោះចូលរៀននៅមត្តេយ្យសាលារដ្ឋ | ឪពុក ម្តាយ គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀនក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក |
| ៣ | ក្នុងចំណោមកម្មករឡូតដ្ឋ៣០នាក់មានកុមារ១០នាក់ដែលមានអាយុពី១២ឆ្នាំ ទៅ ១៤ឆ្នាំ | ឪពុកម្តាយ មន្ត្រីក្រសួង មន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ម្ចាស់សិប្បកម្មឡូតដ្ឋ ក្រុមប្រឹក្សាឃុំ គ.ក.ន.ក |

## ៥.៤ ការគិតពិចារណាប្រកបដោយគំនិតច្នៃប្រឌិត

**+ ករណីការចាក់ថ្នាំបង្ការ**

ក្នុងករណីដែលឪពុកម្តាយ មិនចង់បញ្ជូនកូនទៅទទួលថ្នាំបង្ការក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកទទួលបន្ទុកកិច្ចការ នារី និងកុមារគួរបង្កើតគំនិតផ្តួចផ្តើម ដើម្បីបញ្ចុះបញ្ចូលឪពុកម្តាយអោយយកកូនរបស់គាត់ទៅទទួលថ្នាំបង្ការបាន គ្រប់ចំនួន ។ ខាងក្រោមនេះ ជាឧទាហរណ៍មួយចំនួនដែលអាចប្រើបាន :

- ជារឿងធម្មតាទេ ក្រោយពីទទួលថ្នាំបង្ការកុមារតែងតែគ្រុនក្តៅ ពីរ បីថ្ងៃ ដែលនេះជាសញ្ញានៃប្រសិទ្ធិភាព របស់ថ្នាំបង្ការនោះ ។
- គ្រុនពីរបីថ្ងៃ ប្រសើរជាជាងបណ្តោយអោយកុមារពិការមួយជីវិត
- នេះជាវិធីតែមួយគត់ សម្រាប់កាត់បន្ថយអត្រាស្លាប់របស់កុមារ ដូច្នេះ ឪពុកម្តាយគ្រប់ៗរូបត្រូវតែយកកូន ទៅចាក់ថ្នាំបង្ការអោយបានគ្រប់ចំនួន។
- ការចាក់ថ្នាំបង្ការទាំងនេះ អាចការពារកូនអ្នកពីជំងឺឆ្លងផ្សេងៗ
- ការចាក់ថ្នាំបង្ការធានាអោយកុមារមានសុខភាពល្អ ។ សុខភាពល្អគឺជាសិទ្ធិជាមូលដ្ឋានរបស់ កុមារ ។

អ្នកអាចបង្កើតគំនិតថ្មីៗផ្សេងទៀត ដើម្បីធ្វើយ៉ាងណាអោយឪពុកម្តាយព្រមនាំកូនរបស់គេទៅទទួលថ្នាំបង្ការ បានគ្រប់ចំនួន ។

**+ ករណីឪពុកម្តាយវាយកូន**

ក្នុងករណីដែលឳពុកម្តាយ វាយកូនរបស់ខ្លួនក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ គួរបង្កើតគំនិតដើម្បីពន្យល់ឳពុក ម្តាយ អោយបញ្ឈប់នូវការវាយកូនរបស់ខ្លួន ។

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួនដែលអាចប្រើបាន :

- អ្នកមិនមែនកំពុងប្រដៅអប់រំកូនទេ នៅពេលដែលអ្នកវាយធ្វើបាបកូនខ្លួនឯងដូច្នេះនោះ ។ ផ្ទុយទៅវិញ អ្នកកំពុងរំលោភសិទ្ធិកូនរបស់អ្នក ហើយព្រមទាំងធ្វើអោយកូនរបស់អ្នករងរបួសរូបរាងកាយ ទៀតផង ។

- អំពើរបស់អ្នកអាចធ្វើអោយកុមារពិការរូបរាងកាយអស់មួយជីវិត

- អ្នកនឹងធ្វើអោយកូនរបស់អ្នកឃ្លាតឆ្ងាយពីអ្នក ប្រសិនបើអ្នកបន្តធ្វើបែបនេះតទៅទៀតនោះ ។ កូនរបស់អ្នក និងមិនស្រលាញ់អ្នកនៅពេលដែលគេធំឡើង ហើយគេនឹងរត់ចេញឆ្ងាយពីអ្នកតាមតែគេ អាចធ្វើទៅបាន ។

- នៅពេលអ្នកកំពុងវាយធ្វើបាបកូនយ៉ាងនេះ គឺដូចជាកំពុងប្រព្រឹត្តបទល្មើស ( បង្ករបួសស្នាម ) ហើយ នគរបាលអាចធ្វើការចោទប្រកាន់រូបអ្នកបាន ។

- តើអ្នកគិតថាកូនរបស់អ្នកអាចធ្វើតាមអ្នកឬទេនៅពេលគេធំឡើង?

ដូចជា គេអាចនឹងវាយកូនរបស់គេដូចអ្នកវាយគេអញ្ចឹងដែរ ។ អ្នកអាចបង្កើតគំនិតថ្មីៗផ្សេងទៀត ដើម្បីធ្វើ យ៉ាងណាអោយឳពុក ម្តាយបញ្ឈប់ការវាយធ្វើបាបកូនរបស់គេទៀត ។

**+ ករណីឳពុក ម្តាយមិនចង់បញ្ជូនកូនស្រីទៅសាលារៀន**

ក្នុងករណីឳពុក ម្តាយមិនចង់បញ្ជូនកូនស្រីទៅរៀនបន្ត ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកទទួលបន្ទុកកិច្ច ការនារី និងកុមារ គួរបង្កើតគំនិងផ្តួចផ្តើមដើម្បី បញ្ចុះបញ្ចូលឳពុកម្តាយអោយយល់ព្រម ។

**ខាងក្រោមនេះជាឧទាហរណ៍មួយចំនួន :**

- ឳពុកម្តាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំអោយមានក្រុមស្ម័គ្រចិត្តបុរស១ ដែលជាសាច់ ញាតិរបស់ក្រុម គ្រួសារក្មេងស្រីនោះ ដូចជាបុរសពេញវ័យ ឬបងប្រុស អាចទទួលខុសត្រូវក្នុងការជូន ក្មេងស្រីទៅ និងមកពីសាលា រៀន ។

- អ្នកអាចសំណូមពរអោយមន្ត្រីនគរបាល ផ្តល់សន្តិសុខបន្ថែមទៀតនៅពេលដែលក្មេងស្រីទៅ និង មកពី សាលារៀន ។

- អ្នកអាចលើកឡើងថា សិស្សប្រុស១អាចជូនដំណើរក្មេងស្រីទៅនិងត្រឡប់មកពីសាលារៀននៅ ក្រៅភូមិ ។

- អ្នកអាចលើកឡើងថា សហគមន៍ទាំងអស់គ្នាអាចចូលរួមចំណែកជាប្រាក់ដើម្បីទិញយានយន្ត ឬ រ៉ឺម៉កប្រើ ប្រាស់ដើម្បីដឹកជញ្ជូនសិស្សទៅ និងមកពីសាលារៀន ។

- អ្នកអាចលើកឡើងថា ប្រសិនបើក្មេងស្រីទទួលបានការអប់រំខ្ពស់នោះគេអាចធ្វើការ និងរកប្រាក់ចំណូលបាន ច្រើនជាងក្មេងស្រីដែលទទួលការអប់រំតិច ។ លើសពីនេះទៀត គេអាចជួយអោយជីវភាពគ្រួសារបានប្រសើរ ឡើងផងដែរ ។ ដូច្នេះគប្បីផ្តល់ឱកាសអោយកូនស្រីទៅរៀនបន្តជាការល្អបំផុតសម្រាប់ជីវភាពគ្រួសារអ្នក ។

អ្នកអាចបង្កើតគំនិតថ្មីៗផ្សេងទៀត ដើម្បីធ្វើយ៉ាងណាអោយឪពុកម្តាយយល់ព្រមអនុញ្ញាតអោយកូនស្រី របស់គេទៅរៀនបន្ត ។

# ផ្នែក ទី៣

# កិច្ចការពារកុមារ

# ១. កុមារត្រូវការកិច្ចការពារពិសេស

*ឯកសារភ្ជាប់ ១.១*

- កុមារ គឺជាមនុស្សគ្រប់រូបដែលស្ថិតក្នុងដំណើរការវិវឌ្ឍន៍ ហើយមានអាយុចាប់ពីសូន្យឆ្នាំ ដល់ក្រោម១៨ឆ្នាំ ។
- **កុមារដែលងាយរងគ្រោះ** គឺកុមារដែលរស់នៅក្នុងកាលៈទេសៈលំបាក ហើយប្រឈមមុខនឹងគ្រោះថ្នាក់ប៉ុន្តែពុំទាន់មានការប៉ះពាល់ដល់ការអភិវឌ្ឍរបស់ពួកគេ ។
- **កុមារត្រូវការកិច្ចការពារពិសេស** គឺជាកុមារដែលស្ថិតក្នុងកាលៈទេសៈលំបាកពិសេស ឬកុមារដែលមានគ្រោះថ្នាក់ហើយមានការប៉ះពាល់ដល់ការអភិវឌ្ឍរបស់ពួកគេ ។
- **ការអភិវឌ្ឍរបស់កុមារ** គឺជាដំណើរការនិងយន្តការដែលត្រូវប្រតិបត្តិនៅក្នុងរយៈពេលនៃការអភិវឌ្ឍខាងរាងកាយ ចិត្តសាស្ត្រនិងប្រាជ្ញាស្មារតីរបស់កុមារដើម្បីក្លាយជាមនុស្សពេញវ័យ ។
- **ដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារ គឺៈ**
  - ទារកអាយុពី 0-១២ខែ ( ១ឆ្នាំ )
  - កុមារវ័យដំបូងពី ១-៦ឆ្នាំ
  - វ័យកុមារភាព ៦-១២ឆ្នាំ
  - កុមារវ័យជំទង់អាយុពី ១២-ក្រោម១៨ឆ្នាំ

*ឯកសារភ្ជាប់ ១.២*

## ១.១. កុមារដែលត្រូវការកិច្ចការពារពិសេស

+ កុមារដែលត្រូវការកិច្ចការពារពិសេសមាន ៩ប្រភេទ ដូចជា :

- កុមារកំព្រា
- កុមារពិការ
- កុមារត្រូវគេបោះបង់ចោល
- កុមារត្រូវគេកេងប្រវ័ញ្ចឱ្យធ្វើការងារប្រកបដោយគ្រោះថ្នាក់
- កុមាររងផលប៉ះពាល់ពីមេរោគអេដស៍ ឬជំងឺអេដស៍
- កុមាររងគ្រោះពីអំពើហិង្សា
- កុមារចាកចេញទៅក្រៅសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ
- កុមារទំនាស់នឹងច្បាប់

- កុមារត្រូវគេរំលោភផ្លូវភេទ ឬកុមារត្រូវគេកេងប្រវ័ញ្ចផ្លូវភេទ ឬកុមារត្រូវគេជួញដូរ
- ...។ល ។

*ឯកសារភ្ជាប់ ១.៣*

**១.២. សារៈប្រយោជន៍នៃការចុះសំបុត្រកំណើត**

ការចុះសំបុត្រកំណើតកុមារ ជាមូលដ្ឋានគ្រឹះមួយក្នុងកិច្ចការពារកុមារ ដូច្នេះបើមានទារកកើត ឪពុក ឬម្តាយមានកាតព្វកិច្ចត្រូវទៅរាយការណ៍ចុះសៀវភៅអាត្រានុកូលដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារកនោះមិនឱ្យហួស៣០ថ្ងៃ។ ការចុះសំបុត្រកំណើតនេះផ្តល់សារៈប្រយោជន៍ជាច្រើនដូចជាៈ **ក). សារៈប្រយោជន៍សម្រាប់កុមារផ្ទាល់**

- កុមារមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអត្តសញ្ញាណស្របច្បាប់
- កុមារទទួលបាននូវមធ្យោបាយផ្សេងៗសម្រាប់រស់រាន និងអភិវឌ្ឍន៍
- កុមារមានឯកសារភ្ជាប់សម្រាប់ចុះឈ្មោះចូលរៀនបឋមសិក្សា
- កុមារមានសិទ្ធិទទួលកេរមរតិក
- កុមារមានសិទ្ធិការពារខ្លួនពីការធ្វើការងារធ្ងន់ធ្ងរ
- កុមារដែលមានអាយុក្រោម១៣ឆ្នាំ មិនត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ
- កុមារទទួលបាននូវការការពារពីច្បាប់ក្នុងកាតព្វកិច្ចបម្រើជាតិ ដូចជាចូលបម្រើក្នុងជួរកងទ័ពជាដើម
- កុមារដែលមានអាយុក្រោម១៥ឆ្នាំទទួលបាននូវការការពារពីច្បាប់ នៅពេលដែលមានមនុស្សពេញវ័យចង់ទំនាក់ទំនងផ្លូវភេទជាមួយខ្លួន (មាត្រា៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស)។
- ...។ល។

**ខ). សារៈប្រយោជន៍សម្រាប់អាជ្ញាធរមូលដ្ឋាន**

- អាចគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋបានត្រឹមត្រូវ
- ងាយស្រួលពិនិត្យតាមដានចំពោះសេវាមូលដ្ឋាន ដែលត្រូវផ្តល់ចំពោះកុមារទៅតាមអាយុ
- ដឹងពីអត្រាកំណើតរបស់កុមារ
- ងាយស្រួលទប់ស្កាត់ការកេងប្រវ័ញ្ចពលកម្មកុមារ
- អាចជួយឱ្យការចាក់ថ្នាំបង្ការបានដល់កុមារសុក្រឹត
- កុមារអាចចូលរៀនតាមអាយុពិតប្រាកដ
- ...។ល។

# ២. កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា

*ឯកសារភ្ជាប់ ២.១*

❖ **កុមារដែលត្រូវគេបោះបង់ចោល** គឺជាកុមារដែលឪពុកម្តាយ ឬអ្នកផ្តល់ការថែទាំបឋមទុកចោលនៅតាមមន្ទីរពេទ្យ តាមទីសាធារណៈ ឬនៅកន្លែងណាមួយហើយចាកចេញទៅកាន់កន្លែងមួយផ្សេងទៀត ឬជាកុមារដែលឪពុកម្តាយបដិសេធពុំមើលថែ ។

❖ **កុមារកំព្រា** គឺកុមារដែលគ្មានឪពុកម្តាយ ( ឪពុក ម្តាយស្លាប់ ) ។

❖ **តើត្រូវដោះស្រាយយ៉ាងដូចម្តេច ចំពោះកុមារត្រូវគេបោះបង់ចោល និងកុមារកំព្រា ?**

ដំណោះស្រាយអាចមានដូចជា :

❖ ស្វែងរកមធ្យោបាយសម្រាប់ថែទាំកុមារក្នុងរយៈពេលខ្លី ។

តើកុមារមានញាតិសន្តាននៅក្នុងភូមិ ឬនៅភូមិក្បែរដែរឬទេ ?

- បើមានញាតិសន្តាន ពួកគេប្រហែលជាអាចទទួលយកកុមារទាំងនេះទៅចិញ្ចឹមមួយរយៈ ។

- បើគ្មានញាតិសន្តានទេ ប្រហែលជាអ្នកជិតខាងដែលមានសន្តានចិត្តល្អ អាចទទួលយកកុមារទាំងនេះទៅថែរក្សាមួយរយៈបាន ។

- បើគ្មានញាតិសន្តាន និងអ្នកជិតខាងណាអាចថែទាំកុមារទាំងនេះក្នុងរយៈពេលខ្លីបានទេ ត្រូវបញ្ជូនកុមារទាំងនេះទៅកន្លែងស្នាក់នៅសុវត្ថិភាពបណ្តោះអាសន្ន ដូចជាវត្តអារាម មណ្ឌលកុមារកំព្រា... ។ល។

➢ ប្រឹងប្រែង ព្យាយាមទាក់ទង ឬស្វែងរកឪពុកម្តាយរបស់កុមារ ។ ប្រហែលជាញាតិសន្តានដទៃទៀត ដឹងថាឪពុកម្តាយរបស់កុមារនេះនៅឯណា ឬមេភូមិ មេឃុំ ចៅសង្កាត់អាចតាមរក ឪពុកម្តាយ ។ ការស្វែងរកទាំងនេះត្រូវចំណាយកំលាំង ធនធាន និង ពេលវេលាច្រើន ប៉ុន្តែវាជាការសំខាន់សម្រាប់អនាគតរបស់កុមារ ។

❖ ប្រសិនបើអាចទាក់ទងជាមួយឪពុកម្តាយបាន ឪពុកម្តាយត្រូវសម្រេចចិត្ត ថាតើត្រូវត្រឡប់មកមើលថែកូនៗរបស់ខ្លួនវិញឬបោះបង់កូនចោល ។ បើឪពុកម្តាយសម្រេចចិត្តបោះបង់កូនចោលអ្នកត្រូវទាក់ទងមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ដើម្បីស្វែងរកការថែទាំរយៈពេលយូរអង្វែងសម្រាប់កុមារទាំងនោះ ។

- ប្រសិនបើមានអ្នកជិតខាងនៅក្នុងភូមិមានបំណង និងមានលទ្ធភាពទទួលយកកុមារទៅចិញ្ចឹម នោះគឺជាដំណោះស្រាយមួយដ៏ប្រសើរបំផុត ដោយសារតែកុមារអាចបន្តរស់នៅក្នុងភូមិកំណើត ហើយអាចទៅរៀនជាមួយមិត្តភក្តិរបស់ពួកគេបន្តទៀតបាន ។
- ឬអាចប្រើមធ្យោបាយសមស្របផ្សេងទៀត ដែលអាចជួយដល់កុមារបាន ។

# ៣.កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា

អំពើហិង្សាក្នុងគ្រួសារ សំដៅលើអំពើហិង្សា ឬការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកជីវភាពសេដ្ឋកិច្ចដែលត្រូវប្រព្រឹត្តដោយមនុស្សម្នាក់ ឬច្រើននាក់ ដើម្បីត្រួតត្រាលើមនុស្សផ្សេងទៀត ដែលកំពុងរស់នៅក្នុងគ្រួសារនោះ ។

*ឯកសារភ្ជាប់ ៣.១*

## ៣.១. ផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារលើកុមារ

កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា អាចទទួលរងផលប៉ះពាល់ភ្លាមៗនិងផលប៉ះពាល់រយៈ ពេលយូរ ។

**ក). ផលប៉ះពាល់ភ្លាមៗ មានដូចជា :**

- របួសលើរាងកាយដូចជា ស្នាមជាំ បាក់ដៃ បាក់ជើង បាក់ឆ្អឹង ជាំភ្នែក ...
- ដេកមិនលក់ យល់សុបិន្តអាក្រក់
- ហូបមិនបាន
- មានភាពតានតឹងក្នុងអារម្មណ៍
- មិនចង់លេងសើចជាមួយកុមារដទៃ ឬផ្តាច់ខ្លួនពីសង្គម
- ពិបាកទំនាក់ទំនងជាមួយអ្នកដទៃដូចជា មិនចូលចិត្តឱ្យគេប៉ះ
- កើតទុកក្រៀមក្រំ និងមានភាពស្រងេះស្រងោច
- មានសភាពភ័យខ្លាច
- ឆាប់ខឹង ងាយនឹងប្រព្រឹត្តអំពើឃោឃៅ
- មានបញ្ហាក្នុងការផ្តោតអារម្មណ៍ ឬរៀនមិនពូកែ
- ខ្វះការជឿជាក់លើខ្លួនឯង
- ... ។ល ។

**ខ). ផលប៉ះពាល់រយៈពេលយូរ មានដូចជា :**

- កុមារដែលទទួលរងអំពើហិង្សាក្នុងគ្រួសារញឹកញាប់ ពិបាកដឹងពីវិធីសាស្ត្រដោះស្រាយទំនាស់ឱ្យបានត្រឹមត្រូវ ។
- កុមារអាចចម្លងយកឥរិយាបថពីឪពុកម្ដាយ ដូចជាធំពេញវ័យ គេអាចក្លាយទៅជាអ្នកប្រព្រឹត្តអំពើហិង្សាទៅលើមិត្តភក្តិឬប្រពន្ធ ប្ដី ឬគេអាចក្លាយជាអ្នកដែលព្រមទទួលយក និងស៊ូទ្រាំអត់ធ្មត់រស់ក្នុងអំពើហិង្សាជាដើម ។
- កុមាររងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារអាចរត់ចេញពីផ្ទះ និងអាចក្លាយជាកុមាររស់នៅតាមចិញ្ចើមថ្នល់ ។
- ...។ល។

*ឯកសារភ្ជាប់ ៣.២*

## ៣.២. ដំណោះស្រាយ

ដោះស្រាយចំពោះកុមារ ដែលទទួលរងគ្រោះថ្នាក់ដោយអំពើហិង្សាក្នុងគ្រួសារអាចមានដូចជា :

**ក). ចំពោះករណីស្រាល**

- បើញាតិសន្តាន គ្រូបង្រៀន អ្នកជិតខាង ព្រះសង្ឃ មិត្តភក្តិសង្ស័យថាកុមារត្រូវគេវាយដំត្រូវរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតដើម្បីសុំអន្តរាគមន៍ ។
- បើមានអំពើហិង្សាកើតឡើងក្នុងគ្រួសារម្ដងម្កាល ឬពុំសូវញឹកញាប់ សាច់ញាតិ ចាស់ទុំ មិត្តភក្តិ មេភូមិ មេឃុំ ចៅសង្កាត់ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតធ្វើការអប់រំណែនាំដល់ឪពុកម្ដាយ ឬអ្នកប្រព្រឹត្តិហិង្សាថា ការវាយដំកូនមិនត្រឹមតែបង្កគ្រោះថ្នាក់ដល់រាងកាយ ផ្លូវចិត្ត និងសុខភាពខាងសតិអារម្មណ៏របស់កុមារប៉ុណ្ណោះទេ ប៉ុន្តែការវាយដំកុមារ ក៏អាចបណ្ដាលឱ្យមានរបួសធ្ងន់ធ្ងរ ហើយជាសកម្មភាពដែលប្រឆាំងនឹងច្បាប់របស់ប្រទេសកម្ពុជាយើងទៀតផង ។ ដូច្នេះបើអ្នកវាយដំកូនធ្ងន់ធ្ងរនោះអ្នកត្រូវមានទោស ហើយអាចជាប់ពន្ធធានាគារទៀតផង។
- ហេតុផលនេះអាចគ្រប់គ្រាន់ឱ្យឪពុក ម្ដាយបញ្ឈប់ការវាយដំកូនរបស់គេ ។

**ខ). ចំពោះករណីធ្ងន់ធ្ងរ**

- បើភាពរំលោភបំពានមានភាពធ្ងន់ធ្ងរខ្លាំង ឬកើតមានជាបន្តបន្ទាប់ឬមានរយៈពេលយូរ ឬកើតឡើងជាប្រចាំ មេភូមិ ឬភ្នាក់ងារស្ម័គ្រចិត្តភូមិ (ក្នុងតំបន់មានបណ្ដាញការពារកុមារ ) ត្រូវរាយការណ៏ទៅសង្គមកិច្ចស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ឬអ្នកមានសមត្ថកិច្ចដទៃទៀតដើម្បីសុំការធ្វើអន្តរាគមន៍ ។
- បើមានលទ្ធភាពត្រូវនាំកុមារចេញពីផ្ទះបណ្ដោះអាសន្ន ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ (ករណីនេះឪពុកម្ដាយ ឬអាណាព្យាបាលអាចនឹងត្រូវបាត់បង់អំណាចមេបាទៅលើកុមារ ) ។

- ចំណុចដែលសំខាន់បំផុតគឺ សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ ។ បើកុមារអាចស្នាក់នៅបណ្ដោះអាសន្នជាមួយញាតិសន្ដាន ឬអ្នកជិតខាងនៅក្នុងសហគមន៍នេះគឺ ជាដំណោះស្រាយយ៉ាងល្អបំផុត ។
- តែបើសិនកុមារស្នាក់នៅបណ្ដោះអាសន្នជាមួយសាច់ញាតិឬអ្នកជិតខាងក្នុងសហគមន៍ ហើយនៅតែរងការវាយដំ ដោយឪពុក ម្ដាយ ឬអាណាព្យាបាលទៀត ត្រូវបញ្ជូនកុមារទៅមណ្ឌល សង្គ្រោះ ឬអង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សនៅក្រៅសហគមន៍ ។
- ស្វែងរកមណ្ឌលដែលអាចផ្ដល់ជម្រកឱ្យស្ត្រីដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងកូនរបស់គេអាចទៅស្នាក់នៅបណ្ដោះអាសន្នបាន ។
- ក្នុងរាល់ករណីខាងលើ កុមារ និងជនរងគ្រោះផ្សេងទៀត (អាចជាម្ដាយ ...) ដែលបានទទួលរងការវាយដំ ត្រូវការចាំបាច់នូវការគាំទ្រខាងផ្លូវចិត្ត ព្រោះគេអាចមានអារម្មណ៍ថា ការវាយដំទាំងនេះ មិនមែនជាកំហុសរបស់ជនមុខសញ្ញាឡើយ តែវាគឺជាកំហុសរបស់ខ្លួនពួកគេផ្ទាល់ ដូចជាកុមារអាចយល់ថាគេគឺជាក្មេងមិនល្អ ឯស្ត្រីអាចមានអារម្មណ៍ថា គាត់ជាប្រពន្ធមិនល្អ ជាដើម ។ ដូច្នេះ អ្នកជិតខាង មេភូមិ មេឃុំ ចៅសង្កាត់ និងអ្នកពាក់ព័ន្ធដទៃទៀតត្រូវផ្ដល់នូវការលើកទឹកចិត្តនិងគាំទ្រដល់កុមារ និងស្ត្រីទាំងនោះជាចាំបាច់ បើមិនដូច្នោះទេពួកគេនឹងទទួលរងនូវ ការវាយដំកាន់តែខ្លាំងថែមទៀត ។

# ៤. កុមារដែលត្រូវគេរំលោភផ្លូវភេទ

ការរំលោភផ្លូវភេទលើកុមារ គឺជាសកម្មភាពនៃការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស់ការប្រព្រឹត្តអំពើអាស្រូវភាស និងសកម្មភាពរំលោភផ្លូវភេទផ្សេងទៀតដើម្បីបន្ទាបបន្ថោកដល់កុមារ ទោះជាកុមារនោះព្រម ឬមិនព្រមក្តី ។

*ឯកសារភ្ជាប់ ៤.១*

## ៤.១. ផលប៉ះពាល់នៃការរំលោភផ្លូវភេទលើកុមារ

បន្ទាប់ពីទទួលរងនូវការរំលោភផ្លូវភេទ កុមារនឹង :

- ទទួលផលប៉ះពាល់ជាអវិជ្ជមានលើការអភិវឌ្ឍផ្នែកស្មារតី និងផ្នែកសង្គម
- ទទួលការឈឺចាប់ផ្នែករាងកាយ និងផ្លូវចិត្ត
- សុខភាពទ្រុឌទ្រោម បាត់បង់សមត្ថភាពពលកម្ម និងសមត្ថភាពបញ្ញា
- ឆ្លងជំងឺកាមរោគផ្សេងៗ ពិសេសជំងឺអេដស៍
- ក្លាយជាមនុស្សឆេវឆាវ ចូលចិត្តប្រើអំពើហិង្សា ហើយពិបាកសំរបខ្លួនជាមួយអ្នកដទៃ
- មានការភ័យខ្លាចនៅពេល នៅតែម្នាក់ឯង
- គ្មានជំនឿលើខ្លួនឯង
- ទទួលការរើសអើងក្នុងសង្គម
- អស់សង្ឃឹមក្នុងជីវិត
- មានផ្ទៃពោះ
- អាចក្លាយជាឪពុកម្តាយដែលមានចរិកឃោរឃៅ
- រត់ចេញពីផ្ទះ
- ធ្វើអត្តឃាត
- លែងជឿទុកចិត្តលើមនុស្សពេញវ័យ
- ... ។ល ។

## ៤.២ ល្បិចកលជនល្មើស

ដើម្បីអូសទាញ និងបោកបញ្ឆោតជនរងគ្រោះ ពិសេសកុមារ ជនល្មើសបានប្រើមធ្យោបាយមួយចំនួន ដូចជា :

- សន្យាផ្តល់ការងារធ្វើ ដោយអោយប្រាក់ខែខ្ពស់
- លួងលោម ទិញទឹកចិត្តកុមារ ឬគ្រួសារកុមារដោយអោយប្រាក់កាស គ្រឿងអលង្ការ ឬសង់ផ្ទះអោយជាដើម
- ប្រើល្បិចស្តីដណ្តឹងរៀបការ រួចយកទៅលក់នៅបរទេស
- សុំធ្វើជាកូនធម៌ ឬបងប្អូនធម៌
- អូសទាញអោយចូលរួមពិធីជប់លៀង ហូបចុកក្នុងរង្គសាល ឬផ្ទះសំណាក់
- បញ្ឆោតអោយដើរលេងជាមួយនៅកន្លែងស្ងាត់ កន្លែងងងឹត ឬកន្លែងបិទជិត ហើយចាប់រំលោភ
- ប្រើថ្នាំសណ្តំ
- សុំធ្វើជាសង្សារ ឬគូរកំណាន់ចិត្ត
- ... ។ល។

រាល់ការប្រើប្រាស់ល្បិចកលទាក់ទាញទឹកចិត្តមនុស្សម្នាក់ ឬច្រើននាក់ក្នុងគោលបំណងដើម្បីជួញដូរ លក់ ឬអោយធ្វើពេស្យាចារ ដោយមិនគិតថាអ្នកនោះយល់ព្រម ឬមិនយល់ព្រមនោះទេ ត្រូវផ្តន្ទាទោស ហើយត្រូវដាក់ទម្ងន់ទោសបន្ថែម បើជនរងគ្រោះជាកុមារក្រោមអាយុ១៥ឆ្នាំ ( មាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើ ពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មមនុស្ស ) ។

*ឯកសារភ្ជាប់ ៤.៣*

## ៤.៣ ការអន្តរាគមន៍ករណីរំលោភផ្លូវភេទលើកុមារ

ក្នុងករណីមានការរំលោភផ្លូវភេទលើកុមារកើតមានឡើង ឪពុកម្តាយ សាច់ញាតិ ឬអ្នកដទៃទៀតគួរតែផ្តល់ព័ត៌មានទៅមេភូមិ មេឃុំ ចៅសង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ នគរបាល មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ និងអ្នកមានសមត្ថកិច្ចផ្សេងទៀតអោយបានឆាប់រហ័ស ដើម្បីសុំអន្តរាគមន៍ ។

មេឃុំ ចៅសង្កាត់ មេភូមិ ឪពុកម្តាយ សាច់ញាតិ និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ត្រូវចាត់វិធានការនានា ដើម្បីធានាសុវត្ថិភាពដល់កុមារ ដូចជា :

- ចេញឯកសារស្របច្បាប់បណ្តោះអាសន្ន ស្តីពីការចាត់ចែងទៅលើការថែទាំកុមារ
- បញ្ជូនកុមារទៅមជ្ឈមណ្ឌលផ្តល់ទីជំរក និងការថែទាំ ( បើចាំបាច់ )

- នាំកុមារទៅទទួលការផ្តល់ប្រឹក្សាយោបល់ និងការថែទាំពីអ្នកដែលមានជំនាញ ជាពិសេសពីមន្ត្រីសង្គមស្រុក ខណ្ឌ ឬពីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដូចជាអង្គការលីការដូ អាដហុក អង្គការចិត្តសង្គមអន្តរវប្បធម៌ ( ធីភីអូ ) ឬមណ្ឌលនានាដែលផ្តល់សេវាទាំងនេះ

- បញ្ជូនកុមារទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាព ក្នុងរយៈពេល២៤ម៉ោង បន្ទាប់ពីពេលកើតហេតុដើម្បីរងភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌ

- ត្រូវរៀបចំដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ ជាជាងទទួលយកការសងជំងឺចិត្តពីជនល្មើសជាទឹកប្រាក់ ឬជាការរៀបចំចាត់ចែង រៀបអាពាហ៍ពិពាហ៍

- អប់រំប្រជាពលរដ្ឋក្នុងសហគមន៍អោយយល់ច្បាស់ថា កុមារជាជនរងគ្រោះដោយសារការរំលោភបំ ពាន ដូច្នេះយើងត្រូវជួយដល់កុមាររងគ្រោះទាំងនោះ ហើយមិនត្រូវរើសអើង ឬស្អប់ខ្ពើមពួកគេទេ ។ លើសពី នេះទៀតយើងត្រូវតែប្រឆាំងនូវវាលទង្វើនៃការរំលោភបំពានទាំងនេះ ។

- ... ។ល ។

# ៥. កុមារត្រូវគេកេងប្រវ័ញ្ចកម្លាំងពលកម្ម

*ឯកសារភ្ជាប់ ៥.១*

## ៥.១ ពលកម្មកុមារ

ពលកម្មកុមារ គឺជាការងារដែលតម្រូវអោយកុមារធ្វើការច្រើនម៉ោងក្នុងមួយថ្ងៃៗ សម្រាប់ប្រាក់កម្រៃដ៏តិចតួច ហើយជាទូទៅស្ថិតក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់ដល់ការរីកលូតលាស់នៃរាងកាយ និងខួរក្បាលរបស់ពួកគេ ឬបំបែកពួកគេចេញពីគ្រួសារ និងជាញឹកញាប់កាត់ផ្តាច់ពួកគេចេញពីការសិក្សា ។ ពលកម្មកុមារមិនបានរាប់បញ្ចូលកុមារដែលត្រូវធ្វើការ ពីរ បីម៉ោង ក្នុងមួយសប្តាហ៍ដើម្បីជួយគ្រួសាររបស់ពួកគេលើការងារមួយចំនួនដូចជា ការងារស្រែចម្ការ ការងារផ្ទះ ការងារតូចតាចក្នុងមុខជំនួញរបស់គ្រួសារ ...។ល។

នៅពេលដែលកុមារត្រូវបានគេកេងប្រវ័ញ្ចកម្លាំងពលកម្ម និងបង្ខំអោយធ្វើការប្រកបដោយគ្រោះថ្នាក់ នោះពួកគេនឹងរងគ្រោះថ្នាក់ដល់ការអភិវឌ្ឍផ្នែករាងកាយ ការសិក្សា ស្មារតី ចិត្តគំនិត និងផ្នែកសង្គម ។

ការងារដែលប្រកបដោយគ្រោះថ្នាក់ ត្រូវបានហាមឃាត់ដោយច្បាប់ចំពោះកុមារអាយុក្រោម១៨ឆ្នាំ ។ យោងមាត្រា១៧៥ និង១៧៧ នៃច្បាប់ស្តីពីការងារ (របស់កម្ពុជាឆ្នាំ១៩៩៧) ចែងថា : អាយុអប្បបរមាអាចចូលធ្វើការត្រូវបានកំណត់ត្រឹម១៥ឆ្នាំ ។ អាយុអប្បបរមាអាចចូលធ្វើការងារ ត្រូវកំណត់ត្រឹម១៨ឆ្នាំ ចំពោះ មុខរបរ ឬការងារគ្រប់ប្រភេទដែលអាចធ្វើឱ្យខូចសុភាព សន្តិសុខ ឬសីលធម៌របស់មនុស្សវ័យជំទង់ ដោយសារ តែល័ក្ខខ័ណ្ឌ ឬប្រភេទមុខរបរ និងការងារទាំងនោះបង្កឡើង ។ ការងារពេលយប់នៅក្នុងសហគ្រាស ត្រូវបាន ហាមឃាត់ចំពោះកុមារដែលមានអាយុតិចជាង១៨ឆ្នាំ ប៉ុន្តែអាចអនុញ្ញាតបានចំពោះករណីលើកលែង (ប្រកាស របស់ក្រសួងទទួលបន្ទុកវិស័យការងារ) ចំពោះកុមារដែលមានអាយុច្រើនជាង១៨ឆ្នាំ ។

ទោះបីជាអាយុស្របច្បាប់របស់កុមារ អាចធ្វើការក្នុងស្ថាប័នមិនមែនធ្ងន់ធ្ងរពី១៥-១៨ឆ្នាំក៏ដោយ ក៏ច្បាប់ការងារកម្ពុជាបានចែងថា កុមារទាំងនោះត្រូវទទួលការហ្វឹកហ្វឺនមុននឹងអនុញ្ញាតអោយចូលធ្វើការ ។ អង្គការពលកម្មអន្តរជាតិបានប៉ាន់ប្រមាណថា មានកុមារកម្ពុជាអាយុក្រោម១៨ឆ្នាំ ចំនួន២៥២,៤៥៥នាក់ ត្រូវគេជួលអោយធ្វើការងារក្រោមទម្រង់នៃពលកម្មកុមារដ៏ធ្ងន់ធ្ងរ ( របាយការណ៍របស់ក្រសួងផែនការ និងអង្គការពលកម្មអន្តរជាតិ ឆ្នាំ២០០១) ។

*ឯកសារភ្ជាប់ ៥.២*

## ៥.២. ការងារដែលមានការកេងប្រវ័ញ្ច និងមានគ្រោះថ្នាក់

ការងារដែលមានការកេងប្រវ័ញ្ច និងមានគ្រោះថ្នាក់សម្រាប់កុមារ គឺជាការងារដែលអាចគ្រោះថ្នាក់ដល់សុខភាព សុវត្ថភាព ឬសីលធម៌របស់មនុស្សវ័យក្មេង ។ ការងារដែលមានការកេងប្រវ័ញ្ច និងមានគ្រោះថ្នាក់ទាំងនោះមានដូចជា:

- កុមារធ្វើការនៅសណ្ឋាគារ និងភោជនីយដ្ឋាន និងអ្នកចំអិនអាហារ អ្នកបំរើតាមបន្ទប់ អ្នកលក់ស្រាបៀរ ។
- កុមារធ្វើការនៅពេលយប់ ( លើកលែងស្ថានភាពមួយចំនួន និងប្រសិនបើកុមារមានអាយុលើសពី ១៨ឆ្នាំ ) ។
- កុមារធ្វើការជាអ្នកបម្រើតាមផ្ទះ ឬជាអ្នកយាមទ្វារ ។
- កុមារវ័យក្មេងធ្វើការក្នុងសិប្បកម្មឡឥដ្ឋ រោងចក្រកាត់ដេរ សិប្បកម្មលោហៈធាតុ ឬនៅជុំវិញគ្រឿងចក្រដែលអាចមានគ្រោះថ្នាក់ រោងចក្រកែច្នៃត្រី ចម្ការកៅស៊ូ ស្រែអំបិល ។
- កុមារដែលធ្វើការនៅទីកន្លែងដែលគេអាចទទួលរងគ្រោះថ្នាក់ ដោយការកេងប្រវ័ញ្ចលើរាងកាយ ពាក្យសំដី ឬផ្លូវភេទ ឬទីកន្លែងដែលគេត្រូវដាក់បង្ហាញដើម្បីការសរសេររឿង រូបភាពអាសអាភាស ឱ្យធ្វើសកម្មភាពប្រឆាំងនិងច្បាប់ ឬការប្រព្រឹត្តអនាចារ ។
- ដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន (ដឹកធ្ងន់ៗ) ។
- កន្លែងគំនរសំរាម ។
- ...។ល។

*ឯកសារភ្ជាប់ ៥.៣*

## ៥.៣. ផលប៉ះពាល់ពីការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ

+ ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ផ្តល់ផលប៉ះពាល់ជាអវិជ្ជមានជាច្រើនដូចជា :

- កុមារលូតលាស់មិនបានល្អ (ក្រិន) ។
- កុមារមានស្នាកោង ។
- កុមារខ្សោយកម្លាំង និងពិការដៃជើង និងអវៈយវៈ ។
- កុមារកាន់តែទទួលរងគ្រោះដោយត្រូវគេជួញដូរ រំលោភបំពាន ឬកេងប្រវ័ញ្ច ។
- កុមារទទួលរងនូវភាពឯកកោ ដោយសារត្រូវគេចាកចេញពីសហគមន៍ ដើម្បីមកធ្វើការដែលនាំឱ្យមានការប៉ះពាល់ដល់ការអភិវឌ្ឍរាងកាយ ផ្លូវចិត្ត និងប្រាជ្ញាស្មារតី ។

- កុមារមិនបានទទួលការសិក្សាអប់រំ និងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីមើលថែឪពុកម្ដាយរបស់គេ ។
- អាចធ្វើឱ្យកុមារស្លាប់ ។
- សង្គមជាតិបាត់បង់ធនធានមនុស្សទៅថ្ងៃអនាគត ។
- ពលកម្មកុមារ ជាមូលហេតុធ្វើឱ្យមានភាពក្រីក្រ ។
- ...។ល។

*ឯកសារភ្ជាប់ ៥.៤*

## ៥.៤. ការអន្តរាគមន៍

### ក). ករណីកុមារធ្វើការងារតាមការបញ្ជារបស់ឪពុកម្ដាយ

- ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ មេភូមិត្រូវធ្វើការផ្សព្វផ្សាយ និងពន្យល់ដល់ឪពុកម្ដាយអំពីផលប៉ះពាល់ជាអវិជ្ជមាននៃការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ មេភូមិត្រូវរាយការណ៍ទៅមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ឬបញ្ជូនករណីទាំងនោះទៅមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវខេត្ត ក្រុង ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។ ឪពុកម្ដាយអាចបាត់បង់សិទ្ធិទៅលើកូន ហើយត្រូវផ្ដន្ទាទោសតាមច្បាប់ ។
- មេឃុំ ចៅស្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធផ្សេងទៀតអាចទៅសួរសុខទុក្ខកុមារផ្ដល់កម្លាំងចិត្ត និងផ្ដល់នូវការថែទាំសមស្រប ។

### ខ). ករណីកុមាររត់ចេញពីផ្ទះដោយត្រូវគេល្បួងលោមបោកប្រាស់

- ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ មេភូមិត្រូវធ្វើការផ្សព្វផ្សាយ និងពន្យល់ដល់ប្រជាពលរដ្ឋក្នុងភូមិអំពីផលប៉ះពាល់ជាអវិជ្ជមាន នៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម កុមារ ។
- ឪពុកម្ដាយ សាច់ញាតិ អ្នកជិតខាង និងអ្នកផ្សេងទៀតដែលបានដឹងត្រូវផ្ដល់ព័ត៌មានទៅមេឃុំ ចៅសង្កាត់ មេភូ នគរបាលប៉ុស្តិ៍ឃុំ សង្កាត់ មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតដើម្បីសុំអន្តរាគមន៍ ។
- មេឃុំ ចៅសង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធផ្សេងទៀតអាចទៅសួរសុខទុក្ខកុមារ ផ្ដល់កម្លាំចិត្ត និងផ្ដល់នូវការថែទាំសមស្រប ។
- បើឪពុកម្ដាយក្រីក្រខ្លាំងពេក ពុំអាចទទួលកូនឱ្យត្រឡប់មករស់នៅក្នុងគ្រួសារវិញ ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងអាជ្ញាធរមានសម្ថតកិច្ចផ្សេងទៀតត្រូវទំនាក់ទំនងជា មួយស្ថាប័នដែលអាចផ្ដល់ជំនួយបានដូចជា អង្គការមិនមែនរដ្ឋាភិបាល ឬសប្បុរសជននានា ដើម្បីការពារកុមារពីការធ្វើពលកម្មប្រកបដោយគ្រោះថ្នាក់ និងអាចធ្វើឱ្យពួកគេទៅសាលារៀនបាន ។

# ៦. កុមារចាកចេញពីសហគមន៍ ដោយគ្មានឪពុកម្ដាយនៅជាមួយ

កុមារដែលចាកចេញពីសហគមន៍ដោយគ្មានឪពុកម្ដាយទៅជាមួយ គឺជាការនាំកុមារចេញពីលំនៅដ្ឋានដែលគេធ្លាប់រស់នៅជាប្រក្រតី ទៅកាន់កន្លែងដទៃទៀតនៅក្នុងប្រទេស ឬក្រៅប្រទេស ដើម្បីគោលបំណងណាមួយដោយមិនមានឪពុកម្ដាយទៅជាមួយ ។

*ឯកសារភ្ជាប់ ៦.១*

## ៦.១. មូលហេតុដែលនាំឱ្យកុមារចាកចេញពីសហគមន៍

មូលហេតុដែលនាំឱ្យកុមារចាកចេញពីសគមន៍មានដូចជា :

- ❖ ស្វែងរកការងារនៅតាមទីរួមខេត្ត ក្រុង តាមទីប្រជុំជន និងក្រៅប្រទេស
- ❖ ជីវភាពក្រីក្រ
- ❖ អូសទាញពីអ្នកបោកបញ្ឆោត ( មេខ្យល់)
- ❖ ចាកចេញដោយខ្លួនឯង
- ❖ ទទួលរងការធ្វើបាបដោយសារអំពើហិង្សាក្នុងគ្រួសារ
- ❖ ទទួលព័ត៌មានពីការជ្រើសរើសបុគ្គលិក ឬកម្មករ
- ❖ ...។ល។

*ឯកសារភ្ជាប់ ៦.២*

## ៦.២. ភាពគ្រោះថ្នាក់

កុមារដែលចាកចេញពីសហគមន៍ដោយមិនមានឪពុកម្ដាយទៅជាមួយ អាចជួបប្រទះបញ្ហាមួយចំនួន ដូចជា:

- ❖ កុមារត្រូវបែកពីគ្រួសារ ពីបណ្ដាញសហគមន៍ និងពីយន្តការការពារទូទៅ ។
- ❖ កុមារងាយចាញ់បោកគេ ឬប្រព្រឹត្តសកម្មភាពដែលផ្ទុយនិងច្បាប់ ។
- ❖ ក្នុងករណីចាកចេញទៅក្រៅប្រទេស ជាញឹកញាប់កុមារពុំចេះនិយាយភាសាបរទេស និងត្រូវបានបដិសេធនូវសិទ្ធិស្របច្បាប់ ។ មិនថាទៅធ្វើការនៅទីកន្លែងផ្សេង ឬក៏អ្នកដែលរត់ចេញ

ពីផ្ទះឡើយ គឺសុទ្ធតែជាកុមារដែលងាយរងគ្រោះធ្ងន់ធ្ងរ ដោយសារការរំលោភបំពាន និងការកេងប្រវ័ញ្ចពីសំណាក់មនុស្សពេញវ័យ ។

*ឯកសារភ្ជាប់ ៦.១*

## ៦.៣. ដំណោះស្រាយ

### ក). ករណីកុមាររត់ចេញពីផ្ទះ

- ❖ ឪពុកម្តាយ និងញាតិសន្តានត្រូវជូនដំណឹងទៅអាជ្ញាធរមូលដ្ឋាន
- ❖ អាជ្ញាធរមូលដ្ឋាន អាចទាក់ទងទៅមន្ត្រីសង្គមកិច្ច នគរបាល អង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីស្វែងរកកុមារ
- ❖ បើរកកុមារឃើញ ហើយអាចនាំកុមារត្រឡប់មកផ្ទះវិញបាន មន្ត្រីសង្គមកិច្ច និងអ្នកពាក់ព័ន្ធ ត្រូវធ្វើការជាមួយគ្រួសារកុមារ ដើម្បីជួយស្វែងរកដំណោះស្រាយ ចំពោះបញ្ហាដែលធ្វើឱ្យកុមាររត់ចេញពីផ្ទះ ។
- ❖ បើកុមាររត់ចេញពីផ្ទះដោយសារការវាយដំ ឬការរំលោភបំពាននានានៅក្នុងផ្ទះ សូមមើលដំណោះស្រាយករណីកុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា ។ ជាការសំខាន់ណាស់ដែល ត្រូវធានាថាកុមារនិងមិនរត់ចេញពីផ្ទះជាថ្មីម្តងទៀតទេ ។
- ❖ ញាតិសន្តាន និងសមាជិកដទៃទៀតនៅក្នុងសហគមន៍ត្រូវជួយផ្តល់យោបល់ និងលើកទឹកចិត្តដល់កុមារ ។
- ❖ អ្នកទាំងអស់គ្នាត្រូវធ្វើការងារជាមួយឪពុកម្តាយ ដើម្បីលើកកំពស់ការធ្វើសមាហរណកម្ម កុមារ ។

### ខ). ករណីកុមារចាកចេញពីសហគមន៍ដើម្បីទៅរកការងារធ្វើ

- ❖ ឪពុកម្តាយត្រូវដឹងពីទីកន្លែងដែលកុមារត្រូវទៅ និងវិធីដែលអាចឱ្យពួកគេទាក់ទងកុមារគ្រប់ពេលវេលា ។
- ❖ បើមានលទ្ធភាព កុមារអាចរស់នៅជាមួយញាតិសន្តាន ឬមិត្តភក្តិដែលអាចទុកចិត្តបានរបស់ក្រុមគ្រួសារនៅកន្លែងថ្មី ដែលពួកគេត្រូវទៅនោះ ។ ឪពុកម្តាយត្រូវទៅពិនិត្យទីកន្លែងដែលកុមារត្រូវទៅរស់នៅ ដើម្បីធានាថា ទីនោះគឺជាកន្លែង មានសុវត្ថិភាព សម្រាប់កុមាររស់នៅ ។
- ❖ ដើម្បីកុំឱ្យកុមារចាកចេញពីសហគមន៍ទៅរកការងារធ្វើ មេភូមិ ចៅសង្កាត់ មន្ត្រីសង្គមកិច្ច សហគមន៍ និងអ្នករួមសម្តតកិច្ចដទៃទៀតត្រូវៈ
  - + បង្កើតការងារសមស្របសម្រាប់កុមារវ័យជំទង់នៅក្នុងសហគមន៍
  - + ជួយបង្កើនជីវភាពដល់ឪពុកម្តាយរបស់កុមារទាំងនោះ
  - + ... ។ល ។

### គ). ករណីកុមារត្រូវគេលួងលោមបោកប្រាស់

- ឪពុកម្តាយត្រូវទាក់ទងជាមួយមេភូមិ និងមេឃុំ ចៅសង្កាត់ ដែលជាអ្នកអាចតាមជួយរកទីកន្លែងរបស់កុមារ និងរំដោះកុមារបានដោយមានជំនួយពីនគរបាល និងការិយាល័យសង្គមកិច្ចស្រុក ខណ្ឌ ។
- ឪពុកម្តាយត្រូវតែដឹងជានិច្ចពីទីកន្លែងដែលកុមាររស់នៅ និងមានវិធីអាចទាក់ទងពួកគេបានគ្រប់ពេល ។
- អាជ្ញាធរមូលដ្ឋានត្រូវទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬអ្នកផ្តល់សេវាផ្សេងទៀត ដើម្បីធ្វើការផ្សព្វផ្សាយ និងផ្តល់នូវការយល់ដឹងអំពីការចាកចេញប្រកបដោយសុវត្ថិភាព ភាពគ្រោះថ្នាក់ និងល្បិចបោកបញ្ឆោតរបស់ជនល្មើស ។

ទោះបីជាកុមារត្រូវផ្លាស់ប្តូរទីកន្លែងទៅរស់នៅកន្លែងផ្សេងជាមួយញាតិសន្តាន ឬក្រុមគ្រួសាររបស់មិត្ត ភក្តិ ឬទៅនៅតាមវត្តអារាម ដែលអាចឱ្យពួកគេបន្តការសិក្សាក៏ដោយ ក៏ឪពុកម្តាយ ឬអ្នកថែទាំបឋមត្រូវនាំ កុមារទៅទីកន្លែងទាំងនោះ ដើម្បីធានាថា ទីនោះជាកន្លែងមានសុវត្ថិភាពសម្រាប់កុមាររស់នៅ និងមាន មធ្យោបាយអាចទាក់ទងជាមួយកុមារបានគ្រប់ពេលបើមានការចាំបាច់ ។ កុមារត្រូវតែបានទទួលចំណេះដឹងអំពី វិធីទាក់ទងជាមួយគ្រួសារ ឬមេភូមិ ។ កុមារម្នាក់ៗត្រូវតែដឹងពីសិទ្ធិជាមូលដ្ឋានរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹង ពីភាពគ្រោះថ្នាក់នៃរស់អ្នកជួញដូរកុមារ និងពីល្បិចកលរបស់ឈ្មួញទាំងនោះ ។

# ៧. កុមារពិការ

☞ កុមារពិការ គឺជាកុមារមិនឯករាជ្យ (គ្មានម្ចាស់ការលើខ្លួនឯង) ឬមិនអាចផ្សារភ្ជាប់ខ្លួនឯងបានពេញលេញទៅក្នុងសហគមន៍ ដោយសារតែពិការភាព ។

☞ ពិការភាព គឺជាការខ្វះខាត ឬការគ្មានលទ្ធភាពក្នុងការធ្វើសកម្មភាពដូចមនុស្សធម្មតា ឬក្នុងកំរិតដែលមនុស្សធម្មតាអាចធ្វើបាន ។ ពិការភាពអាចប៉ះពាល់ទៅលើរាងកាយ ខួរក្បាល លទ្ធភាពក្នុងការរៀនសូត្រ ការនិយាយស្តី ឬអាកប្បកិរិយា ...។ល។ (អង្គការសុខភាពពិភពលោក) ។

*ឯកសារភ្ជាប់ ៦.១*

## ៧.១ ប្រភេទ និងលក្ខណៈពិការភាពរបស់កុមារ

យើងអាចសម្គាល់ប្រភេទ និងលក្ខណៈពិការភាពរបស់កុមារបានដូចខាងក្រោម :

| ប្រភេទ | និយមន័យ | លក្ខណៈពិការភាព |
|---|---|---|
| ពិបាកក្នុងការមើល | អ្នកទាំងឡាយណាដែលមានលទ្ធភាពមើលឃើញតិចតួច លទ្ធភាពសម្លឹងមើលចុះខ្សោយ ឬមិនអាចមើលឃើញវត្ថុអ្វីមួយ ។ | ឧទាហរណ៍ : ងងឹតភ្នែកម្ខាង ឬទាំងសងខាង ស្វិតឬរលាកសសៃបាតភ្នែក ភ្នែកល្មៀនមើលមិនឃើញ កន្ទុយថ្លែន ត្រាក់កូមស្រលៀងភ្នែក ភ្នែកមីញ៉ូប ធ្លាក់ត្របកភ្នែក សម្លាកកញ្ចក់ភ្នែក ជំងឺប្រែងចាក់ភ្នែក សម្ពាធទឹកក្នុងភ្នែក ងងឹតពួងរោមភ្នែករមូលចូលក្នុងភ្នែក ។ |
| ពិបាកក្នុងការស្តាប់ | អ្នកទាំងឡាយណាដែលមានលទ្ធភាពស្តាប់ចុះខ្សោយ (ពីកំណើត ដោយសាររបួស ឬមេរោគ ឬវ័យចាស់) | ឧទាហរណ៍ : មនុស្សថ្លង់ ត្រចៀកអត់រន្ធ ពុំមានក្រដាសត្រចៀក ធ្លាយក្រដាសត្រចៀក ហៀរអំបៅអំបែក ។ |
| ពិបាកក្នុងការនិយាយ | អ្នកទាំងឡាយណាដែលពិបាកក្នុងការនិយាយ និយាយមិនច្បាស់ ឬនិយាយមិនរួចទាល់តែសោះ ឬអ្នកដទៃពិបាកស្តាប់ ។ | ឧទាហរណ៍ : អ្នកនិយាយដំឡាន់ ត្រដិត ឆែបបបូរមាត់ ឆែបក្រអូមមាត់ កួរ អណ្តាតធំ និយាយមិនច្បាស់ អ្នកមានបញ្ហាធ្មេញ ។ |

| | | |
|---|---|---|
| ពិបាកក្នុងការធ្វើចលនា | អ្នកទាំងឡាយណាដែលមានលទ្ធភាពធ្វើចលនា ( ដោយរាងកាយ ) ផ្លាស់ទីដោយលំបាក ឬកម្រើកផ្នែកណាមួយនៃរាងកាយរបស់ខ្លួនដោយលំបាក ឬមិនអាចកម្រើកទាល់តែសោះ ។ | ឧទាហរណ៍ : ពិការដៃ ពិការជើង ស្វិតដៃជើង ស្វិតសាច់ដុំ គាំងសរសៃ បាក់ឆ្អឹង សាច់ដុំតឹងខ្លាំង ខូចគ្រឿងបញ្ជាចលនា(ខ្សោយ) ជើងខ្វេ ជើងកែក ទន់ត្រឹមកដៃ ជើងទន់ ខូចទ្រង់ទ្រាយពីកំណើត ស្លាប់មួយចំហៀង/កំណាត់ខ្លួន/ស្លាប់អវៈយវៈ ស្លាប់សរសៃ ឆ្អឹងខ្នងវៀច រលាកសន្លាក់ហើម រលាកឆ្អឹងសន្លាក់ របេងឆ្អឹង គមខ្នង(កោងទៅមុខ កោងទៅចំហៀង និងកោងទៅក្រោយ )ខ្ទួស្មាម្ខាង ភ្លាត់ត្រគាក របួសខួរឆ្អឹងខ្នង គ្រិច រលាកភ្លើង ឬទឹកអាស៊ីដ ជំងឺឆ្អឹងទន់ |
| ពិបាកខាងកាយវិញ្ញាណ | អ្នកទាំងឡាយណាដែលបាត់បង់ការដឹង ដោយកាយវិញ្ញាណ ឬអត់ដឹងនៅពេលកាន់ ឬស្ទាបវត្ថុអ្វីមួយ ។ | ឧទាហរណ៍ : អ្នកពិការដោយសារឃ្លង់ ( កម្រិតធ្ងន់ ) អ្នកស្ពឹកដៃជើង កង្វះជីវជាតិ ( ហើម ) ។ |
| ពិបាកខាងផ្លូវចិត្ត | អ្នកទាំងឡាយណាដែលមានវិបត្តិផ្លូវចិត្ត មានអាកប្បកិរិយា ខុសពីមនុស្សធម្មតា | ឧទាហរណ៍ : អ្នកដែលដើរគ្មានសម្លៀកបំពាក់ អ្នកដែលនិយាយ/សើច/ច្រៀងរាំ/លេងតែម្នាក់ឯងខុសពីប្រក្រតី ស្ងឹងស្មាធ ដេរគេដេរឯង វាយ ឬប្រព្រឹត្តិអំពើហិង្សាដោយមិនដឹងខ្លួន មិនដឹងគ្រោះថ្នាក់ វិកលចរិក ឆ្កួតសតិអារម្មណ៍ តាមតឹងផ្លូវចិត្ត ធ្លាក់ទឹកចិត្ត ថប់អារម្មណ៍ ។ |
| ពិបាកក្នុងការរៀនសូត្រ | អ្នកទាំងឡាយណាដែលមានលទ្ធភាពចងចាំខ្សោយ ភ្លេចច្រើន ឬមិនអាចធ្វើអ្វីមួយដូចអ្នកដទៃទៀតដែលមានអាយុដំណាលគ្នាធ្វើបាន ។ | ឧទាហរណ៍ : អ្នកដែលមានបញ្ហាលូតលាស់យឺត ដោនស៊ីនដ្រូម អ្នករៀនខ្សោយ ការចងចាំនៅមានកម្រិត ខូចប្រព័ន្ធបញ្ជាក្នុងខួរក្បាល ក្មេងដែលមានចរិតទុយមុយ ។ |
| អ្នកដែលឧស្សាហ៍ប្រកាច់ | អ្នកទាំងឡាយណាដែលមានការប្រកាច់ជាញឹកញាប់ព្រមទាំងបែកពពុះមាត់ ដោយមូលហេតុអ្វីមួយ ។ | ឧទាហរណ៍ : អ្នកដែលមានជំងឺឆ្កួតជ្រូក ក្តៅប្រកាច់ ប្រកាច់ដោយសារលើសជាតិស្ករ ឬខ្វះជាតិស្ករនៅក្នុងឈាម ។ |
| ពិការផ្សេងៗ | អ្នកទាំងឡាយណាដែលមានការលំបាកក្នុងការបំពេញតួនាទីផ្នែករាងកាយ ឬតួនាទីក្នុងសង្គម ឬពិការដែលមិន | ឧទាហរណ៍ : អ្នកដែលមានមុខមាត់ ខូចទ្រង់ទ្រាយ/អាក្រក់ អ្នកដែលមានជំងឺរុំារ៉ៃ មនុស្សតឿ/ក្រិនផ្នែកលើស្បែក ( កម្រិតខ្លាំង ) អ្នកមានមេរោគអេដស៍ ក្មេងមានក្បាលធំ ។ |

| | | |
|---|---|---|
| | អាចចាត់ចូលទៅក្នុងប្រភេទពិការណាមួយខាងលើ ។ | |

*ឯកសារភ្ជាប់ ៦.១*

## ៧.២ ការឆ្លើយតបចំពោះកុមារពិការ

កុមារពិការតែងតែទទួលរងគ្រោះមួយចំនួនដូចជា :

- ពួកគេមិនអាចដើរ រត់លេងកំសាន្ត ឬថែទាំរាងកាយរបស់ខ្លួនបានដូចកុមារដទៃទៀតដែលមិនពិការ ។
- ពួកគេមិនអាចទំនាក់ទំនងជាមួយមនុស្សដទៃបានដោយស្រួល
- ពិបាកក្នុងការយកទៅសាលារៀន ឬមិនអាចរៀនសូត្របាន
- អាកប្បកិរិយារបស់ពួកគេស្តែងឡើងខុសប្លែកពីគេ និងមិនអាចអោយមនុស្សដទៃទៀតយល់បាន ។
- ជាញឹកញាប់ណាស់ កុមារពិការតែងតែត្រូវគេរើសអើង ហើយឳពុកម្តាយរបស់កុមារទាំងនោះអាចនឹងមានគំនិតថា វាគឺជាការអាម៉ាស់ដោយសារកូនពិការ ហើយព្យាយាមលាក់បាំងកូនរបស់ខ្លួនពីមនុស្សទាំងឡាយនៅក្នុងសហគមន៏...។ល។

នេះគឺជាចំណុចសំខាន់ណាស់ដែលត្រូវចងចាំថា កុមារពិការក៏ជាកុមារដែរ ។ ពួកគេត្រូវការសេចក្តីស្រលាញ់ ការយកចិត្តទុកដាក់ ការថែទាំ ការយល់ចិត្ត ជាងកុមារធម្មតា ។ ក្រុមគ្រួសាររបស់កុមារទាំងនេះមិនត្រូវមានការអាម៉ាស់ដោយសារកូនរបស់ខ្លួនពិការឡើយ ហើយមនុស្សទាំងឡាយ នៅក្នុងសហគមន៏ត្រូវតែយល់ឱ្យច្បាស់អំពីបញ្ហានេះ ហើយមិនត្រូវរើសអើងចំពោះកុមារពិការឡើយ ។ មានអង្គការមិនមែនរដ្ឋាភិបាលជាច្រើនដែលអាចជួយដល់កុមារពិការ ។ ជាការសំខាន់មួយដែលកុមារពិការត្រូវទទួលបានសេវាសុខភាពយ៉ាងឆាប់រហ័សក្នុងជីវិតរបស់គេ ដោយហេតុថា ពិការភាពមួយចំនួនអាចព្យាបាលអោយជាសះស្បើយឡើងវិញ ដោយការវះកាត់ ការព្យាបាល ឬដោយវិធីផ្សេងៗទៀត ។

# ៨. កុមារទំនាស់នឹងច្បាប់

កុមារទំនាស់នឹងច្បាប់ គឺកុមារអាយុក្រោម១៨ឆ្នាំ ដែលត្រូវបានសង្ស័យ ចោទប្រកាន់ ឬទទួលស្គាល់ថា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ កុមារបែបនេះត្រូវទទួលបាន នូវការប្រព្រឹត្តពិសេស មិនដូចនឹងជនល្មើសដែលជាមនុស្សពេញវ័យឡើយ ។

## ៨.១ ការប្រព្រឹត្តរបស់នគរបាលទៅលើកុមារ

- នគរបាលគប្បីប្រព្រឹតទៅលើកុមារជាជនល្មើសដោយសេចក្តីថ្លៃថ្នូរ ។

- កុមារដែលប្រព្រឹត្តបទល្មើសមិនត្រូវទទួលរងការវាយដំ មិនត្រូវគេសម្រាតសម្លៀកបំពាក់ ឬជេរប្រមាថឡើយ ។

- នគរបាលអាចធ្វើការទំនាក់ទំនងជាមួយកុមារដែលជាជនល្មើសតាមរយៈការជជែកពិភាក្សាគ្នា ពោលគឺមិនមែនតាមការប្រើអំពើហិង្សានោះទេ ។

## ៨.២ ការជំនុំជម្រះក្តី និងការឃុំខ្លួន

### ក). មុនពេលជំនុំជម្រះក្តី

- ត្រូវដាក់កុមារនៅក្រៅពន្ធនាគារ ឬកន្លែងដែលមានសុវត្ថិភាពទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

- កុមារដែលមានអាយុក្រោម១៣ឆ្នាំ មិនត្រូវស្ថិតក្នុងការឃុំឃាំងបណ្តោះអាសន្នឡើយ ( មាត្រា១៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ) ។

- ដាក់កុមារក្នុងពន្ធនាគារ គឺជាជម្រើសចុងក្រោយបំផុត និងក្នុងរយៈពេលមួយជាអប្បបរមាតាមដែលអាចធ្វើបាន ។

- កុមារត្រូវទទួលខុសត្រូវចំពោះអំពើខុសឆ្គងរបស់ខ្លួន តាមមធ្យោបាយមួយដែលគោរពដល់សេចក្តីថ្លៃ ថ្នូរ និងការលើកទឹកចិត្តអោយកុមារកែប្រែអាកប្បកិរិយា ( ឧទាហរណ៍ : សុំទោសជនរងគ្រោះ ទទួលការអប់រំ និងចូលរួមក្នុងសកម្មភាពសាធារណៈណាមួយ ) ។

- អនុញ្ញាតអោយកុមារបានស្នាក់នៅជាមួយឪពុកម្តាយ និងទៅសាលារៀន ។

**ខ). ក្នុងអំឡុងពេលជំនុំជម្រះរឿងក្តី**

- ក្នុងអំឡុងពេលនៃការរងចាំការជំនុំជម្រះរឿងក្តី ជាការចាំបាច់បើអាចធ្វើបាន កុមារត្រូវរស់នៅជាមួយក្រុមគ្រួសារ ឬសហគមន៍ គឺមិនមែននៅក្នុងពន្ធនាគារឡើយ ។

- កុមារដែលជាប់ចោទមានសិទ្ធិទទួលបាន ជំនួយពីមេធាវី និងមានវត្តមានឪពុកម្តាយ ឬអាណាព្យាបាលរបស់គេនៅគ្រប់ដំណាក់កាលនៃដំណើរការរឿងក្តី ។

- អ្នកធ្វើការខាងសង្គមកិច្ចត្រូវចូលរួមផ្តល់ព័ត៌មានអំពីកុមារ និងផ្តល់ការគាំទ្រផ្នែកសតិអារម្មណ៍ ។

**គ). ល័ក្ខខ័ណ្ឌនៃការឃុំខ្លួនកុមារដែលជាជនល្មើស**

- មានតែនៅក្នុងករណីដែលធ្ងន់ធ្ងរប៉ុណ្ណោះ ដែលកុមារអាចនឹងត្រូវឃុំខ្លួន ដើម្បីសុវត្ថិភាពជនរងគ្រោះ ឬសហគមន៍ ។

- នៅក្នុងពន្ធនាគារ ត្រូវដាក់កុមារអោយនៅដាច់ដោយឡែកពីជនល្មើសដែលជាមនុស្សពេញវ័យ ។

- ត្រូវមានកន្លែងសមល្មម និងមានខ្យល់អាកាសល្អ មានអាហាររូបត្ថម្ភគ្រប់គ្រាន់ មានទឹកស្អាត និងសម្លៀកបំពាក់ដែលមានអនាម័យ ។

- ទទួលបានការហាត់ប្រាណ និងការចេញទៅលំហែកាយក្រៅបន្ទប់ យ៉ាងតិច ១ម៉ោង ក្នុង១ថ្ងៃ ។

- មានសិទ្ធិជួបជាមួយញាតិសន្តាន ដែលមកសួរសុខទុក្ខយ៉ាងតិច ១ម៉ោង ក្នុង១សប្តាហ៍ ។

- មានសិទ្ធិបន្តការសិក្សា ឬចូលរួមវគ្គបណ្តុះបណ្តាលនានា ។

- មានសិទ្ធិទទួលបានការព្យាបាល ។

## ៨.៣ ចំណុចគួរចងចាំ

☞ កុមារគ្រប់រូបអាយុក្រោម១៨ឆ្នាំ ដែលប្រព្រឹត្តអំពើទំនាស់នឹងច្បាប់ ត្រូវទទួលនូវការប្រព្រឹត្តជាពិសេសមកលើខ្លួន ពោលគឺមិនត្រូវបានគេប្រព្រឹត្តមកលើខ្លួន ដូចជនល្មើសដែលជាមនុស្សពេញវ័យឡើយ ទោះជាបទល្មើសនោះធ្ងន់ធ្ងរបែបណាក៏ដោយ ។

☞ ចូលចងចាំថា កុមារប្រព្រឹត្តអំពើទំនាស់នឹងច្បាប់ អាចបណ្តាលមកពីមូលហេតុច្រើនយ៉ាង ដូចជាភាពក្រីក្រ ការមិនអើពើយកចិត្តទុកដាក់ ឬការរំលោភបំពានពីសំណាក់ឪពុកម្តាយអាណាព្យាបាល ឬជនណាមួយ កង្វះការអប់រំណែនាំ កង្វះសកម្មភាពដែលមានអត្ថប្រយោជន៍នៅក្នុងសង្គម រងការគាបសង្កត់ពីមិត្តភក្តិ ( ឧទាហ រណ៍ : ក្រុមបងធំ ) ការបង្ខិតបង្ខំពីមនុស្សពេញវ័យ ឬការសេពសារធាតុញៀនជាដើម ។

☞ លើកស្ទួយការគោរពសេចក្តីថ្លៃថ្នូរពីកំណើត ចំពោះកុមារទំនាស់នឹងច្បាប់ ។ ការពារកុមារពីការសងសឹក ឬអំពើហិង្សានៅក្នុងសហគមន៍ ។ កុមារអាចរៀនសូត្រពីជីវិតបានល្អ តាមរយៈការផ្តល់ហេតុផលមិនមែនតាមរយៈអំពើហិង្សានោះទេ ។

☞ ចូលចងចាំថា ការបង្ករបួសស្នាមទៅលើជនជាប់សង្ស័យ ទោះជាអ្នកនោះជាកុមារ ឬជាមនុស្សពេញវ័យក្តី គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។

☞ លើកទឹកចិត្តដល់គ្រួសារ ក្នុងការណែនាំកូនអោយមានអាកប្បកិរិយាល្អ ។ ផ្តល់ឱកាសឱ្យកុមារទទួលខុសត្រូវ ចំពោះអំពើខុសឆ្គងរបស់ខ្លួនតាមរយៈសកម្មភាព ដែលជួយស្តារការខូចខាតរបស់ជនរងគ្រោះ (ឧទាហរណ៍ : ការសុំទោស ការសង...) និងលើកទឹកចិត្តអោយកុមារកែប្រែអាកប្បកិរិយា ។

☞ ករណីកុមារត្រូវបាននគរបាលចាប់ខ្លួន ត្រូវជូនដំណឹងភ្លាមទៅឪពុកម្តាយរបស់កុមារ ឬសាច់ញាតិជិតបំផុត ឬអាណាព្យាបាលអំពីឧប្បត្តិហេតុ និងទីកន្លែងដែលកុមារកំពុងស្ថិតនៅ។ ឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ មានសិទ្ធិចូលរួមនៅក្នុងដំណើរការនៃការស៊ើបអង្កេត និងការជំនុំជម្រះរឿងក្តី ។

☞ បញ្ជូនករណីទៅរកសេវាសង្គមកិច្ច ( មន្ត្រីសង្គមកិច្ចថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ខេត្ត ក្រុង )។ កុមារមានសិទ្ធិទទួលនូវជំនួយឧបត្ថម្ភពីអ្នកធ្វើការងារសង្គមកិច្ចនៅក្នុងដំណាក់កាលស៊ើបអង្កេត និងជំនុំជម្រះ ។ ករណីចាំបាច់ត្រូវបញ្ជូនកុមារទៅអង្គការ ដែលអាចផ្តល់ជំនួយជាសេវានានា ( ឧទាហរណ៍ : ការថែទាំសុខភាព ការគាំទ្រផ្នែកអារម្មណ៍ និងការប្រឹក្សាយោបល់ជាដើម ) ។

☞ ឃ្លាំមើលពីរយៈពេលនៃការឃាត់ ឬឃុំខ្លួនកុមារ ។ ជូនដំណឹងទៅអ្នកធ្វើការសង្គមកិច្ច មេធាវី ឬអាជ្ញាធរ ឬអង្គការពាក់ព័ន្ធក្នុងករណីមានការឃាត់ ឬឃុំខ្លួនកុមារលើសរយៈពេលកំណត់ដោយច្បាប់ ។

☞ បញ្ជូនកុមារ និងឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារទៅរកមេធាវី ឬក្រុមផ្តល់ជំនួយផ្នែកច្បាប់នៅក្នុងសហគមន៍របស់អ្នក ។ កុមារជាជនជាប់ចោទ មានសិទ្ធិទទួលជំនួយពីមេធាវី នៅ្នុងដំណាក់កាលនៃការស៊ើបអង្កេត និងជំនុំជម្រះ ។

☞ ជួយកុមារទំនាស់នឹងច្បាប់ អោយបានចូលរៀនក្នុងប្រព័ន្ធសិក្សាផ្លូវការ ឬបើមិនអាចធ្វើបានទេអោយបានចូលរៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈក្រៅប្រព័ន្ធ ។ លើកស្ទួយការប្រឹក្សាយោបល់ តម្លៃនៃការអប់រំ និងការបណ្តុះបណ្តាលលើផ្នែកបំណិនជីវិត ដើម្បីបង្ការកុំអោយកុមារប្រព្រឹត្តបទល្មើសសាជាថ្មី ។

☞ លើទឹកចិត្តអោយស្រុះស្រួលគ្នារវាងកុមារដែលបានប្រព្រឹត្តល្មើស និងជនរងគ្រោះ ក៏ដូចជាក្រុមគ្រួសារនៃអ្នកទាំងនោះផងដែរ ដើម្បីធានាអោយមានការធ្វើសមាហរណកម្មកុមារទៅក្នុងសង្គម និងភាពសុខសាន្តនៅក្នុងសហគមន៍ ។

# គំរោងមេរៀនទី ១
## យេនឌ័រជាអ្វី?

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀន អ្នកចូលរួមទាំងអស់អាចៈ

- យល់ដឹងពីផ្នត់គំនិត និងឥរិយាបថ របស់គ្រួសារសហគមន៍ និងសង្គមចំពោះស្ត្រីនិងបុរសដែលបាន ផ្ដល់នូវផលប៉ះពាល់ជាអវិជ្ជនាមដល់ក្មេងស្រី ស្ត្រីនិងសងម ។
- យល់ដឹងពី និយមនយ័ និង ភាពខុសគ្នារវាងយេនឌ័រ និងភេទ

**រយៈពេល** : ៤៥ នាទី

**វិធីសាស្ត្រ** : បំផុសគំនិត បង្ហាញរូបភាព បិតកាតពិណ

**សំភារៈ** : ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសពណ៌ ផ្ទាំងរូបភាព

**-ឯកសារមេរៀនទី ១ យេនឌ័រជាអ្វី?**

របៀបសំរបសំរួល:

- អ្នកសំរបសំរួលបង្ហាញគោលបំណងនៃមេរៀនទី២ និងសុំអោយអ្នកចូលរួមអាន។ អ្នកសំរបសំរួស ពន្យល់ៗ លើគោលបំណង។

**១ .លក្ខណៈដូចគ្នា និងខុសគ្នា រវាងទារក និងទារិការ**

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា កូនស្រី និងកូនប្រុសដែលទើប និងកើត មានលក្ខណៈដូចគ្នា និងខុសគ្នាត្រង់ណាខ្លះ?
- អ្នកសំរបសំរួលកត់ត្រាចំលើយ លើក្រដាសផ្ទាំងធំ
- អ្នកសំរបសំរួល បកស្រាយ បង្ហាញបន្ថែម អំពីលក្ខណៈដូចគ្នា និងខុសគ្នារវាងកូនប្រុស និងកូនស្រី មួយចំណុចម្ដងៗ ដោយផ្អែកទៅលើឯកសារមេរៀនទី ១
- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថាតើមានចំងល់អ្វី? អ្នកសំរបសំរួលបកស្រាយនូវចំងល់ទាំងនោះ។

**២. ផ្នត់គំនិត និងការប្រព្រិត្តរបស់ គ្រួសារ និងសង្គម មកលើកូនប្រុស និងកូនស្រី :**

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថាដែលឮពាក្យថាយេនឌ័រដែរឬទេ? តើមាននយ័យ៉ាងដូចម្ដេច?
- អ្នកសំរបសំរួលកត់ត្រាចំលើយ លើក្រដាសផ្ទាំងធំ
- អ្នកសំរបសំរួល បំផុសអោយអ្នកចូលរួម បញ្ចេញយោបលពីការគិត ការប្រព្រិត្ត របស់គ្រួសារ និងសង្គម មកលើកូនប្រុស និងកូនស្រី បុរស និងស្ត្រី ចាប់តាំងពីពេលកើតរហូតដល់ពេញវ័យ ដោយផ្ដោតទៅលើការកំណត់ តួនាទី ឱកាសទទួលបានការអប់រំការចូលរួមក្នុងសង្គម និងសិទ្ធិអំណាច របស់ក្មេងប្រុស និងក្មេងស្រី បុរស និងស្ត្រី ហើយអ្នកសំរបសំរួលបញ្ជាក់បន្ថែមថា មានតែភេទទេដែលជាកំណត់ពីធម្មជាតិ ហើយមិនអាចកែប្រែបាន។

- អ្នកសំរបសំរួល បំផុសអោយអ្នកចូលរួម កំណត់ពីនិយមនយ័ យេនឌ័រ និងភេទ

- អ្នកសំរបសំរួល បង្ហាញពីភាពខុសប្លែកគ្នារវាងភេទ និងយេនឌ័រ ( ឯកសារមេរៀនទី១ ចំណុចទី២)

- អ្នកសំរបសំរួល សួរទៅអ្នកចូលរួមថា មានចំងល់អ្វីទេ? ហើយអ្នកសំរបសំរួលបកស្រាយចំងល់

### ៣ . ផលប៉ះពាល់ជាអវិជ្ជមាន ចំពោះកូនស្រី និងស្ត្រី នៅក្នុងគ្រួសារ សង្គម និងសហគមន៍

- អ្នកសំរបសំរួល សួរទៅអ្នកចូលរួមថា តើផ្នត់គំនិតខាងលើដែលបានដែលបានរៀបរាប់កន្លងមកបានផ្តល់តផលប៉ះពាល់ដូចម្តេចចំពោះកូនស្រី ស្ត្រី?

- អ្នកសំរបសំរួល កត់ត្រាចំលើយលើក្រដាសផ្ទាំងធំ

- អ្នកសំរបសំរួល បកស្រាយបន្ថែមពីផលប៉ះពាល់ជាអវិជ្ជមានចំពោះកូនស្រី ដោយផ្អែកទៅលើឯកសារមេរៀនទី១ ចំណុចទី៣

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើមានចំងល់អ្វីទេ? ហើយអ្នកសំរបសំរួលបកស្រាយចំងល់នោះ

### ៤. ការកែលំអរផ្នត់គំនិត និងការប្រព្រិត្តរបស់គ្រួសារ សង្គម និងសហគមន៍

- អ្នកសំរបសំរួលបញ្ជាក់បន្ថែមថា យេនឌ័រកើតចេញពីផ្នត់គំនិត និងការប្រព្រិត្តរបស់គ្រួសារ សង្គម សហគមន៏ មកលើកូនប្រុស និងកូនស្រី ហើយបានផ្តល់ផលប៉ះពាល់ជាអវិជ្ជមានមកលើកូនស្រី ។ ក៏ប៉ុន្តែបញ្ហាទាំងអស់នេះអាចផ្លាស់ប្តូរបាន

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើមានអ្នកណាខ្លះជាអ្នកកែលំអរផ្នត់គំនិតទាំងអស់នេះ ហើយត្រូវធ្វើដូចម្តេច?

- អ្នកសំរបសំរួលកត់ត្រាចំលើយ លើក្រដាសផ្ទាំងធំ

- អ្នកសំរបសំរួលបកស្រាយបន្ថែម លើចំលើយរបស់អ្នកចូលរួមអំពីការកែលំអរផ្នត់គំនិត ដោយផ្អែកទៅលើឯកសារមេរៀនទីចំណុច៤ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើមានចំងល់អ្វីទេ? ហើយអ្នកសំរប-សំរួលបកស្រាយ ចំងល់នោះ

### សង្ខេបមេរៀន

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា បានទទួលអ្វីខ្លះពីមេរៀននេះ

- អ្នកសំរបសំរួលសួរបំផុសទៅអ្នកចូលរួម សង្ខេបនូវចំណុចនិមួយៗនៃមេរៀន យេនឌ័រជាអ្វី?

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា ខ្លឹមសារមេរៀនដែលបានទទួល ឆ្លើយតបទៅនិងគោលបំណង ហើយឬនៅ?

## គំរោងមេរៀនទី ២
## តួនាទីយេនឌ័រ

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀន អ្នកចូលរួមទាំងអស់អាចៈ

- កំណត់បាន ពីទំនាក់ទំនងការងារប្រចាំថ្ងៃទាំងបីប្រភេទ របស់ ស្ត្រី-បុរស ការងារ មានកំរៃ ការងារគ្មានកំរៃ និងការងារសហគមន៍
- យល់ដឹង និងទទួលស្គាល់ ថា ស្ត្រី និងបុរសចូលរួមយ៉ាងសកម្មក្នុងការងារទាំងបីប្រភេទនេះ

**រយៈពេល** : ៣០នាទី

**វិធីសាស្ត្រ** : ពិភាក្សារជាគូ ពិភាក្សារក្រុមតូច

**សំភារៈ** : ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ។ល។

-ឯកសារមេរៀនទី២ តួនាទីយេនឌ័រ

របៀបសំរបសំរួលៈ

- អ្នកសំរបសំរួលបង្ហាញគោលបំណងនៃមេរៀនទី២ និងសំអោយអ្នកចូលរួមអាន។
- អ្នកសំរបសំរួលបកស្រាយត្រួស១ លើគោលបំណង

### ១ ការងារប្រចាំថ្ងៃរបស់ បុរស ស្ត្រី

+អ្នកសំរបសំរួលពន្យល់ ពាក្យតួនាទីយេនឌ័រ

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើបុរស-ស្ត្រី ធ្វើការងារធ្វីខ្លះជារៀងរាល់ថ្ងៃ?

+អ្នកសំរបសំរួល បំផុសអោយអ្នកចូលរួមបញ្ចេញយោបល់ពីការងារដែលបុរស និងស្ត្រីធ្វើជារៀងរាល់ថ្ងៃ?

+ អ្នកសំរបសំរួលកត់ត្រាចំលើយ លើក្រដាសផ្ទាំងធំ

+ អ្នកសំរបសំរួល បំផុសអោយអ្នកចូលរួម បែងចែកប្រភេទនៃការងារទាំងនោះមានបីប្រភេទៈ ការងារ មានកំរៃ ការងារគ្មានកំរៃ ការងារសហគមន៍។

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើអ្នកណាខ្លះជាអ្នកចូលរួមធ្វើទទួលខុសត្រូវលើការងារទាំងបី ប្រភេទនេះ?

+ អ្នកសំរបសំរួលកត់ត្រាចំលើយលើក្រដាសផ្ទាំងធំ

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើការងារណាមួយមានកំរៃជាងការងារណា ?

+ អ្នកសំរបសំរួលកត់ត្រាចំលើយ លើក្រដាសផ្ទាំងធំ

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមបន្តថា តើការងារណាមួយដែលស្ត្រីមិនអាចធ្វើបានហើយការងារណាមួយដែលបុរសមិនអាចធ្វើបាន?

+ អ្នកសំរបសំរួលកត់ត្រាចំលើយ លើក្រដាសផ្ទាំងធំ

+ អ្នកសំរបសំរួល បកស្រាយបង្ហាញបន្ថែមអំពីការងារបុរស-ស្ត្រីមានបីប្រភេទ និងការចូលរួមរបស់បុរស-ស្ត្រីលើការងារទាំងនោះដោយផ្អែកលើ ឯកសារមេរៀនទី២ ចំណុចទី១

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមបន្តថា តើមានចំងល់ឬទេ ? និងបកស្រាយចំងល់ ។

**២.សារៈសំខាន់នៃការងារទាំងបីប្រភេទ**

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា នៅក្នុងចំណោមការងារទាំងបីប្រភេទនេះ តើការងារណាមួយមានសារៈសំខាន់ជាងគេ?

+ អ្នកសំរបសំរួលកត់ត្រាចំលើយ លើក្រដាសផ្ទាំងធំ

+ អ្នកសំរបសំរួល បកស្រាយ បង្ហាញបន្ថែម ពីតំលៃ និងសារៈប្រយោជន៏នៃការងារទាំងបីប្រភេទ (ឯកសារ មេរៀនទី២ ចំណុច ទី២)

**សង្ខេបមេរៀន**

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា បានទទួលអ្វីខ្លះពីមេរៀននេះ

+ អ្នកសំរបសំរួលសុំអោយអ្នកចូលសង្ខេបមេរៀន ចំណុច១ម្នាក់ម្តងៗ

+ អ្នកសំរបសំរួលបញ្ជាក់ ថាតើខ្លឹមសារ ដែលបានទទួលឆ្លើយតប និងគោលបំណងដែរឬទេ?
បើមានចំងល់ សុំសួរ

+ អ្នកសំរបសំរួល បកស្រាយបំភ្លឺនូវចំងល់របស់អ្នកចូលរួម

# មេរៀនទី ៣
## គំរូវការយេនឌ័រ

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀន អ្នកចូលរួមទាំងអស់អាចៈ

-យល់ដឹងពីតំរូវការរបស់ស្ត្រីបុរសនៅក្នុងមូលដ្ឋាន

-យល់ដឹងពីតំរូវការជាយុទ្ធសាស្ត្ររបស់ស្ត្រីដើម្បីអោយមានតួនាទីនិងសិទ្ធិអំណាចក្នុងការដឹកនាំ និង គ្រប់គ្រងនៅមូលដ្ឋាន ។

**រយៈពេល** : ៣៥នាទី

**វិធីសាស្ត្រ** : ការបង្ហាញផ្ទាំងរូបភាព ការបង្ហាញកាតពិណ

**សំភារៈ** : ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ ក្រដាសរាម ពណ៌។ល។

**ឯកសារមេរៀន** : ឯកសារមេរៀនទី៣: តំរូវការយេនឌ័រ

### របៀបសំរបសំរួលៈ

- អ្នកសំរបសំរួលបង្ហាញគោលបំណងនៃមេរៀន៣ និងសុំអោយអ្នកចូលរួមអាន។
- ពន្យល់ពាក្យៈ តំរូវការយេនឌ័រ

អ្នកសំរបសំរួល ចាប់ផ្តើម ដោយនិយាយថា : ដោយសារទំនាក់ទំនង តួនាទី សិទ្ធិអំណាច ដែល សង្គម បានផ្តល់ដល់បុរស ស្ត្រី មានលក្ខណៈខុសគ្នា សេចក្តីត្រូវការរបស់ពួកគេក៏មានលក្ខណៈខុសគ្នាទៅតាម នោះដែរ។ ដូចនេះវាមានសារៈសំខាន់ណាស់ក្នុងការវិភាគបែងចែក អោយដាច់ពីគ្នារវាងតំរូវការទាំងនោះ ដើម្បីអោយ

គោលនយោបាយផែនការកម្មវិធីកម្មវិធីគំរោងអភិវឌ្ឍន៍មានប្រសិទ្ធិភាពដោយបានដោះស្រាយឆ្លើយតបទៅនិង សេចក្តីត្រូវការរបស់បុរស-ស្ត្រី ពិតប្រាកដ។

- អ្នកសំរបសំរួលសួរទៅទៅអ្នកចូលរួមថា តើបុរស-ស្ត្រី ត្រូវការអ្វីខ្លះដើម្បីជីវិតរស់នៅ?
- អ្នកសំរបសំរួលកត់ត្រាចំលើយ
- អ្នកសំរបសំរួល បំផុសអោយអ្នកចូលរួម កំណត់ពីប្រភេទនៃតំរូវការបុរស-ស្ត្រីទាំងនោះ គឺតំរូវការ មាន ២ប្រភេទ

### ១.តម្រូវការយេនឌ័រចំពោះមុខៈ

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា : តើតប្រូវការយេនឌ័រចំពោះមុខ មានលក្ខណៈដូចម្តេច? ហើយអាច កែប្រែអ្វីខ្លះដល់ជីវិតរស់នៅប្រចាំថ្ងៃ បុរស ស្ត្រី ?
- អ្នកសំរបសំរួលកត់ត្រាចំលើយ លើក្រដាសផ្ទាំងធំ
- អ្នកសំរបសំរួល បំផុសអោយអ្នកចូលរួមអោយ និយមនយ័ពីតម្រូវការចំពោះមុខ
- អ្នកសំរបសំរួល បកស្រាយ បង្ហាញ ពីតម្រូវការយេនឌ័រចំពោះមុខ (ឯកសារមេរៀន ទី៣ ចំណុចទី១)
- អ្នកសំរបសំរួលសួទៅអ្នកចូលរួមថា តើមានចម្ងល់អ្វីទាក់ទងតម្រូវការយេនឌ័រចំពោះមុខ និងឆ្លើយ សំនួររបស់អ្នកចូលរួម។

**២.តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ**

- អ្នកសំរបសំរួលសួទៅអ្នកចូលរួមថា តើតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រមានលក្ខណៈដូចម្តេច ហើយអាច ជួយកែប្រែអ្វីខ្លះដល់ជីវិតរស់នៅរបស់បុរស-ស្ត្រី?

- អ្នកសំរបសំរួល កត់ត្រាចំលើយ លើក្រដាសផ្ទាំងធំ

- អ្នកសំរបសំរួល បំផុសអោយអ្នកចូលរួមអោយនិយមនយ័ពីតម្រូវការជាយុទ្ធសាស្ត្រ

- អ្នកសំរបសំរួល បកស្រាយ បង្ហាញ ពីតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ (ឯកសារមេរៀន ទី៣ ចំណុចទី២)

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើមានចម្ងល់អ្វីទាក់ទងតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ និង ឆ្លើយសំនួររបស់អ្នកចូលរួម។

**សង្ខេបមេរៀន**

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើគាត់បានទទួលអ្វីខ្លះពីប្រធានបទនេះ?

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួម សង្ខេបខ្លឹមសារ មេរៀនតម្រូវការយេនឌ័រ ១ចំណុចម្នាក់ៗ។

-អ្នកសំរបសំរួល សួទៅអ្នកចូលរួមថា តើអ្វីដែលបានទទួលពីប្រធានបទនេះ ឆ្លើយតបទៅ និងមេរៀន ដែរឬទេ?

# គំរោងមេរៀនទី៤
# ស្ត្រី និងការធ្វើសេចក្តីសំរេច

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀន អ្នកចូលរួមទាំងអស់អាចៈ

-បង្កើនការយល់ដឹងពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសំរេច

**រយៈពេល** : ៤០ នាទី

**វិធីសាស្ត្រ** : បំផុសគំនិត ពិភាក្សារជាគូ

**សំភារៈ** : ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ល។

ឯកសារមេរៀនទី៨ ស្ត្រី និងការធ្វើសេចក្តីសំរេច

របៀបសំរបសំរួលៈបង្ហាញពីគោលបំណង

**១ .ស្ថានភាពស្ត្រីក្នុងការធ្វើសេចក្តីសំរេច**

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា បច្ចុប្បន្ននេះស្ត្រីដែលមានតួនាទីជាថ្នាក់ដឹកនាំនៅគ្រប់លំដាប់ថ្នាក់មានកំរិតណា ? (ចំនួនជា %)

+ អ្នកសំរបសំរួលកត់ត្រាចំលើយ សង្ខេបយោបល់អ្នកចូលរួម

+ អ្នកសំរបសំរួល បកស្រាយបង្ហាញពី ពីចំនួន %ស្ត្រីដែលមានតួនាទីជាអ្នកដឹកនាំគ្រប់លំដាប់ថ្នាក ដោយផ្អែកលើឯកសារមេរៀនទី ចំណុចទី១

**២ . មូលហេតុដែលស្ត្រីជាថ្នាក់ដឹកនាំ និងថ្នាក់ធ្វើសេចក្តីសំរេចមានចំនួនតិច**

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា ហេតុអ្វីបានជាស្ត្រីជាថ្នាក់ដឹកនាំមានចំនួនតិច?

+ អ្នកសំរបសំរួលបំផុសអោយអ្នកចូលរួម បញ្ចេញយោបល់លើចំណុចនេះ ដោយផ្តោតទៅលើតួនាទីយេនឌ័រកំណត់ដោយសង្គម ការទទួលការអប់រំ ការរើសអើងចំពោះស្ត្រី...

+អ្នកសំរបសំរួលកត់ត្រាចំលើយ សង្ខេបយោបលអ្នកចូលរួម

+អ្នកសំរបសំរួល បកស្រាយបង្ហាញពីមូលហេតុ ដែលស្ត្រីជាថ្នាក់ដឹកនាំ នៅមានចំនួនតិច ដែលផ្អែកលើ មេរៀនទី៨ ចំណុចទី២

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើមានចំងល់អ្វីទាក់ទងទៅ និងចំណុចនេះ? ហើយអ្នកសំរប-សំរួលបកស្រាយចំងល់នោះ

**៣ . សារៈសំខាន់នៃការចូលរួមរបស់ស្ត្រី**

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើការចូលរួមរបស់ស្ត្រី នៅគ្រប់លំដាប់ថ្នាក់ មានសារៈ-សំខាន់អ្វីខ្លះ?

+អ្នកសំរបសំរួលកត់ត្រាចំលើយ

+អ្នកសំរបសំរួលបំផុសសំនួរទៅអោយអ្នកចូលរួមបន្តទៀតថា តើត្រូវធ្វើដូចម្តេចដើម្បីអោយស្ត្រីបានចូលរួមធ្វើជាថ្នាក់ដឹកនាំ?

+អ្នកសំរបសំរួលកត់ត្រាចំលើយ

+អ្នកសំរបសំរួល បកស្រាយបង្ហាញបន្ថែមថា គ្រួសារ សហគមន៍ និងសង្គមទាំងមូល ត្រូវជួយចែករំលែកការងារផ្ទះ សំបែងរបស់ស្ត្រីបង្កឳកាស និងគាំទ្រស្ត្រីដើម្បីឆ្ពោះទៅរកតួនាទីជាអ្នកដឹកនាំនៅគ្រប់កំរិត

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើមានចំងល់អ្វីទាក់ទងទៅ និងចំណុចនេះ? ហើយអ្នកសំរបសំរួលបកស្រាយចំងល់នោះ

## សង្ខេបមេរៀន

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា បានទទួលអ្វីខ្លះពីមេរៀននេះ ហើយខ្លឹមសារដែលបានពិភាក្សាឆ្លើយតប និងគោលបំណងនៃមេរៀនដែរឬទេ?

# ប្លង់មេរៀន ទី១
# កុមារត្រូវមានសិទ្ធិ និងត្រូវការសិទ្ធិ

- **គោលបំណង :**

  - ដឹងពីមូលហេតុដែលកុមារត្រូវមានសិទ្ធ និងត្រូវការសិទ្ធិ

- **រយៈពេល : ៤០នាទី**
- **វិធីសាស្រ្ត :** បំផុសគំនិត និងការបង្ហាញកាតពិណ
- **សំភារៈ :** ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត មេរៀនទី១ : កុមារត្រូវមានសិទ្ធ និងត្រូវការសិទ្ធិ
- **សកម្មភាព សំរបសំរួល :**

**១-សេចក្តីផ្តើម :** អ្នកសំរបសំរួលចាប់ផ្តើមដោយលើកសុភាសិតខ្មែរដែលពោលថា : "កុមារជាទំពាំងស្នងឬស្សី "ឬ" កុមារជា សរសរទ្រូងនៃប្រទេសជាតិ" ។ ដើម្បីឱ្យបានឫស្សីល្អចាំបាច់ត្រូវមានទំពាំងល្អ ។

ដូចគ្នានេះដែរដើម្បីឱ្យសង្គមជាតិមានភាពរីកចំរើន និងរឹងមាំចាំបាច់ត្រូវតែមានកុមារដែលល្អ ទាំងរូបកាយចិត្តគំនិត ចំណេះដឹង...។ល។

ដូច្នេះកុមារត្រូវតែទទួលបាននូវការយកចិត្តទុកដាក់បីបាច់ថែរក្សា ការគោរព និងការអនុវត្តសិទ្ធិរបស់ពួកគេ ទើបឱកាសអភិវឌ្ឍន៍សក្តានុពលរបស់ពួកគេបានពេញបរិបូណ៌ ។

**២- ការផ្លាស់ប្តូរយោបល់ពីសិទ្ធិកុមារ :**

- អ្នកសំរបសំរួល សួរទៅអ្នកចូលរួមថា : តើអ្នកធ្លាប់ឮ ឬយល់ពាក្យ "សិទ្ធិ" ដែរឬទេ ?

\+ ចំលើយរួមមាន :

- តើកុមារមានសិទ្ធិដែរឬទេ ? ហេតុអ្វីបានជាកុមារត្រូវមានសិទ្ធិ ?

\+ ចំលើយចូលរួម :

- តើអ្នកមានកូនដែរឬទេ ? តើអ្នកទទួលស្គាល់សិទ្ធិរបស់កូនអ្នកដែរឬទេ ?

\+ ចំលើយចូលរួម :

- តាមយោបល់របស់អ្នកតើអ្វីខ្លះជាសិទ្ធិសំខាន់របស់កុមារ ? ហេតុអ្វី ?

\+ ចំលើយចូលរួម :

- តើអ្នកដឹងពីវិធីជួយឱ្យកុមារទទួលបានសិទ្ធិ របស់ពួកគេបានពេញលេញដែរឬទេ ?

\+ ចំលើយចូលរួម :

- អ្នកសំរបសំរួលបង្ហាញ និងបកស្រាយបំភ្លឺ អំពីកុមារត្រូវមានសិទ្ធិ និងត្រូវការសិទ្ធិ

# ប្លង់មេរៀន ទី២
# សិទ្ធិជាមូលដ្ឋានរបស់កុមារ

- **គោលបំណង :**

    - ដឹងពីសេចក្តីត្រូវការ និងសិទ្ធិជាមូលដ្ឋានរបស់កុមារនៅតាមសហគមន៍

- **រយៈពេល** : ៤៥នាទី
- **សំភារៈ** : ក្រដាសផ្ទាំងធំ ហ្វឺត ឯកសារមេរៀន ទី២
- **វិធីសាស្ត្រ** : សំនួរបំផុសគំនិត ពិភាក្សាក្រុម បង្ហាញរូបភាព បកស្រាយ
- **សកម្មភាពសំរបសំរួល :**

**១- ការពិភាក្សាក្រុមតូច :**

- អ្នកសំរបសំរួលចាប់ផ្តើមដោយលើកឡើងថា :យើងបានពិភាក្សាគ្នារួចមកហើយ អំពីមូលហេតុដែល កុមារចាំបាច់ត្រូវការ និងត្រូវមានសិទ្ធិ ។ ឥឡូវនេះយើងពិភាក្សាអំពីសិទ្ធិជាមូលដ្ឋានរបស់កុមារ ។

- អ្នកសំរបសំរួលបែងចែកសិក្ខាកាមជា៤ក្រុមក្រុមនីមួយៗគូររូបកុមារម្នាក់ដាក់ឈ្មោះកំណត់លក្ខណៈសម្បត្តិរបស់កុមារនោះ ដែលគេចង់ឱ្យកុមារនោះមាន និងរៀបរាប់នូវធនធានសំភារៈដែលកុមារត្រូវការ ។

- បង្ហាញលទ្ធផលពិភាក្សា

**២- ការសួរសំនួរបំផុស និងបង្ហាញពីតំរូវការរបស់កុមារ**

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា : ផ្អែកលើលទ្ធផលនៃការពិភាក្សា តើតំរូវការរបស់កុមារមានអ្វីខ្លះ ?

+ ចំលើយចូលរួម

- អ្នកសំរបសំរួលបន្តសំនួរ

- នៅក្នុងសហគមន៍ តើតំរូវការចាំបាច់ណាខ្លះដែលបានផ្តល់ឱ្យកុមារ ? ហើយអ្វីខ្លះដែលមិនបានផ្តល់ ?

- ផលដោយអ្នកណា ?ស្ថាប័នណា?

- ហេតុអ្វីបានជាតំរូវការខ្លះមិនបានផ្តល់ឱ្យ ?

- តើក្រុមប្រឹក្សាឃុំ/សង្កាត់ មានវិធានការអ្វីខ្លះដែលត្រូវអនុវត្តន៍ ដើម្បីបំពេញសេចក្តីត្រូវការទាំងនោះ ?

- អ្នកសំរបសំរួលបង្ហាញ បកស្រាយ ឯកសារមេរៀន ទី២ សិទ្ធិជាមូលដ្ឋានរបស់កុមារ (ចំណុចទី១)

-ការពិភាក្សាក្រុមតូច :

- អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមសរសេរសិទ្ធិកុមារចំនួន១០

- អ្នកសំរបសំរួលបែងចែកជា៤ក្រុម ហើយចែករូបភាពទាំង១៦ ដែលបង្ហាញពីសិទ្ធិកុមារឱ្យក្រុមនីមួយៗ ហើយពន្យល់ថា រូបភាពនីមួយៗជាប់ពាក់ព័ន្ធ និងផ្អែកនៃសិទ្ធិកុមារជាមូលដ្ឋានណាមួយក្នុងចំណោមសិទ្ធិជាមូលដ្ឋានទាំង៤

- អ្នកសំរបសំរួលស្នើឱ្យក្រុមនីមួយៗរៀបរូបភាពជា៤ក្រុម

**ឧទាហរណ៏ ៖** គូររូបភាពណាដែលគិតថាតំណាងឱ្យសិទ្ធិការពារ - សិទ្ធិចូលរួម - សិទ្ធិអភិវឌ្ឍន៍ - សិទ្ធិរស់រាន ។ ហើយបញ្ជាក់ថាមានតែ៤រូបភាពទេក្នុងសិទ្ធិនីមួយៗ ។

- អ្នកសំរបសំរួលសរសេរចំណងជើង នៃសិទ្ធិជាមូលដ្ឋានទាំង៤នៅលើក្រដាសផ្ទាំងធំ ហើយបិទទៅលើ ជញ្ជាំងនិមួយៗ នៃបន្ទប់បណ្តុះបណ្តាល ។
- ពេលពិភាក្សាចប់ អ្នកសំរបសំរួលស្នើឱ្យ ៖
  - ក្រុមទី ១ ៖ បិទរូបភាព " សិទ្ធិទទួលការការពារ "
  - ក្រុមទី ២ ៖ បិទរូបភាព " សិទ្ធិរស់រានមានជីវិត "
  - ក្រុមទី ៣ ៖ បិទរូបភាព " សិទ្ធិក្នុងការអភិវឌ្ឍន៍ "
  - ក្រុមទី ៤ ៖ បិទរូបភាព " សិទ្ធិក្នុងការចូលរួម "
- អ្នកសំរបសំរួលពិនិត្យមើលថា តើសិក្ខាកាមបានបិទរូបភាពទាំងនោះបានត្រឹមត្រូវហើយឬនៅ? និងត្រូវធ្វើ ការកែតម្រូវបើចាំបាច់ ។

+ ចំលើយមានដូចជា ៖

| | |
|---|---|
| **រស់រានមានជីវិត**<br>- កុមារទាំងអស់ត្រូវតែទទួលទានចំណីអាហារបានគ្រប់គ្រាន់<br>- កុមារទាំងអស់ត្រូវតែមានឈ្មោះ និងសញ្ជាតិ<br>- កុមារទាំងអស់ត្រូវតែមានជំរកសមរម្យ<br>- កុមារទាំងអស់ត្រូវទទួលការចាក់ថ្នាំបង្ការ និងថែទាំសុខភាព | **ទទួលការ ការពារ**<br>- ត្រូវការពារកុមារពីការរំលោភផ្លូវភេទ<br>- ត្រូវការពារកុមារពីអំពើហិង្សា<br>- ត្រូវការពារកុមារពីពលកម្មធ្ងន់ធ្ងរ<br>- ត្រូវការពារកុមារឱ្យផុតពីការប្រើប្រាស់គ្រឿងញៀន |
| **អភិវឌ្ឍន៍**<br>- កុមារត្រូវការថែទាំយ៉ាងកក់ក្តៅពីក្រុមគ្រួសារ<br>- កុមារទាំងអស់ត្រូវទទួលបាននូវការអប់រំ រៀនសូត្រ<br>- កុមារត្រូវមានឱកាសចូលរួមក្នុងសិល្បៈ វប្បធម៌ជាតិ<br>- កុមារត្រូវការកម្សាន្ត និងលំហែ | **ការចូលរួម**<br>- កុមារអាចចូលរួម និងបង្កើត សមាគមន៍<br>- ត្រូវអនុញ្ញាតិឱ្យកុមារបញ្ចេញ មតិយោបល់<br>- កុមារត្រូវទទួលបាន និងផ្សព្វផ្សាយនូវពតិមាន សមស្រប<br>- កុមារត្រូវដឹងពីសិទ្ធិរបស់ខ្លួន |

អ្នកសម្របសម្រួលបង្ហាញបកស្រាយមេរៀនទី២ (ចំណុចទី ២ សិទ្ធិនានាដែលស្ថិតនៅក្នុងផ្នែកនិមួយៗ នៃសិទ្ធិជា មូលដ្ឋានរបស់កុមារ )

## គំរោងមេរៀនទី ៣ :
## គោលការណ៍ជាមូលដ្ឋានពាក់ព័ន្ធនឹងសិទ្ធិកុមារ

**គោលបំណង :**

- ដឹងច្បាស់ពីគោលការណ៍ទាំង ៤ ដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ

**រយៈពេល :** ៣០ នាទី

**សំភារៈ :** ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ឯកសារមេរៀនទី ៣

**វិធីសាស្ត្រ :** សំនួរបំផុសគំនិត ការពិភាក្សារក្រុមតូច

**សកម្មភាពអ្នកសំរបសំរួល :**

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា :

+ តើគោលការណ៍ជាមូលដ្ឋានពាក់ព័ន្ធនឹងសិទ្ធិកុមារមានអ្វីខ្លះ ? ចំលើយអ្នកចូលរួម :

+ អ្នកចូលរួមបង្ហាញពីគោលការណ៍មូលដ្ឋានទាំង ៤ ហើយជំរាបទៅសិក្ខាកាមថា យើងនឹងពិភាក្សាគោលការណ៍ទាំង ៤នេះ មួយចំណុចម្តង១ :

**១- ការមិនរើសអើង :**

- អ្នកសំរបសំរួលបង្ហាញពីស្ថានភាពផ្សេង១របស់កុមារ ហើយសួរទៅអ្នកចូលរួមថា :

+ តើអ្នកគិតថា កុមារទាំងអស់មានសិទ្ធិស្មើគ្នាដែររឺទេ ? បើមានហេតុអ្វី ?

ប្រសិនបើមិនមានហេតុអ្វី ? ចំលើយអ្នកចូលរួម :

- អ្នកសំរបសំរួល ធ្វើការពន្យល់ឯកសារមេរៀនទី ៣ (ចំណុចទី ១ : ការមិនរើសអើង ) មួយ ចំណុចម្តង១។

**២- ឧត្តមប្រយោជន៏របស់កុមារ :**

- អ្នកសំរបសំរួលបកស្រាយ បង្ហាញឯកសារមេរៀនទី ៣ (ចំណុច ៣.២ : ឧត្តមប្រយោជន៏របស់កុមារ ) មួយចំណុចម្តង១ ហើយសុំអោយអ្នកចូលរួមជួយរកឧទាហរណ៏ផ្សេង១ទៀត ដែលមានក្នុងសហគមន៏របស់ពួកគេ។

- ក្រោយពីបង្ហាញចប់ អ្នកសំរបសំរួលត្រូវបញ្ជាក់បន្ថែមទៀតថា រាល់ការធ្វើសេចក្តីសំរេចចិត្តទាំងឡាយណាដែលប៉ះពាល់ដល់កុមារ អ្នកធ្វើសេចក្តីសំរេចចិត្តនោះត្រូវគិត និងអនុវត្តតាមគោលការណ៏ឧត្តមប្រយោជន៏របស់កុមារ។

**៣- ការរស់រានមានជីវិត និងការអភិវឌ្ឍន៏ :**

- អ្នកសំរបសំរួលបង្ហាញ និងបកស្រាយពន្យល់ឯកសារមេរៀនទី ៣(ចំណុច ៣.៣ : ការរស់រានមានជីវិត និងការអភិវឌ្ឍន៏ ) មួយចំណុចម្តង១ ហើយសុំអោយអ្នកចូលរួមជួយរកឧទាហរណ៏ផ្សេង១ ទៀត ដែលនៅក្នុងសហគមន៏របស់គេ។

**៤- គោរពមតិយោបល់របស់កុមារ :**

- អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា

+ តើអ្នកធ្លាប់ធ្វើតាមមតិយោបល់របស់កុមារ ឬកូនៗរបស់លោកអ្នកដែរទេ ? សូមអោយឧទាហរណ៍

+ ហេតុអ្វីបានជាអ្នកត្រូវធ្វើតាមមតិយោបល់របស់កុមារ?

+ កត់ត្រាចំលើយ

+ អ្នកសំរបសំរួលបង្ហាញ និងបកស្រាយឯកសារមេរៀនទី ៣ ( ចំណុច ៣.៤ : គោរពមតិយោបល់របស់កុមារ ) មួយចំណុចម្តងៗ ។

## គំរោងមេរៀនទី ៤ :
## កត្តាដែលនាំអោយមានការរំលោភបំពានសិទ្ធិកុមារ

**គោលបំណង :**

- ដឹងច្បាស់ ពីកត្តាដែលនាំអោយមានការរំលោភបំពានសិទ្ធិកុមារ

**រយៈពេល :** ៩០ នាទី

**សំភារៈ :** ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ឯកសារមេរៀនទី ៤

**វិធីសាស្ត្រ :** សំនួរបំផុសគំនិត និងករណីសិក្សារ

**សកម្មភាពអ្នកសំរបសំរួល :**

១- អ្នកសំរបសំរួលអានករណីសិក្សា ទារកឈ្មោះ "ដា" ហើយសុំអោយសិក្ខាកាមរកមូលហេតុ ដែលនាំអោយមានការរំលោភបំពានចំពោះទារកឈ្មោះ "ដា" ។ ចំលើយអាចមានដូចជា :

| កុមារ និងគ្រួសារ | សមាគមន៍ និងបរិស្ថានដែលកុមាររស់នៅ |
|---|---|
| - ភាពក្រីក្ររបស់កុមារ | - គ្មានអង្គការ ឬស្ថាប័នសំរាប់ផ្តល់សេវា ជួយដល់កុមារក្រីក្រនៅសហគមន៍ |
| - កើតមកមានជើងពិកា | - ខ្វះការផ្សព្វផ្សាយអំពីសិទ្ធិកុមារ |
| - ឪពុករបស់ "ដា" ស្លាប់ | - ចំណេះដឹងរបស់ប្រជាពលរដ្ឋ នៅមានកំរិត |
| - "ដា" មានបង-ប្អូនច្រើន | - នៅមានជំនឿលើកម្មផល |
| | - មានការរើសអើងចំពោះក្មេងស្រី |

២- អ្នកសំរបសំរួលស្នើអោយសិក្ខាកាម ពិនិត្យឡើងវិញអំពីការអនុវត្តសិទ្ធិកុមារនៅក្នុងសហគមន៍របស់គេថា:

+ តើសិទ្ធិជាមូលដ្ឋានទាំង ៤ របស់កុមារ ត្រូវបានគេអនុវត្តនៅក្នុងសហគមន៍ របស់អ្នកហើយឬនៅ? បានអនុវត្តសិទ្ធិអ្វីខ្លះ ?

+ តើសិទ្ធិទាំងនោះ បានអនុវត្តពេញលេញហើយឬនៅ ? ហើយតើមានមូលហេតុអ្វីខ្លះ ? ដែលនាំអោយមានការរំលោភបំពានលើសិទ្ធិកុមារ? ចំលើយចូលរួម អាចមាន :

**- កុមារទទួលបានសិទ្ធិ ៤ :**

+ កុមារទទួលបានការស្រឡាញ់ថ្នាក់ថ្នម ពីឪពុក-ម្តាយ និងក្រុមគ្រួសារ
+ កុមារបានចុះសំបុត្រកំណើត មានម្ហូបអាហារ សំលៀកបំពាក់ និងផ្ទះសំបែង
+ កុមារទទួលបានការរៀនសូត្រ និងលេងកំសាន្តជាមួយមិត្តភ័ក្ត្រ
+ កុមារទទួលបានការព្យាបាល និងចាក់ថ្នាំបង្ការជម្ងឺ
+ កុមារមិនទទួលរងនូវការរំលោភបំពាននានា ពីឪពុក-ម្តាយ ញាតិមិត្ត បង-ប្អូន និងអ្នកដទៃ ដូចជាការកេងប្រវ័ញ្ចពលកម្ម ឬការបោកបញ្ឆោតផ្សេងៗ ។
+ កុមារមានទូរទស្សន៍ សៀវភៅ និងឯកសារនានា ដើម្បីអាននិងទទួលពត៌មាន ... ។ល ។
+ អ្នកសំរបសំរួលបង្ហាញឯកសារមេរៀនទី ៤

## គំរោងមេរៀនទី៥

## ការដោះស្រាយការរំលោភសិទ្ធកុមារ

**គោលបំណង:**

+ ដឹងពីអ្នកទាមទារសិទ្ធិ និងអ្នកមានកាតព្វកិច្ចទទួលខុសត្រូវ

+ ធ្វើការកំណត់ចំណាំ លើប្រភេទសិទ្ធិដែលត្រូវគេរំលោភ និងអ្នកមានកាតព្វកិច្ចទទួល ខុសត្រូវ

+ មានគំនិតផ្តួចផ្តើមដើម្បីដោះស្រាយបញ្ហា

**រយៈពេល** : ៧៥ នាទី

**វិធីសាស្ត្រ** : សំនួរបំផុសគំនិត និងពិភាក្សារជាគូ

**សំភារះ** : ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ល។

សកម្មភាពសំរបសំរួល

**១ . អ្នកទាមទារសិទ្ធិនិងអ្នកមានកាតព្វកិច្ចទទួលខុសត្រូវះ**

អ្នកសំរបសំរួលបំផុសគំនិត និងកត់ត្រាចំលើយរបស់អ្នកចូលរួម រួចបកស្រាយបញ្ជាក់បន្ថែម តាមខ្លឹមសារ ( 5.1 ) ។

**២.ការកំណត់សិទ្ធិដែលត្រូវគេបានរំលោភះ**

អ្នកសំរបសំរួលរៀបចំអោយអ្នកចូលរួមពិភាក្សាដៃគូ យកតារាងកំណត់សិទ្ធិដែលគេត្រូវរំលោភបំពានមកធ្វើលំហាត់នៅក្រុមធំ ( 5.2 ) អ្នកសំរបសំរួលបញ្ជាក់បន្ថែម ។

**៣.ការកំណត់អ្នកមានកាតព្វកិច្ចទទួលខុសត្រូវះ**

អ្នកសំរបសំរួលយកតារាង ( 5.3 ) ធ្វើលំហាត់ក្រុមធំ ហើយធ្វើសុពលភាពតាមខ្លឹមសារមេរៀន ។

**៤.ការគិតពិចារណាដោយគមនិតច្នៃប្រឌិតះ**

អ្នកសំរបសំរួលលើកសំនួរបំផុសគំនិត ហើយពន្យល់បកស្រាយដោយលើកឧទាហរណ៏មានស្រាប់ នៅក្នុង ( 5.4 )

-ករណីចាក់ថ្នាំបង្ការ

-ករណីឳពុកម្តាយវាយកូន

-ករណីឳពុកម្តាយមិនចង់អោយកូនស្រីទៅរៀន

# ប្លង់មេរៀនទី១
# កុមារត្រូវការ កិច្ចការពារពិសេស

- **គោលបំណង :**

    - ដឹងពីប្រភេទកុមារដែលត្រូវការកិច្ចការពារពិសេសនៅក្នុងសហគមន៍
    - ដឹងពីអត្ថប្រយោជន៍នៃការចុះសំបុត្រកំណើត

- **រយៈពេល** : **៤០នាទី**
- **សំភារៈ** : ក្រដាសធំ ហ្វឹត ស្កុត ឯកសារមេរៀន ពិភាក្សាក្រុមធំ
- **វិធីសាស្ត្រ** : សំណួរបំផុសគំនិត រូបភាព បង្ហាញពន្យល់
- **សកម្មភាពសម្របសម្រួល :**

## ១.១- កុមារដែលត្រូវការ កិច្ចការពារពិសេស

+ អ្នកសម្របសម្រួលចាប់ផ្តើមដោយសួរថា :

    - តើអ្នកស្គាល់កុមារបានដោយយ៉ាងដូចម្តេច ?
    - តើកុមារដែលងាយរងគ្រោះមានន័យដូចម្តេច ?
    - តើកុមារត្រូវការកិច្ចការពារពិសេសមានន័យដូចម្តេច ?
    - តើការអភិវឌ្ឍន៍របស់កុមារមានអ្វីខ្លះ ?
    - តើការអភិវឌ្ឍន៍របស់កុមារមានប៉ុន្មានដំណាក់កាល ? អ្វីខ្លះ ?

+ អ្នកសម្របសម្រួលបូកសរុបសចម្លើយ

- អ្នកសម្របសម្រួលចែករូបភាពកុមារស្ថិតនៅក្នុងស្ថានភាពលំបាកទី១ ដល់ទី៦ ហើយសួរថា :

    - តើអ្នកបានឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ ?
    - តើអ្នកមានអារម្មណ៍បែបណាចំពោះស្ថានភាពកុមារទាំងនោះ ?

ចម្លើយចូលរួម :

- អ្នកសម្របសម្រួលបន្ថែមថា ជាធម្មតាកុមារត្រូវបានគេចាត់ទុកថាជាជនងាយរងគ្រោះពីព្រោះ :

    - កុមារពឹងផ្អែកយ៉ាងច្រើនទៅលើមនុស្សចាស់ ទាំងខាងផ្លូវចិត្ត ផ្លូវកាយ ដែលជាហេតុធ្វើឱ្យពួកគេងាយនឹងត្រូវគេ បោកបញ្ឆោត រំលោភបំពាន ឬកេងប្រវ័ញ្ចបានយ៉ាងងាយជាងមនុស្សពេញវ័យ
    - កុមារដែលមានវ័យកាន់តែក្មេង កាន់តែងាយរងគ្រោះ

- កុមារជឿជាក់យ៉ាងខ្លាំងលើមនុស្សចាស់ដែលជាហេតុធ្វើឱ្យពួកគេងាយនឹងត្រូវគេបោកបញ្ឆោត រំលោភបំពាន ឬកេងប្រវ័ញ្ចបានយ៉ាងងាយជាងមនុស្សពេញវ័យ ។

យើងទាំងអស់គ្នាបានដឹងហើយថា កុមារជាច្រើននៅក្នុងសហគមន៍ គឺជាកុមារដែលងាយរងគ្រោះ ប៉ុន្តែកុមារ ដែលត្រូវអន្តរាគមន៍ជាបន្ទាន់នោះគឺកុមារដែលត្រូវការកិច្ចការពារពិសេស

+ អ្នកសម្របសម្រួល សុំឱ្យក្រុមធំធ្វើលំហាត់លើក្រដាសផ្ទាំងធំ ឯកសារ ១.១ លំហាត់អំពីការកំណត់ប្រភេទកុមារដែលត្រូវការកិច្ចការពារពិសេស

+ អ្នកសម្របសម្រួលបង្ហាញ និងសំរបសំរួលឯកសារមេរៀនទី១ ( ចំណុច ១.១ កុមារដែលត្រូវការកិច្ចការពារពិសេស )

**១.២- សារៈប្រយោជន៏នៃការចុះសំបុត្រកំណើត**

+ អ្នកសម្របសម្រួលបង្ហាញសំបុត្រកំណើត ហើយសួរថាតើអ្នកដឹងទេនេះគឺជាអ្វី ?

-តើសំបុត្រកំណើតនេះផ្តល់សារៈប្រយោជន៍អ្វីខ្លះដល់កុមារ?ដល់អាជ្ញាធរមូលដ្ឋាន ?

កត់ត្រាចម្លើយ

+ អ្នកសម្របសម្រួល បង្ហាញឯកសារមេរៀនទី១ ( ចំណុច ១.២ សារៈប្រយោជន៏ នៃសំបុត្រកំណើត) ហើយបញ្ជាក់ថា :

នៅជំហ៊ានដំបូង ដើម្បីការពារកុមារ គឺត្រូវធានាថា កុមារគ្រប់រូបនៅក្នុងភូមិ-ឃុំ-សង្កាត់ បានចុះសំបុត្រកំណើត និងទទួលបានសំបុត្រកំណើត ។ បើកុមារមិនបានចុះសំបុត្រកំណើត ពួកគេនឹងងាយក្លាយខ្លួនជាកុមារដែលងាយរងគ្រោះ ហើយត្រូវការកិច្ចការពារពិសេស ។

+ អ្នកសំរបសំរួល សុំឱ្យអ្នកចូលរួមធ្វើសុពលភាព ( ឯកសារ ១.២ ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ) លើក្រដាសផ្ទាំងធំ ។

# ប្លង់មេរៀនទី ២

# កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា

**គោលបំណង :**

- ដឹងពីកុមារកំព្រា និងកុមារដែលត្រូវគេបោះបង់ចោល
- ចាត់វិធានការណ៍សមស្រប នៅពេលដែលមានកុមារកំព្រា និងកុមារដែលត្រូវគេបោះបង់ចោល ។

**រយះពេល** : ៥០ នាទី

**វិធីសាស្ត្រ** : សំនួរបំផុសគំនិត និងបកស្រាយ ករណីសិក្សារ

**សំភារះ** : ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ។ល។

## សកម្មភាពសំរបសំរួល

១. ការពិភាក្សាតាមក្រុមតូច

- អ្នកសំរបសំរួល ចែកសិក្ខាកាមជាពីរក្រុមពិភាក្សា

១ - ឯកសារ ២.១ ករណីសិក្សារឿងរបស់សារឿន

២ - ឯកសារ ២.២ ករណីសិក្សារឿងរបស់មុំ

- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សា
- អ្នកសំរបសំរួល បកស្រាយបង្ហាញ មេរៀនទី ២ ដោយសួរទៅអ្នកចូលរួម
- តើកុមារកំព្រាមានន័យដូចម្តេច?
- តើកុមារដែលត្រូវគេបោះបង់ចោលមានន័យដូចម្តេច?
- តើដំណោះស្រាយអ្វីខ្លះ ដើម្បីជួយដល់កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា?
- អ្នកសំរបសំរួលកត់ត្រាចំលើយ
- អ្នកសំរបសំរួលបង្ហាញ (ឯកសារ ២.៣ ផែនការសកម្មភាពរបស់អជ្ញាធរមូលដ្ឋាន) និងសុំអោយអ្នកចូលរួមជួយបន្ថែម សកម្មភាពនានាទៀត ។

## ប្លង់មេរៀនទី ៣

## កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា

**គោលបំណង:**

-ដឹងពីផលប៉ះពាល់ជាអវិជ្ជមាន នៃអំពើហិង្សាក្នុងគ្រួសារចំពោះកុមារ

-ដឹងពីសេវាសមស្របនានា សំរាប់ជួយកុមាររស់នៅ ក្នុងគ្រួសារដែលមានអំពើហិង្សា

-បង្កើតផែនការសកម្មភាព ដើម្បីជួយដល់កុមាររងគ្រោះ

**រយៈពេល** : ៤៥ នាទី

**វិធីសាស្ត្រ** : សំនួរបំផុសគំនិត និងបង្ហាញរូបភាព

**សំភារៈ** : ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ផ្ទាំងរូបភាព។ល។

**សកម្មភាពសំរបសំរួល**

**១ - ផលប៉ះពាល់នៃអំពើហឹស្សាក្នុងគ្រួសារ**

+ អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា

+ តើអំពើហឹស្សាក្នុងគ្រួសារ មានន័យដូចម្តេច? ចំលើយអ្នកចូលរួម

+ អ្នកសំរបសំរួល បង្ហាញ រូបភាព អំពើរូបភាព អំពើហឹស្សាក្នុងគ្រួសារ ហើយសួរទៅ អ្នកចូលរួមថា

+ តើអ្នកបានឃើញអ្វីខ្លះនៅក្នុងផ្ទាំងរូបភាពនេះ?

+ តើរូបភាពនិមួយៗមានន័យដូចម្តេច?

+ តើបញ្ហានេះធ្លាប់កើតនៅក្នុងសហគមន៏ អ្នកដែរឬទេ? បើមានសូមលើកឧទាហរណ៏ ចំលើយអ្នកចូលរួម

+ អ្នកសំរបសំរួលសួរបន្តទៀតថា

+ តើអំពើហឹស្សាក្នុងគ្រួសារ ផ្តល់ផលប៉ះពាល់អ្វីខ្លះដល់កុមារ? ចំលើយអ្នកចូលរួម

+ អ្នកសំរបសំរួលបង្ហាញ ឯកសារមេរៀនទី ៣ (ចំណុច៣.១ផលប៉ះពាល់នៃអំពើហឹស្សាលើកុមារ)

**២.ដំណោះស្រាយ:**

+ អ្នកសំរបសំរួលសួរបន្តទៀតថា

+ តើគួរធ្វើយ៉ាងណា នៅពេលមានអំពើហិង្សាក្នុងគ្រួសារ ដែលប៉ះពាល់ដល់កុមារ ចំលើយអ្នកចូលរួម

+ អ្នកសំរបសំរួលបង្ហាញ ឯកសារមេរៀនទី ៣ (ចំណុច៣.២ ដំណោះស្រាយ)

+ អ្នកសំរបសំរួលបង្ហាញ (ឯកសារចំណុច ៣.១ ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន) ហើយសុំអោយអ្នកចូលរួមជួយបន្ថែម សកម្មភាពនានាទៀត។

## ប្លង់មេរៀនទី ៤ :
## កុមារដែលត្រូវគេរំលោភផ្លូវភេទ

**គោលបំណង :**

- ដឹងច្បាស់ ពីផលប៉ះពាល់ជាអវិជ្ជមាន នៃការរំលោភផ្លូវភេទលើកុមារ
- ដឹងពីល្បិចកលរបស់ជនល្មើស
- ចាត់វិធានការណ៍ សមស្រប ដើម្បីទប់ស្កាត់ការរំលោភផ្លូវភេទលើកុមារ

**រយៈពេល :** ៣០ នាទី

**សំភារៈ :** ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត រូបភាព ឯកសារមេរៀនទី ៤

**វិធីសាស្ត្រ :** ពិភាក្សារជាគូរ

**សកម្មភាពអ្នកសំរបសំរួល :**

**១- ផលប៉ះពាល់នៃការរំលោភផ្លូវភេទលើកុមារ :**

- អ្នកសំរបសំរួលចាប់ផ្តើមសួរថា :

+ តើការរំលោភផ្លូវភេទលើកុមារ មានន័យដូចម្តេច? ចំលើយអ្នកចូលរួម :

- អ្នកសំរបសំរួលបង្ហាញផ្ទាំងរូបភាព អំពីការរំលោភផ្លូវភេទលើកុមារ ហើយសួរថា :

+ តើអ្នកបានឃើញអ្វីខ្លះ ក្នុងរូបភាពនេះ ?

+ តើរូបភាពនីមួយៗ មានន័យដូចម្តេច?

+ តើបញ្ហានេះ ធ្លាប់កើតមាននៅក្នុងសហគមន៍អ្នកដែរទេ ? បើមានសូមលើកឧទាហរណ៍ ?
ចំលើយអ្នកចូលរួម :

- អ្នកសំរបសំរួលបន្តសំនួរ

+ តើការរំលោភផ្លូវ ផ្តល់ផលប៉ះពាល់អ្វីខ្លះដល់កុមារ ? ចំលើយអ្នកចូលរួម :

- អ្នកសំរបសំរួលបង្ហាញបកស្រាយឯកសារមេរៀនទី៤ (ចំណុច៤.១: ផលប៉ះពាល់នៃការរំលោភផ្លូវភេទ )។

**២- ល្បិចកលជនល្មើស :**

- អ្នកសំរបសំរួល សុំអោយអ្នកចូលរួមពិភាក្សាគ្នាថា :

+ តើជនល្មើសប្រើល្បិចកល ឬមធ្យោបាយអ្វីខ្លះ ដើម្បីទាក់ទាញជនរងគ្រោះ? បង្ហាញលទ្ធផល :

- អ្នកសំរបសំរួលបង្ហាញឯកសារមេរៀនទី ៤ ( ចំណុច ៤.២ : ល្បិចកលជនល្មើស )

**៣- ការអន្តរាគមន៍ករណីរំលោភផ្លូវភេទលើកុមារ :**

- អ្នកសំរបសំរួល សួរទៅសិក្ខាកាមថា :

+ តើអ្នកអាចធ្វើអ្វីខ្លះ នៅពេលដែលទទួលបានពតិមានអំពីការរំលោភផ្លូវភេទលើកុមារភ្លាមៗ ?
ចំលើយអ្នកចូលរួម :

- អ្នកសំរបសំរួលបង្ហាញឯកសារមេរៀនទី៤ (ចំណុច៤.៣: ការអន្តរាគមន៍ករណីរំលោភផ្លូវភេទលើកុមារ )

- អ្នកសំរបសំរួលបង្ហាញ ឯកសារ ៤.១: ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ) ហើយសុំអោយអ្នកចូលរួមបន្ថែមសកម្មភាពនានា ។

# ប្លង់មេរៀនទី ៥
# កុមារត្រូវគេកេងប្រវ័ញ្ចកំលាំងពលកម្ម

- **គោលបំណង :**
  - ❖ ដឹងពីប្រភេទការងារ ដែលនាំឱ្យមានគ្រោះថ្នាក់ដល់កុមារ
  - ❖ ដឹងពីផលប៉ះពាល់ជាអវិជ្ជមាន លើកុមារដែលត្រូវគេកេងប្រវ័ញ្ចពលកម្ម
  - ❖ ចាត់វិធានការណ៍ដើម្បីដោះស្រាយការកេងប្រវ័ញ្ចពលកម្ម
- **រយៈពេល :៣០ នាទី**
- **សំភារៈ** ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត ឯកសារមេរៀន
- **វិធីសាស្ត្រ :** សំនួរបំផុសគំនិត និងសំនួរ-ចំលើយ
- **សកម្មភាពសំរបសំរួល**

**១- ពលកម្មកុមារ :**

+ អ្នកសម្របសម្រួលចាប់ផ្តើមដោយសួរថា :

-តើពលកម្មកុមារ មានន័យដូចម្តេច ? ចំលើយចូលរួម :

- អ្នកសំរបសំរួលបង្ហាញ ឯកសារមេរៀនទី៥ ( ចំណុច ៥.១ : ពលកម្មកុមារ )

**២- ការងារដែលមានការកេងប្រវ័ញ្ច និងមានគ្រោះថ្នាក់**

+ អ្នកសំរបសំរួលបន្តសួរសំនួរ :

❖ តើក្នុងឃុំ-សង្កាត់ របស់លោកអ្នកមានកុមារដែលមានអាយុក្រោម១៨ឆ្នាំកំពុងតែធ្វើការងារដែរឬទេ? តើពួកគេធ្វើការនៅឯណា ? ចំលើយចូលរួម :

❖ តើទីកន្លែងណាខ្លះ ដែលអ្នកចាត់ទុកថាជាកន្លែងមានគ្រោះថ្នាក់ធ្ងន់ធ្ងរសំរាប់កុមារ ? ចំលើយចូលរួម :

❖ អ្នកសំរបសំរួលបង្ហាញឯកសារមេរៀនទី៥ (ចំណុច ៥.២ ការងារដែលមានការកេងប្រវ័ញ្ច និងមានគ្រោះថ្នាក់)

**៣- ផលប៉ះពាល់ពីការកេងប្រវ័ញ្ចកំលាំងពលកម្មកុមារ**

+ អ្នកសំរបសំរួលបន្តសំនួរ

- តើពលកម្មកុមារផ្តល់ផលប៉ះពាល់អ្វីខ្លះដល់កុមារ? ចម្លើយរួមមាន

+ អ្នកសំរបសំរួលបង្ហាញឯកសារមេរៀនទី៥ (ចំណុចទី ៥.៣ ផលប៉ះពាល់ពីការកេងប្រវ័ញ្ចកំលាំង-ពលកម្មកុមារ)

**៤- ការអនុវត្តន៍**

+ អ្នកសំរបសំរួលសួរទៀតថា

- ក្នុងនាមជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាការទទួលបន្ទុកកិច្ចការនារី និងកុមារ និងតំណាង-ភូមិ តើអាចធ្វើអ្វីបានខ្លះដើម្បីដោះស្រាយបញ្ហាការកេងប្រវ័ញ្ចកំលាំងពលកម្មកុមារ?

ចម្លើយរួមមាន

+ អ្នកសំរបសំរួលបង្ហាញឯកសារមេរៀនទី៥ ( ចំណុច ៥.៤ ការអនុវត្តន៍)

+អ្នកសំរបសំរួលបង្ហាញ (ឯកសារ៥.១ ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន) ហើយសូមឱ្យអ្នកចូលរួមបន្ថែមនូវសកម្មភាពនានាទៀត។

# គំរោងមេរៀនទី ៦ :
# កុមារចាកចេញពីសហគមន៍ដោយគ្មានឪពុក-ម្ដាយទៅជាមួយ

**គោលបំណង :**

- ដឹងច្បាស់ ពីមូលហេតុ ដែលនាំអោយចាកចេញពីសហគមន៍ ដោយគ្មានឪពុក-ម្ដាយទៅជាមួយ
- ដឹងពីភាពគ្រោះថ្នាក់ ដែលកុមារចាកចេញពីសហគមន៍ ដោយគ្មានឪពុក-ម្ដាយទៅជាមួយ
- ចាត់វិធានការណ៍ ដើម្បីទប់ស្កាត់កុមារ ដែលចាកចេញពីសហគមន៍ ដោយគ្មានឪពុក-ម្ដាយទៅជាមួយ ។

**រយៈពេល :** ៣០ នាទី

**សំភារៈ :** ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ឯកសារមេរៀនទី ៦

**វិធីសាស្ត្រ :** សំនួរបំផុសគំនិត បង្ហាញ ពន្យល់ ពិភាក្សាក្រុមតូច

**សកម្មភាពអ្នកសំរបសំរួល :**

**១- មូលហេតុដែលនាំអោយកុមារចាកចេញពីសហគមន៍ :**

- អ្នកសំរបសំរួលចាប់ផ្ដើម ដោយសួរទៅអ្នកចូលរួមថា :

+ តើមានកុមារចាកចេញ ទៅក្រៅសហគមន៍ ដោយគ្មានឪពុក-ម្ដាយទៅជាមួយឬទេ ?

+ តើកុមារចាកចេញពីសហគមន៍ ដោយគ្មានឪពុក-ម្ដាយទៅជាមួយ មានន័យដូចម្ដេចដែរ?

ចំលើយអ្នកចូលរួម :

+ ហេតុអ្វីបានជាកុមារទាំងនោះ ចាកចេញទៅក្រៅសហគមន៍របស់គេ? ចំលើយអ្នកចូលរួមៈ

- អ្នកសំរបសំរួលសរុបចំលើយ ហើយបង្ហាញពន្យល់ឯកសារមេរៀនទី ៦ (ចំណុច ៦.១ : មូលហេតុដែលនាំអោយកុមារចាកចេញពីសហគមន៍ ) ។

**២- ភាពគ្រោះថ្នាក់ :**

- អ្នកសំរបសំរួល អោយអ្នកចូលរួមពិភាក្សាលើសំនួរថា :

+ នៅពេលកុមារចាកចេញពីសហគមន៍ ដោយគ្មានឪពុក-ម្ដាយទៅជាមួយ ជួបប្រទះនឹងគ្រោះថ្នាក់អ្វីខ្លះ? កត់ត្រាចំលើយ

- អ្នកសំរបសំរួលបង្ហាញពន្យល់ ឯកសារមេរៀនទី ៦ (ចំណុច ៦.២ : ភាពគ្រោះថ្នាក់ )

**៣- ដំណោះស្រាយ :**

- អ្នកសំរបសំរួល បែងចែកសិក្ខាកាមជា ៣ក្រុម ដើម្បីពិភាក្សា :

១- ករណីកុមាររត់ចេញពីផ្ទះ តើត្រូវដោះស្រាយយ៉ាងដូចម្ដេច?

២- ករណីកុមារចាកចេញពីផ្ទះទៅរកការងារធ្វើ តើត្រូវដោះស្រាយយ៉ាងដូចម្ដេច?

៣- ករណីកុមារត្រូវគេបោកប្រាស់ យកចេញទៅក្រៅសហគមន៍ តើត្រូវដោះស្រាយយ៉ាងដូចម្ដេច?

+ តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សា

+ អ្នកសំរបសំរួលបូកសរុបលទ្ធផល ហើយបង្ហាញ និងពន្យល់ឯកសារមេរៀនទី ៦ (ចំណុច ៦.៣ ដំណោះស្រាយ )

+ អ្នកសំរបសំរួលបង្ហាញឯកសារ៦.១ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយសុំអោយអ្នកចូលរួមបន្ថែមសកម្មភាពទៀត ។

# ប្លង់មេរៀនទី ៧
# កុមារពិការ

~ **គោលបំណង :**

- ដឹងពីអត្តសញ្ញាណ នៃពិការភាពរបស់កុមារ
- ដឹងពីភាពរងគ្រោះ និងការឆ្លើយតបចំពោះកុមារពិការ
- ចាត់វិធានការសមស្រប

~ **រយៈពេល :៣០នាទី**

~ **សំភារៈ** : ក្រដាសផ្ទាំងធំ ស្កុត ហ្វឺត ឯកសារមេរៀនទី៧

~ **វិធីសាស្ត្រ** : បិតតាតពិណ សំណួរបំផុស បង្ហាញ ពន្យល់

~ **សកម្មភាពសម្របសម្រួល :**

**១- និយមន័យ :**

\+ អ្នកសម្របសម្រួលសួរទៅកាន់អ្នកចូលរួមថា :

• តើកុមារពិកាមានន័យដូចម្តេច? ចម្លើយរួមមាន :

\+ អ្នកសម្របសម្រួលបង្ហាញនិយមន័យ

**២- ប្រភេទ និងលក្ខណៈពិការភាពរបស់កុមារ :**

\+ អ្នកសម្របសម្រួលបន្តសំណួរ

• តើអ្នកធ្លាប់ដឹង នឹងឃើញកុមារពិកាដែរឬទេ? ពិកាលើអ្វីខ្លះ? គត់ត្រាចម្លើយ

\+ អ្នកសម្របសម្រួលបង្ហាញ នឹងពន្យល់មួយចំណុចម្តងៗ ឯកសារមេរៀនទី ៧ ( ចំណុច ៧.១ ប្រភេទ នឹងលក្ខណៈពិការបស់កុមារ)

**៣- ការឆ្លើយតចំពោះកុមារពិកា**

\+ អ្នកសម្របសម្រួលសួរទៅកាន់អ្នកចូលរួមថា:

• តើហេតុអ្វីបានជាកុមារពិកាតែងទទួលរងគ្រោះ? រងគ្រោះព្រោះអ្វី? គត់ត្រាចម្លើយ

• តើត្រូវធ្វើដូចម្តេច ដើម្បីឆ្លើយតបចំពោះកុមារពិកា ? កត់ត្រាចម្លើយ

\+ អ្នកសម្របសម្រួលបង្ហាញឯកសារមេរៀនទី ៧ ( ចំណុច ៧.២ ការឆ្លើយតបចំពោះកុមារពិកា)

\+ អ្នកសម្របសម្រួលបង្ហាញ ( ឯកសារ ៧.១ ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន) ហើយសូមឱ្យអ្នកចូលរួមបន្ថែមសកម្មភាពនានាទៀត ។

## ប្លង់មេរៀនទី ៨
## កុមារទំនាស់នឹងច្បាប់

- **គោលបំណង** :
  - ដឹងពីបញ្ហាកុមារទំនាស់នឹងច្បាប់
  - ចាត់វិធានការ ដើម្បីជួយដល់កុមារទំនាស់នឹងច្បាប់
- **រយៈពេល** **:៣០នាទី**
- **សំភារៈ** : ក្រដាសផ្ទាំងធំ ស្កុត ហ្វឹត រូបភាព ឯកសារមេរៀនទី ៨
- **វិធីសាស្រ្ត** : សំណួរបំផុស បង្ហាញ ពន្យល់
- **សកម្មភាពសម្របសម្រួល** :

+ អ្នកសម្របសម្រួលសួរទៅកាន់អ្នកចូលរួមថា :
• តើកុមារទំនាស់នឹងច្បាប់មានន័យដូចម្តេច? ចម្លើយ
+ អ្នកសម្របសម្រួលបង្ហាញពីនិយមន័យ

**១- ការប្រព្រឹត្តរបស់នគរបាលទៅលើកុមារ**

+ អ្នកសម្របសម្រួលបង្ហាញរូបភាពកុមារទំនាស់នឹងច្បាប់ (រូបភាព) ហើយសួរថា :
• តើអ្នកបានឃើញអ្វីខ្លះក្នុងរូបភាពនិមួយៗ
• តើរូបភាពនិមួយៗមានអត្ថន័យដូចម្តេច? កត់ត្រាចម្លើយ
+ អ្នកសម្របសម្រួល បង្ហាញឯកសារមេរៀនទី ៨ (ចំណុច ៨.១ ការប្រព្រឹត្តរបស់នគរបាលទៅលើកុមារ)

**២- ការជុំនុំជំរះក្តី និងការឃុំខ្លួន**

+ អ្នកសម្របសម្រួល បង្ហាញ និងពន្យល់មួយចំណុចម្តងៗ ឯកសារមេរៀនទី ៨ (ចំណុច ៨.២ ការជុំនុំជំរះរឿងក្តី និងការឃុំខ្លួន) និងបន្តទៅ (ចំណុច ៨.៣ ចំណុចគួរចងចាំ)
+ អ្នកសម្របសម្រួលបង្ហាញ (ឯកសារ ៨.១ ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន) ហើយសុំឱ្យអ្នកចូលរួមបន្ថែមសកម្មភាពនានាទៀត ។